# សេចក្ដីអធិប្បាយពីសៀវភៅរបស់យ៉ាកុប



# សេចក្ដីអធិប្បាយពីសៀវភៅរបស់យ៉ាកុប

សំបុត្រយ៉ាកុប ជាបាវបំរើរបស់ព្រះ ហើយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ខ្ញុំផ្ញើមកជំរាបសួរដល់ពូជអំបូរទាំង១២ ដែលត្រូវខ្ចាត់ខ្ចាយ។

**១:១**សំណួរទីមួយដែលយើងភាគច្រើននឹងចោទសួរនៅពេលដែលយើងចាប់ផ្ដើមអានសំបុត្រមួយនេះនោះគឺ តើលោកយ៉ាកុបជានរណា? គាត់បានណែនាំខ្លួនគាត់អោយយើងបានស្គាល់នៅក្នុងខទី១ ប៉ុន្តែរឿងដែលគួរអោយចាប់អារម្មណ៍បំផុតនោះគឺ អ្វីដែលគាត់មិនបាននិយាយអំពីខ្លួនគាត់។ លោកយ៉ាកុបគឺជាប្អូនប្រុសរបស់ព្រះយេស៊ូវ។ ដូច្នេះ លោកយ៉ាកុបបានស្គាល់ព្រះយេស៊ូវពេញមួយជីវិតរបស់គាត់។ គាត់បានធំលូតលាស់ឡើងជាមួយព្រះយេស៊ូវ!

កាលដែលព្រះយេស៊ូវបានចាប់ផ្ដើមព័ន្ធកិច្ចរបស់ទ្រង់ លោកយ៉ាកុបមិនមែនជាសាវ័ករបស់ព្រះយេស៊ូវនោះទេ ប៉ុន្តែព្រះយេស៊ូវទ្រង់មានផែនការសម្រាប់គាត់។ បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ ព្រះយេស៊ូវបានបង្ហាញខ្លួនអោយលោកយ៉ាកុបឃើញ។ បន្ទាប់មកលោកយ៉ាកុបបានចូលរួមជាមួយ ក្រុមពួកសាវ័ករបស់ព្រះយេស៊ូវនៅក្រុងយេរូសាឡឹម។ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធបានយាងចុះមកនៅថ្ងៃបុណ្យទី៥០ ក្នុង គ.ស. ៣៣ លោកពេត្រុសបានអធិប្បាយពីដំណឹងល្អ ហើយមនុស្សចំនួន៣០០០នាក់បានទទួលជឿលើព្រះយេស៊ូវ។ នេះហើយជាការចាប់ផ្ដើមក្រុមជំនុំដំបូងគេបង្អស់។ លោកយ៉ាកុបបានក្លាយជាអ្នកដឹកនាំរបស់ពួកជំនុំ។ ហើយយើងអាចមើលឃើញយ៉ាងច្បាស់នៅក្នុងក្រុមប្រឹក្សា-ក្រុងយេរូសាឡឹមនៅក្នុង គ.ស ៤៩។ ពួកក្រុមចាស់ទុំនិងពួកសាវ័កបានជួបជុំគ្នា ដើម្បីដោះស្រាយបញ្ហាសំខាន់មួយទាក់ទងនឹងពួកសាសន៍ដទៃ។ បន្ទាប់ពីការពិភាក្សាជាច្រើនមក លោកយ៉ាកុបគឺជាអ្នកដែល

បានសម្រេចចិត្តនិងវិនិច្ឆ័យថាតើត្រូវធ្វើយ៉ាងណា (កិច្ចការ ១៥:១៣-២១)។ ហើយការវិនិច្ឆ័យរបស់គាត់ក៏ត្រូវបានបញ្ជូនទៅគ្រប់ក្រុមជំនុំទាំងអស់។ ត្រង់ចំណុចនេះបានបង្ហាញពីសិទ្ធិអំណាចដែលលោកយ៉ាកុបមានចំពោះពួកជំនុំដើម។

ហេតុនេះ លោកយ៉ាកុបជាប្អូនប្រុសរបស់ព្រះយេស៊ូវ ហើយក៏ជាអ្នកដឹកនាំនៃពួកជំនុំដើមបង្អស់ផង ដែរ។ ប៉ុន្តែយើងកត់សម្គាល់ឃើញថា គាត់មិនបានណែនាំខ្លួនគាត់អំពីការពិតដ៏អស្ចារ្យទាំងនេះទេ។ ផ្ទុយទៅវិញគាត់ហៅខ្លួនឯងថាជា **«បាវបម្រើរបស់ព្រះ ហើយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ»**។ ពាក្យដែលគាត់ប្រើដើម្បីពិពណ៌នាអំពីខ្លួនគាត់នោះគឺ (δoῦλoς) គាត់ជាមនុស្សម្នាក់ដែលត្រូវបាន ជ្រើសរើស ត្រូវបានទិញ ហើយឥឡូវនេះក្លាយជាកម្មសិទ្ធិរបស់ចៅហ្វាយ។ សេចក្តីទាំងនេះបានពណ៌នាយ៉ាងល្អពីជីវិតរបស់យើងដែលជាគ្រីស្ទបរិស័ទ។ ព្រះបានជ្រើសរើសយើង បន្ទាប់មក ព្រះយេស៊ូវបានប្រោសលោះយើង ហើយឥឡូវនេះយើងក្លាយជាកម្មសិទ្ធិរបស់ទ្រង់។ ហើយនេះក៏ជាអ្វីដែលនឹង កំណត់ពីអត្តសញ្ញាណថ្មីនៃជីវិតរបស់យើងចាប់ពីពេលនេះតទៅ។ ការពិតដ៏អស្ចារ្យបំផុតអំពីពួកយើងម្នាក់ៗ នោះគឺយើងជាកម្មសិទ្ធិរបស់ព្រះ។ ដូច្នេះ នេះហើយជារបៀបដែលលោកយ៉ាកុបបានណែនាំអំពីខ្លួន គាត់។

សំបុត្រនេះទំនងជាត្រូវបានសរសេរឡើងចន្លោះ គ.ស .៤០ និង គ. ស ៤៨ ។ នេះមានន័យថា វាគឺជាសៀវភៅដែលបានសរសេរឡើងដំបូងគេបង្អស់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ វាត្រូវបានសរសេរឡើងដើម្បីផ្ញើទៅកាន់ពួកគ្រីស្ទបរិស័ទជនជាតិយូដា (មូលហេតុនៃការប្រើពាក្យ «ពូជអំបូរទាំង១២») ដែលបានរត់ភៀសខ្លួនចេញពីទីក្រុងយេរូសាឡឹមដោយសារតែមានការបៀតបៀន។ ឥឡូវពួកគេត្រូវរស់នៅបែកខ្ញែកគ្នាពាសពេញចក្រភពរ៉ូម។ លោកយ៉ាកុប គឺជាគ្រូគង្វាលរបស់ពួកគេកាលដែលពួកគេរស់នៅក្រុង

យេរូសាឡឹមនៅឡើយ ហេតុដូច្នេះហើយ គាត់ស្គាល់ពួកគេយ៉ាងច្បាស់។ គាត់ស្វាគមន៍ពួកគេតាមបែប សាមញ្ញដែលមានន័យថា "ចូរអរសប្បាយ" ។

## ការល្បងល

បងប្អូនអើយ កាលណាអ្នករាល់គ្នាមានសេចក្ដីល្បួងផ្សេងៗ នោះត្រូវរាប់ជាសេចក្ដីអំណរសព្វគ្រប់វិញ

**១:២** ជីវិតគឺពោរពេញទៅដោយការលំបាក។ ពាក្យនៅក្នុងភាសាក្រិកដែលលោកយ៉ាកុបប្រើនោះ (πειρασμός) មានន័យថា ការល្បងល ការធ្វើតេស្តសេចក្ដីជំនឿ និងសេចក្ដីល្បួង។ លោកយ៉ាកុបដឹងថា អ្នកអានសំបុត្ររបស់គាត់គឺកំពុងតែជួបប្រទះទុក្ខលំបាកជាច្រើន។ ពីមុនកាលនៅក្រុងយេរ៉ូសាឡឹម ពួកគេបានជួបជុំគ្នារាល់ថ្ងៃ ចែករំលែកអ្វីៗគ្រប់យ៉ាង និងចម្រើនឡើងក្នុងការស្គាល់ព្រះ និង សេចក្ដី ស្រឡាញ់របស់ព្រះ (កិច្ចការ ២:៤២-៤៧) ។ បន្ទាប់មក លោកស្ទេផានត្រូវបានគេគប់នឹងដុំថ្មរហូតដល់ ស្លាប់ដោយសារតែជំនឿរបស់គាត់ចំពោះព្រះយេស៊ូវ (កិច្ចការ ៦:៨-៧:៦០)។ នៅថ្ងៃនោះដែរក៏កើត មានការបៀតបៀនជាខ្លាំងទាស់ប្រឆាំងនឹងពួកជំនុំ។ លោកសុលបានចូលឆែកឆេរគ្រប់ផ្ទះទាំងអស់ ដើម្បីចាប់ទាញអូសគ្រីស្ទបរិស័ទបញ្ជូនទៅដាក់គុក (កិច្ចការ ៨:១-៣)។ គ្រីស្ទបរិស័ទទាំងអស់ដែល លើកលែងតែពួកសាវ័ក បានរត់ភៀសខ្លួនចេញពីក្រុងយេរូសាឡឹម។

នៅក្នុងស្ថានភាពដ៏លំបាកនេះ លោកយ៉ាកុបបានប្រាប់ពួកគេអំពីការត្រៀមចិត្តជាមុននៅពេលដែលពួកជួបការល្បងល។ គាត់បានប្រាប់អោយពួកគេ <**រាប់វាជាសេចក្ដីអំណរវិញ**>។ ចូរធ្វើការសំរេចចិត្តឥឡូវនេះថា អ្នកនឹងមានសេចក្ដីអំណរនៅពេលដែលអ្នកជួបប្រទះការល្បងល។ យើងប្រហែលជាគិត

ថា ប្រសិនបើជីវិតរបស់យើងគ្មានទុក្ខលំបាកនោះទេ នោះយើងនឹងមានសេចក្តីអំណរ។ ប៉ុន្តែលោក យ៉ាកុប បាននិយាយថា យើងនៅតែអាចមានសេចក្តីអំណរ បើទោះជាយើងជួបប្រទះការល្បងល ក៏ដោយ។

គួរកត់សម្គាល់ថា វាជាសេចក្តីអំណរសព្វគ្រប់វិញ។ វាមិនមែនមានន័យថា មានសេចក្តីអំណរខ្លះ ទុក្ខក្រៀមក្រំខ្លះ មួម៉ៅខ្លះ និង ខឹងសម្បាខ្លះនោះទេ។ តើវាអាចទៅរួចដោយរបៀបណាដែលថាយើង នឹងមានសេចក្តីអំណរនៅពេលដែលយើងជួបប្រទះទុក្ខលំបាក? ចម្លើយរបស់វានោះគឺមាននៅក្នុងពាក្យ ដែលបានបកប្រែថា "រាប់" (ἡγήσασθε)។ វាគឺជាពាក្យដែលគេប្រើនៅក្នុងភាសាគណនេយ្យ ហើយ វាមានន័យថា "បូកបញ្ចូលទាំងអស់" ។ នៅក្នុងប្រព័ន្ធគណនេយ្យ អ្នកបូកបញ្ចូលអ្វីដែលអ្នកចំណេញ ហើយដកចេញអ្វីដែលអ្នកខាត ដើម្បីអោយយើងដឹងថាតើយើងខាតឬមួយចំណេញ។ ស្រដៀងគ្នានេះ ដែរប្រសិនបើយើងបូកបញ្ចូលលទ្ធផលវិជ្ជមានទាំងអស់ដែលយើងអាចទទួលបានក្នុងកាលដែលយើងជួ បប្រទះការល្បងល នោះយើងនឹងឃើញថា វាគឺពិតជាមានតម្លៃនៅក្នុងជួបជាមួយការល្បងល។ តើយើងនឹងទទួលបានផលចំណេញអ្វីខ្លះនៅពេលដែលយើងឆ្លងកាត់ការល្បងល? លោកយ៉ាកុបបាន ប្រាប់យើងនៅក្នុង២ខបន្ទាប់ពីនេះ។

ដោយដឹងថា ការល្បងលមើលសេចក្តីជំនឿនៃអ្នករាល់គ្នា នោះនាំបង្កើតឲ្យមានសេចក្តីខ្ជាប់ខ្ជួន

**១:៣** ជំនឿគឺជាការទុកចិត្តលើព្រះ។ យើងទុកចិត្តលើចរិតលក្ខណៈរបស់ទ្រង់ ព្រះបន្ទូលរបស់ទ្រង់ (ព្រះគម្ពីរ) ផែនការរបស់ទ្រង់ និង ការសន្យារបស់ទ្រង់។ ពេលដែលយើងឆ្លងកាត់ទុក្ខលំបាក យើងត្រូវ តែសំរេចចិត្តថាយើងនឹងនៅតែបន្តទុកចិត្តលើព្រះអង្គ។ ការល្បងលនឹងល្បងតេស្តសេចក្តីជំនឿរបស់

យើង។ ការល្បងលជំនឿរបស់យើង គឺមិនមែនធ្វើអោយយើងបរាជ័យនោះទេ។ ពាក្យ **“ការល្បងល”** (តេស្ត) (δοκίμιον) មានន័យថា ល្បងតេស្តមើលដើម្បីបញ្ជាក់អះអាងថាពិតឬត្រឹមត្រូវ។ ពាក្យនេះត្រូវបានគេប្រើសម្រាប់ធ្វើតេស្តលើលោហៈដើម្បីបញ្ជាក់ថាវាជារបស់ពិត ឬ អត់។

យើងស្រមៃថាឈ្មួញពីរនាក់។ ឈ្មួញម្នាក់គាត់លក់មាសក្លែងក្លាយ។ ហើយគាត់មិនចង់អោយនរណាម្នាក់ធ្វើតេស្តលើមាសរបស់គាត់នោះទេ ពីព្រោះមនុស្សគ្រប់គ្នានឹងដឹងថា មាសរបស់គាត់គឺជាមាសក្លែងក្លាយ។ ចំណែកឈ្មួយម្នាក់ទៀតគាត់លក់មាសពិតប្រាកដ។ គាត់ស្វាគមន៍ចំពោះមនុស្សគ្រប់គ្នាដែលចង់ធ្វើតេស្តមាសរបស់គាត់ ព្រោះការធ្វើតេស្តនឹងបង្ហាញអោយគេគ្រប់គ្នាឃើញ ពីតម្លៃពិតប្រាកដចំពោះរបស់ដែលគាត់មាន។ ដូច្នេះហើយ ប្រសិនបើជំនឿរបស់យើងជាជំនឿពិតប្រាកដនោះការល្បងលនឹងបង្ហាញអោយយើងបានឃើញ។ ជំនឿរបស់យើងគឺប្រៀបបានដូចជាមាស ហើយការល្បងលប្រៀបបានដូចជាភ្លើង។ មាសត្រូវបានបន្សុទ្ធដោយភ្លើង។ នៅពេលដែលយើងឆ្លងកាត់ការល្បងលដោយមានការទុកចិត្តលើព្រះ ទុក្ខលំបាកនឹងល្បងល បញ្ជាក់អោយឃើញចម្រើនកម្លាំង និង បន្សុទ្ធជំនឿរបស់យើង។

ចរិតលក្ខណៈពិតប្រាកដនៃជំនឿដែលនឹងត្រូវបានចម្រើនឡើងតាមរយៈការឆ្លងកាត់នូវការល្បងលនោះគឺ **សេចក្ដីខ្ជាប់ខ្ជួន**។ សេចក្ដីខ្ជាប់ខ្ជួន (ὑπομονήν) គឺជាសេចក្ដីអត់ធន់ដែលវាប្រៀប ដូចជាពេលយើងរត់ម៉ារ៉ាតុង ហើយយើងសម្រេចចិត្តថាយើងនឹងរត់អោយដល់ទី។ ព្រះយេស៊ូវបានប្រើពាក្យនេះនៅក្នុងរឿងប្រស្នារបស់អ្នកសាបព្រោះ ដើម្បីពណ៌នាអំពីគ្រាប់ពូជដែលបង្កើតផល (លូកា ៨:១៥)។ គ្រាប់ពូជស៊ូអត់ធន់ឆ្លងកាត់គ្រប់ដំណាក់កាលនៃដំណើរការដែលចាំបាច់ ដើម្បីបង្កើតជាផលផ្លែ។

ពាក្យថា "សេចក្តីខ្ជាប់ខ្ជួន" នៅក្នុងភាសាក្រិកមានន័យថា "ឋិតនៅក្រោម" ។ វាគឺជាលក្ខណៈអមួយ ដែលអ្នកមានការអភិវឌ្ឍន៍ខ្លួននៅពេលដែលអ្នកកំពុងស្ថិតនៅក្រោមបន្ទុកដ៏ធ្ងន់ ហើយអ្នករើសយក ការឋិតនៅក្រោមបន្ទុកនោះ ជាជាងការព្យាយាមរត់គេចចេញពីវា។ ពេលយើងឋិតនៅក្នុងស្ថានភាព លំបាកវាបង្កើតអោយមានជាសេចក្តីអត់ធន់។ ក៏ប៉ុន្តែយើងត្រូវតែជ្រើសរើសឋិតនៅក្រោមការលំបាក ដោយឈរនៅលើសេចក្តីជំនឿ។ ប្រសិនបើយើងឆ្លើយតបទៅកាន់ទុក្ខលំបាកដោយការសង្ស័យចំពោះ ព្រះ ការរអ៊ូរទាំ ឬភាពទន់ជ្រាយនោះ វានឹងបង្កើតទៅជាសេចក្តីជូរល្វីង ការបាក់ទឹកចិត្ត និង ភាពក្មេង ខ្ចីវិញ គឺមិនមែនជាសេចក្តីអត់ធន់នោះឡើយ។ អត្ថប្រយោជន៍ដែលយើងនឹងទទួលបានពីស្ថានភាព លំបាក គឺវាអាស្រ័យទៅលើការឆ្លើយតបរបស់យើងក្នុងវេលាដែលយើងកំពុងឆ្លងកាត់ការល្បងល ទាំងនោះ។

ចូរទុកឲ្យសេចក្តីខ្ជាប់ខ្ជួននោះ បានធ្វើការឲ្យសំរេចពេញលេញចុះ ដើម្បីឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ហើយពេញខ្នាតឥតខ្វះអ្វីឡើយ

**១:៤** ហេតុអ្វីបានជាសេចក្តីអត់ធន់វាមានតម្លៃរហូតដល់អាចធ្វើអោយមានសេចក្តីអំណរនៅក្នុងពេល ដែលយើងជួបជាមួយនឹងការល្បងល? ពីព្រោះសេចក្តីអត់ធន់វានាំយើងអោយក្លាយទៅជា "**បានគ្រប់លក្ខណ៍ ហើយពេញខ្នាត ឥតខ្វះអ្វីឡើយ**" ។ ត្រង់ចំណុចនេះបានបង្ហាយអោយយើងឃើញថា វាពិតជាមានអ្វីអស្ចារ្យដែលយើងអាចនឹងទទួលបាន ជាជាងយើងគ្រាន់តែឲ្យយើងធ្វើយ៉ាងម៉េចអោយ តែឆ្លងផុតពីការល្បងលនោះ។ តាមរយៈការល្បងលនៅក្នុងជីវិតរបស់យើង យើងនឹងត្រូវបានក្លាយទៅជាគ្រប់លក្ខណ៍ និង ពេញខ្នាតដោយសារតែព្រះជាម្ចាស់។

ផែនការរបស់ព្រះសម្រាប់អ្នកជឿគ្រប់រូបគឺ នៅថ្ងៃណាមួយយើងទាំងអស់គ្នានឹងដូចព្រះយេស៊ូវ (ភីលីព ៣:១០-១១; រ៉ូម ៨:២៩; យ៉ូហាន ១:១-៣)។ ទុក្ខលំបាកការល្បងល ចាំបាច់ត្រូវកើតឡើង ដើម្បីធ្វើឲ្យការនេះអាចសម្រេច។ ទុក្ខលំបាកការល្បងល អភិវឌ្ឍចរិតលក្ខណៈរបស់យើងឲ្យ ដូចព្រះគ្រីស្ទ ដោយល្បងលពីជំនឿរបស់យើង និងជម្រុញអោយមានការជំនះតស៊ូ។ ហើយនៅថ្ងៃណាមួយនេះវានឹងធ្វើអោយយើងមានភាព**ចាស់ទុំ** និងពេញខ្នាតដូចព្រះយេស៊ូដែរ។ នៅចុងបញ្ចប់យើងមិនមានការខ្វះខាតផ្នែកណាមួយនៃចរិតលក្ខណៈរបស់ព្រះគ្រីស្ទឡើយ។ នេះគឺជាមូលហេតុនៃសេចក្តីអំណរសម្រាប់អស់អ្នក ដែលចង់ក្លាយដូចជាព្រះយេស៊ូវ។ ឥឡូវយើងឃើញថាលោកយ៉ាកុបបានប្រាប់មកកាន់យើងថា “ត្រូវរាប់ជាសេចក្តីអំណរសព្វគ្រប់វិញ” នៅពេល យើងជួបក ការល្បងលផ្សេងៗ ព្រោះថាការទាំងនោះធ្វើឲ្យយើងមានភាពចាស់ទុំ និង មានភាពពេញខ្នាត។

ការល្បងល ⇨ ល្បង (តេស្ត) សេចក្តីជំនឿ ⇨ បង្កើតឲ្យមានសេចក្តីខ្ជាប់ខ្ជួន(អត់ធន់តស៊ូ)

⇩

**ធ្វើឲ្យយើងមានភាពចាស់ទុំ និង ពេញខ្នាត**

ការល្បងលតែងតែមានមូលហេតុ ហើយជារឿយៗវាមានការពាក់ព័ន្ធជាមួយនឹងអំពើអាក្រក់របស់មនុស្ស។ ទោះយ៉ាងណាក៏ដោយ យើងត្រូវតែមើលអោយហួសពីបុព្វហេតុរបស់មនុស្ស ទៅកាន់សំនួរធំជាងនេះ ថាហេតុអ្វីបានជាព្រះអោយរាស្ត្ររបស់ទ្រង់ប្រឈមមុខនឹងការសាកល្បងទាំងនេះ។ មូលហេតុគឺដើម្បីអភិវឌ្ឍចរិតលក្ខណៈនៅក្នុងខ្លួនយើងអោយដូចព្រះគ្រីស្ទ។ នៅក្នុងការល្បងល អ្វីដែលមនុស្សមានបំណងសម្រាប់ការអាក្រក់ នោះព្រះទ្រង់មានបំណងសម្រាប់ការល្អវិញ (លោកុប្បត្តិ ៥០:២០)។

ចូរទុកចិត្តទៅកាន់សេចក្តីស្រលាញ់ និង អធិរាជភាពរបស់ទ្រង់ ដោយជឿថាទ្រង់នឹងប្រើប្រាស់ការល្បងលនៅក្នុងជីវិតរបស់អ្នក សម្រាប់គោលបំណងល្អ ដែលទ្រង់មានស្រមាប់អ្នក។

តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ

**១:៥** ពេលខ្លះវាមានអារម្មណ៍ថាការល្បងលទាំងនោះកំពុងធ្វើឲ្យយើងមានអារម្មណ៍លើសលប់។ ប្រហែលជាយើងបារម្ភថា ជំនឿរបស់យើងនឹងមិនអាចឆ្លងកាត់ការល្បងលបានទេ។ តើយើងគួរធ្វើអ្វី? ចម្លើយគឺ យើងត្រូវសុំប្រាជ្ញាមកពីព្រះ។ ការមានប្រាជ្ញា គឺជាការដឹងនិងធ្វើអ្វីដែលគាប់ព្រះហឫទ័យទៅកាន់ព្រះ។ មានតែព្រះដែលទ្រង់ជាអ្នកអាចផ្តល់ឱ្យយើងនូវអំណោយទានប្រាជ្ញានេះ ហើយទ្រង់ផ្តល់វាអោយដល់អស់អ្នកណាដែលសុំពីទ្រង់។ យើងត្រូវសុំប្រាជ្ញាពីទ្រង់ជាទៀងទាត់ នោះយើងនឹងដឹងថាអ្វីដែលល្អបំផុតដែលត្រូវធ្វើក្នុងគ្រប់ស្ថានភាពនៃជីវិតរបស់យើង។ នៅពេលយើងទូលសុំប្រាជ្ញាពីព្រះទ្រង់នឹងប្រទានអោយដោយមិនចាប់កំហុសរបស់យើង។ ហើយទ្រង់ក៏នឹងមិនបន្ទោសយើងឡើយចំពោះការដែលយើងគ្មានប្រាជ្ញាមកពីខ្លួនឯង ឬការខ្វះប្រាជ្ញាផ្សេងៗ ដែលនាំអោយយើងធ្លាក់ខ្លួនមកក្នុងស្ថានភាពដែលយើងកំពុងឋិតនៅនោះទេ។

តែត្រូវឲ្យអ្នកនោះសូមដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ ដ្បិតអ្នកណាដែលសង្ស័យ នោះប្រៀបដូចជារលកសមុទ្រដែលត្រូវផាត់ដោយខ្យល់ ទាំងរំពើកចុះឡើង

**១:៦** អំណោយទាននៃប្រាជ្ញាគឺមានសម្រាប់មនុស្សទាំងអស់ ប៉ុន្តែ មានល័ក្ខខណ្ឌ។ នៅពេលយើងទូលសុំប្រាជ្ញាពីព្រះយើងត្រូវតែជឿថា ព្រះទ្រង់សណ្តាប់សេចក្តីអធិស្ឋានរបស់យើង ហើយទ្រង់នឹងប្រទានប្រាជ្ញាដល់យើង។ ព្រះនឹងមិនឆ្លើយតបនឹងការអធិស្ឋានរបស់អស់អ្នកណាដែលមានការសង្ស័យលើទ្រង់ឡើយ។ ជំនឿបង្កើតអោយមានទំនាក់ទំនងជាមួយព្រះ។ ការសង្ស័យបំផ្លាញទំនាក់ទំនងនេះវិញ។ រលកសមុទ្រត្រូវបានផាត់ដោយសារខ្យល់ ទាំងរំពើកចុះឡើង។ លោកយ៉ាកុប បាននិយាយថាមនុស្ស ដែលមានការសង្ស័យគឺជាមនុស្សដែលសាវ៉ា ប្រៀបដូចជារលកទាំងនោះដែរ។

កុំឲ្យមនុស្សយ៉ាងនោះនឹកស្មានថា ខ្លួននឹងបានអ្វីពីព្រះអម្ចាស់ឡើយ ដ្បិតអ្នកនោះជាមនុស្សមានចិត្ត២ចេះតែសាវ៉ាក្នុងគ្រប់ទាំងផ្លូវ។

**១:៧-៨** អស់អ្នកដែលមានការសង្ស័យទៅលើព្រះ នឹងមិនទទួលបានប្រាជ្ញាពីទ្រង់ឡើយ។ លោកយ៉ាកុបបានប្រើពាក្យមួយដោយចំៗ សម្រាប់មនុស្សដែលមានការសង្ស័យច្រើន (δίψυχος) ថាជាមនុស្ស "ចិត្តពីរ" ។ ពាក្យនេះមិនមាននៅក្នុងអក្សរសាស្ត្រក្រិកទេ។ ប្រហែលជា លោកយ៉ាកុបបានបង្កើតពាក្យដោយខ្លួនឯង។ ខ្លឹមសារសំខាន់ គឺថាមនុស្សមានការសង្ស័យ គឺដោយសារតែពួកគេមានគំនិតពីរផ្ទុយគ្នាក្នុងការគិតរបស់ពួកគេ ហើយពួកគេមិនអាចជ្រើសរើសបានថា តើគំនិតមួយណាគឺជា គំនិតត្រឹមត្រូវឡើយ។ ពួកគេអាចជឿមួយរំពេច ហើយពេលក្រោយពួកគេលែងជឿក៏អាចថាបាន។

ត្រូវឲ្យបងប្អូនណា ដែលមានសណ្ឋានទាបថោកបានត្រេកអរ ដោយបានដំកើងឡើង

**១:៩** ដោយសារការល្បងលដែលពួកយើងកំពុងជួបប្រទះ បានធ្វើអោយអ្នកអានរបស់លោកយ៉ាកុប ជាច្រើននាក់កាន់តែក្រលំបាកទៅៗ ។ លោកយ៉ាកុបបានលើកទឹកចិត្តពួកគេ។ ពួកគេប្រហែលជាមិន មានទ្រព្យសម្បត្តិច្រើនទេ ក៏ប៉ុន្តែពួកគេគឺជាអ្នកមាននៅខាងផ្នែកព្រះពរខាងវិញ្ញាណ។ "ឋានៈខ្ពស់" ដែលពួកគេមាន នោះគឺជាឋានៈដែលពួកគេមាននៅក្នុងព្រះគ្រីស្ទ។ ពួកគេគឺជាកូនស្ងួនភ្ងាដ៏គួរជា ទីស្រឡាញ់របស់ព្រះ ហើយគឺជាអ្នកដែលទទួលបានភាពបរិបូរនៃជីវិតអស់កល្បជានិច្ច។ ទោះបីជា យើងមិនមានអ្វីនៅក្នុងលោកីយ៍នេះក៏ដោយ អ្នកជឿលើទ្រង់អាចអរសប្បាយនឹងឋានៈខាងផ្នែកព្រលឹង វិញ្ញាណដ៏ខ្ពង់ខ្ពស់ដែលគាត់មានដោយសារព្រះគុណរបស់ព្រះជាម្ចាស់ និងក្តីសង្ឃឹមដែលការនោះនាំ មកកាន់ជីវិតរបស់គាត់។

ហើយអ្នកមានត្រូវអរសប្បាយ ដោយត្រូវបន្ទាបចុះវិញ ដ្បិតគេនឹងបាត់ទៅដូចជាផ្កាស្មៅ

**១:១០** ដោយសារតែភាពលោភលន់ និងការបង្រៀនខុសឆ្គង មនុស្សខ្លះគិតថាទ្រព្យសម្បត្តិ គឺជាសញ្ញា នៃការពេញចិត្តរបស់ព្រះ។ ប៉ុន្តែវាមិនមែនជាអ្វីដែលព្រះយេស៊ូវបានបង្រៀនយើងនោះទេ។ អ្នកណា ដែលកំពុងប្រមូលទ្រព្យសម្បត្តិនៅលើផែនដី គឺមានន័យថាពួកគេកំពុងរស់នៅជាមួយជីវិត ដែលមិនគិត អំពីភាពអស់កល្បជានិច្ចនៅក្នុងគំនិតរបស់ពួកគាត់ឡើយ។ លោកយ៉ាកុប ធ្វើការប្រៀបធៀបជីវិតរបស់ បុរសអ្នកមានស្តុកស្តម្ភម្នាក់ទៅនឹង ផ្កាស្មៅ។ ផ្កាស្មៅដុះឡើងយ៉ាងឆាប់រហ័សនៅនិទាឃរដូវ។ ផ្កានោះ មើលទៅដូចជាគួរអោយទាក់ទាញ ប៉ុន្តែវាមានអាយុកាលមិនវែងទេ វានឹងអស់ជីវិតបន្ទាប់ពីនិទាឃរដូវ។

ពីព្រោះថ្ងៃរះឡើង មានចំហាយក្តៅវេលាណា នោះធ្វើឲ្យស្មៅក្រៀមស្វិត ហើយផ្កាក៏រោយរុះ ឯលំអក៏វិនាសសូន្យទៅ ដូច្នេះ អ្នកមានក៏នឹងត្រូវស្រពោនទៅក្នុងផ្លូវខ្លួនយ៉ាងនោះដែរ

**១:១១** នៅប្រទេសអ៊ីស្រាអែល មានខ្យល់ក្តៅយ៉ាងខ្លាំង ដែលបក់ពីវាលខ្សាច់ភាគខាងត្បូងមកលើដែនដី។ ក្នុងរយៈពេលមួយម៉ោង វាអាចធ្វើស្មៅនិងផ្កាទាំងអស់ឆេះ។ នេះប្រៀបដូចនឹងចុងបញ្ចប់នៃជីវិតរបស់អ្នកមាន ដែលវាអាចមកដល់យ៉ាងឆាប់រហ័ស ដោយគ្មានការរំពឹងទុក ឬ ការព្រមានជាមុន។ កន្លែងល្អបំផុតដែលយើងគួរតែមានទ្រព្យសម្បត្តិ គឺនៅឋានសួគ៌ មិនមែននៅផែនដីនោះទេ។ បើទ្រព្យសម្បត្តិយើងនៅលើផែនដី នៅពេលយើងស្លាប់យើង យើងចាកចោលទ្រព្យសម្បត្តិទាំងនោះ។ ប៉ុន្តែបើទ្រព្យសម្បត្តិយើងនៅឋានសួគ៌ ពេលយើងស្លាប់យើង ទ្រព្យសម្បត្តិរបស់យើង នឹងនៅជាមួយយើង។ ការរីករាយជាមួយនឹងទ្រព្យសម្បត្តិរបស់អ្នកមាន នៅផែនដីនេះមិនអាចប្រៀបស្មើនឹងការរីករាយរបស់អ្នកជឿទាំងអស់នឹងមាននៅស្ថានសួគ៌ ដ៏អស់កល្បជានិច្ច។ ដូច្នេះអ្នកក្រដែលស្រឡាញ់ ព្រះជាម្ចាស់ គឺមានទ្រព្យសម្បត្តិច្រើនជាងអ្នកមានបំផុតនៅលើពិភពលោក ដោយព្រោះ ថាអ្នកនោះមិនជឿ ហើយមិនស្រលាញ់ដល់ព្រះ។ ជាជាងតាមស្វែងរកទ្រព្យសម្បត្តិ យើងគួរដើរតាម ព្រះយេស៊ូវ ព្រមទាំងសុខចិត្តលះបង់ដើម្បីជាសិស្សរបស់ទ្រង់ ហើយព្យាយាមស៊ូទ្រាំរាល់ការល្បងល របស់យើង ដោយមានសេចក្តីជំនឿ។

មានពរហើយ មនុស្សណាដែលស៊ូទ្រាំនឹងសេចក្តីល្បួង ដ្បិតកាលណាត្រូវល្បងល ឃើញថាខ្ជាប់ខ្ជួនហើយ នោះនឹងទទួលបានមកុដនៃជីវិត ដែលព្រះអម្ចាស់ទ្រង់សន្យានឹងប្រទានឲ្យដល់អស់អ្នកណាដែលស្រឡាញ់ទ្រង់។

**១:១២** នៅពេលដែលអ្នកមានជំនឿ បានស៊ូជំនះឆ្លងកាត់ការល្បងលរបស់ពួកគេដោយជោគជ័យ ពួកគេនឹងទទួលបានសេចក្តីអំណរដ៏អស្ចារ្យបំផុត។ នេះគឺដោយសារតែនៅពេលដែលពួកគេត្រូវបាន

ឆ្លងកាត់ដោយការល្បងលពួកគេនឹងទទួលបានពរជ័យដែលព្រះបានសន្យាគឺៈ មកុដនៃជីវិត។ ក្នុងពាក្យក្រិក «មកុដ» (στέφανος) គឺជាកម្រងផ្កាដាក់លើក្បាលកីឡាករដែលមានជ័យជំនះ។ មកុដគឺជីវិតដែលអស់កល្បជានិច្ច។ ជីវិតដែលអស់កល្បជានិច្ច គឺជាអំណោយដែលព្រះបានសន្យាដល់អស់អ្នកណាដែលស្រឡាញ់ទ្រង់។ ដូច្នេះអ្វីដែលសំខាន់បំផុតដែលត្រូវធ្វើនៅពេលយើងឆ្លងកាត់ការល្បងលគឺត្រូវបន្តស្រឡាញ់ព្រះ។ បន្តស្រឡាញ់ព្រះ មិនថាមានអ្វីកើតឡើងនៅក្នុងជីវិតរបស់អ្នកទេ នោះអ្នកនឹងទទួលបានជ័យជំនះ។

**សំណួរឆ្លុះបញ្ចាំង**

- តើជាធម្មតា ខ្ញុំឆ្លើយតបទៅនឹង ការល្បងលក្នុងជីវិតខ្ញុំដោយរបៀបណា?

## ព្រះទ្រង់ល្អណាស់

កាលណាមានសេចក្តីល្បួង នោះកុំឲ្យអ្នកណានិយាយថា ព្រះទ្រង់ល្បួងខ្លួនឡើយ ដ្បិតសេចក្តីអាក្រក់ពុំអាចនឹងល្បួងនាំព្រះហឫទ័យព្រះបានឡើយ ហើយព្រះក៏មិនដែលល្បួងអ្នកណាដែរ

**១:១៣** លោកយ៉ាកុប ធ្វើសេចក្តីថ្លែង២សំខាន់អំពីព្រះ។

· **គ្មានអ្វីអាចល្បួងព្រះអង្គឲ្យធ្វើការអាក្រក់បាននោះឡើយ។** ការអាក្រក់មិនអាចជះឥទ្ធិពល ឬ មានអំណាច មកលើព្រះអង្គបាននោះឡើយ។

•**ព្រះមិនដែលល្បួងអោយមនុស្សធ្វើអំពើអាក្រក់ឡើយ។** ព្រះអង្គមិនមែនជាប្រភពនៃសេចក្តីល្បួង ឬ ជាមូលហេតុធ្វើឲ្យមនុស្សធ្វើការអាក្រក់នោះឡើយ។

តែដែលគ្រប់គ្នាកើតមានសេចក្តីល្បួង នោះគឺដោយសារតែសេចក្តីប៉ងប្រាថ្នារបស់ខ្លួននាំប្រទាញ ហើយលួងលោមទេ

**១:១៤** សេចក្តីល្បួងគឺកើតចេញពី សេចក្តីប៉ងប្រាថ្នា ដែលពេញដោយអំពើបាបរបស់យើង។ ប្រសិនបើសេចក្តីប្រាថ្នារបស់យើងបរិសុទ្ធ នោះសេចក្តីល្បួងគ្មានអំណោចមកលើយើងនោះទេ ដូចដែលវាគ្មានអំណាចលើព្រះយេស៊ូវដែរ។ សេចក្តីប៉ងប្រាថ្នាអាក្រក់របស់យើង លួងលោម បោកបញ្ឆោត និងទាញយើងឲ្យធ្លាក់ទៅក្នុងគ្រោះថ្នាក់។ ពាក្យក្រិកដែល លោកយ៉ាកុបប្រើ គឺជាពាក្យដែលត្រូវបានប្រើនៅក្នុង វិធីប្រមាញ់សត្វ។ “ទាញចេញ” <នាំប្រទាញ> (ἐξελκόμενος) ពណ៌នាអំពីការល្បួងអោយសត្វចូលទៅក្នុងអន្ទាក់; “លួងលោម” (δελεαζόμενος) គឺចាប់យកសត្វដោយនុយ។ អន្ទាក់នុយទាក់ទាញអោយសត្វរត់រកសេចក្តីស្លាប់ វាដូចនឹងសេចក្តីប្រាថ្នារបស់យើងដែរ វាទាញយើងអោយស្វែងរកអ្វីដែលប្រកបដោយគ្រោះថ្នាក់ ។ នៅពេលដែលយើងត្រូវសេចក្តីល្បួង យើងកំពុងគិតថាវាជាសេចក្តីរីករាយ ប៉ុន្តែការពិតគឺយើងកំពុងនៅក្នុងគ្រោះថ្នាក់ ហើយយើង គឺជាជនរងគ្រោះ។

រួចកាលណាសេចក្តីប៉ងប្រាថ្នាជាប់មានជាផ្ទៃ នោះសំរាលចេញមកជាអំពើបាប ហើយកាលណាបាបបានពោរពេញឡើង នោះក៏បង្កើតជាសេចក្តីស្លាប់។

**១:១៥** នៅពេលដែលយើងជួបសេចក្តីល្បួង វាមិនមែនជាអំពើបាបទេ តែបើយើងអនុញ្ញាតឲ្យសេចក្តីប៉ងប្រាថ្នាអាក្រក់ លួងលោមអូសទាញយើងបាន នោះយើងនឹងធ្លាក់ចូលក្នុងអំពើបាប។ អំពើបាបគឺជាលទ្ធផលនៃដំណើរការមួយ។ លោកយ៉ាកុបបានពណ៌នាពីការនេះ ដូចជាដំណាក់កាលនៃជីវិត។ មាន

ការចាប់កំណើតការកើត និងការស្លាប់។ រួចកាលណាសេចក្ដីប៉ងប្រាថ្នាជាប់មាននៅក្នុងផ្ទៃ នោះនឹងសំរាលចេញមកជាអំពើបាប ហើយកាលណាបាបបានពោរពេញឡើង នោះក៏បង្កើតជាសេចក្ដីស្លាប់។

**សេចក្ដីប៉ងប្រាថ្នា → សេចក្ដីល្បួង → អំពើបាប → សេចក្ដីស្លាប់**

សេចក្ដីប៉ងប្រាថ្នាខុសឆ្គងរបស់យើង លួងលោមនិងទាញឲ្យយើងធ្លាក់ក្នុងការល្បួង។ ប្រសិនបើយើងបរាជ័យក្នុងការទប់ទល់ជាមួយនឹងសេចក្ដីល្បួង នោះយើងនឹងប្រព្រឹត្តអំពើបាប។ ប្រសិនបើអំពើបាបនៅបន្តនៅក្នុងជីវិតរបស់មនុស្សណាម្នាក់ដោយមិនមានការប្រែចិត្តនោះទេ វានឹង បណ្ដាលឱ្យមានសេចក្ដីស្លាប់ដ៏អស់កល្បជានិច្ច។ នេះគឺជាការផ្ទុយជាមួយនឹង សេចក្ដីជំនឿដែលមានការតស៊ូ ហើយនាំឆ្ពោះទៅកាន់មកុដនៃជីវិត។

## បងប្អូនស្ងួនភ្ងាររបស់ខ្ញុំអើយ កុំឲ្យត្រូវបំភាន់ឡើយ

**១:១៦** ការល្បួងដែលយើងជួបប្រទះ មិនមែនមកពីព្រះនោះទេ។ លោកយ៉ាកុបបានប្រាប់អ្នកអានរបស់គាត់ថា កុំឲ្យត្រូវបំភាន់ទៀតឡើយ។ ពួកគេគិតថាព្រះកំពុងល្បួងពួកគេ ប៉ុន្តែពួកគេបានគិតខុសចំពោះការនេះ។ ពាក្យក្រិកដែលបកប្រែថា “ត្រូវបានបំភាន់” <បំភាន់>(πλανᾶσθε) មានន័យថា ងាកចេញពីមាគ៌ាត្រឹមត្រូវ។ ព្រះយេស៊ូវបានប្រើពាក្យនេះក្នុងពាក្យប្រៀបប្រដូច អំពីចៀមដែលវង្វេងបាត់ (លូកា ១៥:៣-៧) ។ នៅពេលដែលអ្នកជឿវង្វេងចេញឆ្ងាយពីការយល់ដឹងដ៏ពិតអំពីព្រះ ពួកគេចាំបាច់ត្រូវការអ្នកគង្វាលរបស់ពួកគេ ជួយនាំពួកគេឲ្យត្រលប់មករកផ្លូវត្រឹមត្រូវវិញ។ លោកយ៉ាកុប

បានធ្វើការនេះ ដោយបង្ហាញណែនាំអ្នកអានរបស់គាត់ ថាព្រះមិនមែនជាប្រភពនៃសេចក្តីល្បួងទេ តែទ្រង់គឺជាប្រភពនៃការល្អទាំងអស់វិញ។

គ្រប់ទាំងរបស់ដ៏ល្អ ដែលព្រះប្រទានមក នឹងអស់ទាំងអំណោយទានដ៏គ្រប់លក្ខណ៍ នោះសុទ្ធតែមកពីស្ថានលើ គឺមកពីព្រះវរបិតានៃពន្លឺ ដែលទ្រង់មិនចេះប្រែប្រួល សូម្បីតែស្រមោលនៃសេចក្តីផ្លាស់ប្រែក៏គ្មានដែរ

**១:១៧** លោកយ៉ាកុប ថ្លែងសេចក្តីពិត ៣ អំពីព្រះ។

១) **ព្រះជាប្រភពនៃគ្រប់ទាំងការល្អទាំងអស់**។ រាល់អ្វីដែលទ្រង់ផ្តល់អោយគឺល្អទាំងអស់ ហើយគ្រប់អំណោយទាំងអស់ដែលទ្រង់ប្រទានគឺល្អឥតខ្ចោះ។ អំណោយរបស់ទ្រង់បានបញ្ជូនអោយពួកយើង ពីឋានសួគ៌មកផែនដី។

២) **ព្រះជា "ព្រះវរបិតានៃពន្លឺ"** ។ ទ្រង់ជាអ្នកបង្កើតព្រះអាទិត្យ ព្រះច័ន្ទ និង ផ្កាយ។ ផ្ទៃមេឃប្រកាសពីសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងបង្ហាញឲ្យយើងឃើញ ឫ ទ្វានុភាពដ៏ខ្លាំងក្លារបស់ព្រះអង្គ។

៣) **ព្រះទ្រង់មានភាពស្មោះត្រង់ ហើយ មិនប្រែប្រួល**។ ពន្លឺពីព្រះអាទិត្យ ព្រះចន្ទ និង ផ្កាយអាចមានការប្រែប្រួល ប៉ុន្តែព្រះជាម្ចាស់ទ្រង់មិនប្រែប្រួលនោះឡើយ។ នៅពេលព្រះ អាទិត្យ និងព្រះចន្ទចែងចាំងមកផែនដី ក៏បង្កើតឲ្យមានស្រមោល។ ស្រមោលមានការប្រែប្រួល ប៉ុន្តែព្រះជាម្ចាស់មិនដែលប្រែប្រួលទេ។ ព្រះអង្គទ្រង់គ្មានការផ្លាស់ប្តូរ ប្រែប្រួលនោះទេ។ ទ្រង់មិនការផ្លាស់ប្តូរប្រែប្រួលដូចជាស្រមោលនោះទេ។ យើងអាចទុកចិត្តលើទ្រង់បាន ពីព្រោះទ្រង់ល្អជានិច្ច និងជារៀងរហូត។

ទ្រង់បានបង្កើតយើងរាល់គ្នាមកតាមព្រះហឫទ័យទ្រង់ ដោយសារព្រះបន្ទូលដ៏ពិត ប្រយោជន៍ឲ្យយើងបានបែបដូចជាផលដំបូង ក្នុងរបស់ទាំងប៉ុន្មានដែលទ្រង់បង្កើតមក។

**១:១៨** លោកយ៉ាកុបប្រាប់យើងអំពីអំណោយដ៏ល្អឥតខ្ចោះ ដែលព្រះបានប្រទានអោយគឺអំណោយនៃការកើតជាថ្មី។ ការកើតជាថ្មីនេះគឺជាការព្យាបាលមកពីព្រះចំពោះ និស្ស័យបាបរបស់យើង (ដែលនាំទៅរកសេចក្តីស្លាប់)។ វាគឺជាការកើតជាថ្មីខាងឯវិញ្ញាណ ដែលកើតឡើងដោយសារតែព្រះចេស្តារបស់ព្រះ។ លោកយ៉ាកុប ប្រើពាក្យសង្កត់ធ្ងន់មួយក្នុងភាសាក្រិក (βουληθεὶς) ដែលមានន័យថា តាមគម្រោងព្រះហឫទ័យ ដែលពេញដោយការប្តេជ្ញាចិត្ត យ៉ាងមួសមុតរបស់ព្រះ។ វាគឺជាគោលបំណងដែលព្រះបានកំណត់ ហើយទ្រង់នឹងធ្វើឲ្យកើតឡើង។

របៀបដែលទ្រង់ប្រទានការកើតជាថ្មីនេះ គឺតាមរយៈ "ព្រះបន្ទូលដ៏ពិត" ដែលជាដំណឹងល្អ។ តាមរយៈការទទួលដំណឹងល្អនោះឯង ដែលធ្វើឲ្យយើងកើតជាថ្មី។ ដំណឹងល្អគឺជាអ្វីគ្រប់យ៉ាងដែលព្រះយេស៊ូវបានធ្វើសម្រាប់យើង។ ដំណឹងល្អគឺជា ដំណោះស្រាយរបស់ព្រះទៅកាន់ អំពើបាប និង សេចក្តីស្លាប់។ អំពើបាបបង្កើតឲ្យមានសេចក្តីស្លាប់ (ខ ១៥) ប៉ុន្តែព្រះអង្គប្រទានការកើតជាថ្មី ដែលនាំឆ្ពោះទៅកាន់ជីវិតអស់កល្បវិញ (ខ ១៨)។ លោកយ៉ាកុបបានប្រើប្រាស់ពាក្យដូចគ្នា (ἀποκυέω) ដែលត្រូវបានគេប្រើសម្រាប់ការ «ការបង្កើត» នៅក្នុងខទាំងពីរ ដើម្បីធ្វើឲ្យមានភាពច្បាស់លាស់ទៅកាន់ភាពផ្ទុយគ្នារបស់ចំនុចទាំងពីរនេះ។

ផលដំបូង ចាប់ផ្តើមមានឡើងពេលដែលរដូវចម្រូតបានចូលមកដល់។ នៅពេលដែលផលដំបូងបានឲ្យផលមក វាគឺជាសញ្ញាមួយដែលបង្ហាញថា ព្រះទ្រង់កំពុងបង្កើតនូវជីវិតថ្មី។ នៅក្នុងគម្ពីរសញ្ញាចាស់

ផលដំបូងតែងតែជារបស់ព្រះជាម្ចាស់ (ចោទិយកថា ២៦: ១-១១)។ លោកយ៉ាកុបយល់ឃើញថា គ្រីស្ទបរិស័ទ គឺដូចជាផលដំបូងដែរ។ ដោយហេតុអ្វី? ទីមួយពីព្រោះយើងជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់។ ទីពីរ ពីព្រោះយើងគឺជាការដើមដំបូងនៃការបង្កើតថ្មី។ អស់អ្នកណាដែលបានកើតជាថ្មី ដោយសារតែដំណឹងល្អ គឺជាសញ្ញា សំគាល់ដំបូង នៃការដែលព្រះទ្រង់ធ្វើការបង្កើតថ្មី ដែលនឹងកើតឡើង ហើយនឹងមកដល់ (រ៉ូម ៨:១៨-២៥; វិវរណៈ ២១ & ២២; យ៉ូហាន ៣:១-១៥; ២ពេត្រុស ៣:១០-១៣)។

## រស់នៅដោយព្រះបន្ទូល

ដូច្នេះ បងប្អូនស្ងួនភ្ងាអើយ ចូរឲ្យគ្រប់គ្នាបានឆាប់នឹងស្តាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹងដែរ 20ដ្បិតសេចក្តីកំហឹងរបស់មនុស្ស មិនដែលសំរេចតាមសេចក្តីសុចរិតរបស់ព្រះទេ

**១:១៩-២០** សេចក្តីសុចរិត គឺជាអាកប្បកិរិយាដែលព្រះជាម្ចាស់ទ្រង់ពេញចិត្ត និង ជាអ្វីដែលទ្រង់ចង់អោយមនុស្សមាន។ នៅក្នុងផ្នែកនេះលោកយ៉ាកុបបង្រៀនអ្នកជឿ ពីរបៀបរស់នៅដោយសុចរិតត្រឹមត្រូវ។ យើងធ្វើការនេះបានតាមរយៈ ការឮព្រះបន្ទូលរបស់ព្រះ ហើយធ្វើតាមព្រះបន្ទូលរបស់ទ្រង់។ យើងត្រូវឆាប់នឹងស្តាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹង។

បានជាចូរទទួលព្រះបន្ទូលដែលបានដាំក្នុងចិត្តអ្នករាល់គ្នា ដោយចិត្តសុភាពចុះ ទាំងលះចោលអស់ទាំងសេចក្តីស្មោកគ្រោកចេញ នឹងសេចក្តីគំរក់ដ៏មានច្រើនម្លេះចេញផង ដ្បិតព្រះបន្ទូលនោះអាចនឹងជួយសង្គ្រោះព្រលឹងអ្នករាល់គ្នាបាន

**១:២១** ប្រសិនបើយើងចង់អោយជីវិតរបស់យើងសុចរិតត្រឹមត្រូវ នោះយើងចាំបាច់ត្រូវធ្វើសកម្មភាពពីរយ៉ាង គឺដកសេចក្តីស្មោកគ្រោក អសីលធម៌ និងអំពើអាក្រក់គំរក់ចេញ ហើយបន្ទាបខ្លួនទទួលព្រះបន្ទូលរបស់ព្រះ។ សេចក្តីស្មោកគ្រោក អសីលធម៌ និងអំពើអាក្រក់ គឺស្ថិតនៅជុំវិញយើង ប៉ុន្តែព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺដូចជាគ្រាប់ពូជដែលដាំនៅខាងក្នុងចិត្តអ្នកជឿ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់នឹងចាក់ឬស ហើយលូតលាស់ឡើងនៅក្នុងយើង នៅពេលយើងទទួលព្រះបន្ទូលដោយការ បន្ទាបខ្លួន។ ក្នុងពាក្យក្រិក ពាក្យ "ទទួល" (δέχομαι) មានន័យថាទទួលដោយការទទួលស្វាគមន៍យ៉ាងកក់ក្តៅ។ យើងសូមស្វាគមន៍ព្រះបន្ទូលរបស់ព្រះជាម្ចាស់ព្រោះយើងអោយតម្លៃខ្ពស់ទៅលើ ព្រះបន្ទូលទ្រង់។ ព្រះបន្ទូលរបស់ទ្រង់មានអំណាច សម្រាប់ជួយសង្គ្រោះព្រលឹងរបស់យើង នៅពេលយើងទទួលព្រះបន្ទូល ដោយការបន្ទាបខ្លួន។

ចូរឲ្យអ្នករាល់គ្នាប្រព្រឹត្តតាមព្រះបន្ទូលទៅ កុំឲ្យគ្រាន់តែស្តាប់ប៉ុណ្ណោះ ហើយបញ្ឆោតខ្លួនវិញនោះឡើយ

**១:២២** ការទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺមិនគ្រាន់តែយើងស្តាប់ប៉ុណ្ណោះទេ។ យើងទទួលព្រះបន្ទូលដោយការអនុវត្តន៍តាម។ វាគឺជាការខុសឆ្គងក្នុងការគិតថា អ្វីដែលយើងត្រូវធ្វើ គឺគ្រាន់តែស្តាប់ ព្រះបន្ទូលប៉ុណ្ណោះ។ ពាក្យដែលលោកយ៉ាកុប ប្រើសម្រាប់ពាក្យ "អ្នកស្តាប់" (ἀκροαταὶ) ត្រូវបានប្រើសម្រាប់មនុស្សដែលអង្គុយស្តាប់ការបង្រៀននៅសាកលវិទ្យាល័យ តែពួកគេមិនមែនជានិស្សិតនោះទេ ពួកគេមិនដែលបានធ្វើលំហាត់កិច្ចការណាមួយ ឬ ការប្រលងឡើយ ដូច្នេះហើយពួកគេ មិនដែលបានបញ្ចប់ការសិក្សារបស់ខ្លួនឡើយ។ យើងនឹងមិនអាចទទួលបានភាពចាស់ទុំខាងវិញ្ញាណនោះទេ ប្រសិន បើយើងមិនស្តាប់បង្គាប់ធ្វើតាមព្រះបន្ទូលរបស់ទ្រង់។

ដ្បិតបើអ្នកណាស្ដាប់ព្រះបន្ទូលហើយ តែមិនប្រព្រឹត្តតាម អ្នកនោះធៀបដូចជាមនុស្សដែលឆ្លុះមុខក្នុងកញ្ចក់ អ្នកនោះគ្រាន់តែមើលខ្លួន រួចចេញបាត់ទៅ ហើយក៏ភ្លេចពីបែបភាពខ្លួនជាយ៉ាងណាភ្លាម

**១:២៣-២៤** នៅពេលដែលមនុស្សចូលមករកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពួកគេប្រហែលជាគិតថា ពួកគេកំពុងតែពិនិត្យមើលព្រះបន្ទូលទ្រង់។ តែតាមពិតព្រះបន្ទូលរបស់ព្រះទ្រង់ទេ ដែលកំពុងពិនិត្យមើលយើងវិញ។ ព្រះបន្ទូលរបស់ព្រះ គឺប្រៀបដូចជាកញ្ចក់។ នៅពេលដែលយើងឆ្លុះមើលព្រះបន្ទូលទ្រង់ ព្រះបន្ទូលនឹងបង្ហាញយើងពីការពិតអំពីខ្លួនយើង។ បុរសនៅក្នុងខនេះ ឆ្លុះមើលកញ្ចក់ដោយយកចិត្តទុកដាក់ប៉ុន្តែបន្ទាប់មកគាត់បានចេញទៅ ហើយភ្លេចអ្វីដែលគាត់បានឃើញ។ គាត់មិនបានធ្វើអ្វីដើម្បីជាការឆ្លើយតបនឹងអ្វីដែលគាត់បានឃើញឡើយ។

លោកយ៉ាកុប កំពុងបង្ហាញយើងពីគ្រោះថ្នាក់ នៃការមិនឆ្លើយតបនឹងអ្វីដែលយើងឃើញនៅក្នុងព្រះបន្ទូលរបស់ព្រះ។ មនុស្សអាចត្រូវបានទទួលការបោកបញ្ឆោតឱ្យគិតថា ពួកគេជាមនុស្សសុចរិតដោយសារពួកគេអានព្រះគម្ពីរ ឬស្ដាប់សេចក្ដីអធិប្បាយ។ ប៉ុន្តែការពិតគឺ ប្រសិនបើយើងមិនបានទទួលព្រះបន្ទូលដោយការយកមកអនុវត្តន៍តាមទេ ព្រះបន្ទូលនោះនឹងមិនមានឥទ្ធិពលអ្វីមកលើយើងឡើយ។ បុរសនោះបានឃើញ និងយល់យ៉ាងត្រឹមត្រូវ ប៉ុន្តែបញ្ហាគឺថា គាត់មិនបានធ្វើសកម្មភាពឆ្លើយតបនឹងអ្វីដែលគាត់បានឃើញ។

តែអ្នកណាដែលពិនិត្យមើលក្នុងក្រិត្យវិន័យដ៏គ្រប់លក្ខណ៍ គឺជាក្រិត្យវិន័យខាងឯសេរីភាព ហើយក៏ជាប់ចិត្តចំពោះ ឥតមានភ្លេចសេចក្ដីដែលស្ដាប់នោះឡើយ គឺបានប្រព្រឹត្តតាមវិញ អ្នកនោះនឹងមានពរក្នុងគ្រប់ទាំងការដែលខ្លួនធ្វើទាំងប៉ុន្មាន។

**១:២៥** ឥឡូវនេះលោកយ៉ាកុបបានរៀបរាប់អំពីអ្នកដែលស្តាប់ ហើយប្រព្រឹត្តតាមអ្វីដែលគាត់បានស្តាប់។ លទ្ធផលគឺគាត់ "**នឹងមានពរក្នុងគ្រប់ទាំងការដែលខ្លួនធ្វើទាំងប៉ុន្មាន**" ។ ចូរកត់សម្គាល់ថា:

- **គាត់ «សំឡឹងយ៉ាងមោះមុត» លើសេចក្តីពិតរបស់ព្រះ**។ លោកយ៉ាកុប ប្រើពាក្យមួយ (παρακύψας) ដែលមានន័យថា "អោនខ្លួនចុះដើម្បីពិនិត្យមើលឲ្យបានជិតដល់" ។ គឺជាពាក្យដូចគ្នា ដែលត្រូវបានប្រើសម្រាប់លោកយ៉ូហាននិង នាងម៉ារាអ្នកស្រុកម៉ាក់ដាឡា នៅពេលពួកគេពិនិត្យមើលផ្នូររបស់ព្រះយេស៊ូវ (យ៉ូហាន ២០:៥,១១) ។ វាមានន័យថា ការអង្កេតមើលអ្វីមួយដោយប្រុងប្រយ័ត្ន។ នេះគឺជាការសំដៅលើ បុគ្គលណាមួយដែលមានភាពសកម្មក្នុងការសិក្សាព្រះបន្ទូលរបស់ព្រះ ដើម្បីឲ្យអាចយល់ច្បាស់ពីអត្ថន័យ។ បុរសមួយមើលដោយយកចិត្តទុកដាក់ (ខ ២៣) ប៉ុន្តែបុរសម្នាក់នេះបានឱនខ្លួនទៅ ពិនិត្យមើល។ ការនេះទាមទារឲ្យមានការបន្ទាបខ្លួន និង ការខិតខំប្រឹងប្រែង។
- "**គាតបន្តធ្វើបែបនេះ**" នេះគឺជាការបង្ហាញពីសារៈសំខាន់ក្នុងការមានទម្លាប់ សិក្សាព្រះបន្ទូលរបស់ព្រះជាប្រចាំ។ បុរសទីមួយបានដើរចេញ (ខ ២៤) ប៉ុន្តែបុរសនេះតស៊ូទៅមុខ។
- **គាត់មិនភ្លេច "អ្វីដែលគាត់បានស្តាប់នោះទេ"** ការនេះបង្ហាញពីសារៈសំខាន់នៃការចងចាំព្រះបន្ទូលរបស់ព្រះជាម្ចាស់។ បុរសទីមួយបានភ្លេចព្រះបន្ទូលរបស់ព្រះជាម្ចាស់ តែបុរសម្នាក់នេះចងចាំទុកក្នុងចិត្ត។
- អ្វីដែលសំខាន់បំផុតនោះគឺ **គាត់ធ្វីតាមអ្វីដែលព្រះបន្ទូលនិយាយ**។ នៅពេលយើងធ្វើតាមព្រះបន្ទូលរបស់ព្រះ ព្រះបន្ទូលទ្រង់ នឹងផ្លាស់ប្រែជីវិតរបស់យើង។ ការស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺជាថ្មដាយ៉ាងរឹងដែលយើងនឹងសាងសង់ជីវិតយើងពីលើ។ ព្រោះព្រះបន្ទូលទ្រង់គឺជា គ្រឹះដ៏រឹងមាំ។

បុរសនោះពិនិត្យមើលក្នុង **"ក្រឹត្យវិន័យដ៏គ្រប់លក្ខណ៍ គឺជាក្រឹត្យវិន័យខាងឯសេរីភាព"**។ ព្រះយេស៊ូវបានបំពេញក្រឹត្យវិន័យរបស់លោកម៉ូសេ ទ្រង់ហើយគឺជាអង្គបុគ្គលដែលបានសម្រេច សេចក្តីសម្រេចរបស់ក្រឹត្យវិន័យ។ ឥឡូវនេះ ក្រឹត្យវិន័យដែលអ្នកជឿដើរតាម គឺជាការបង្រៀនរបស់ព្រះយេស៊ូវ គឺជាអ្វីបើកសំដែងអត្ថន័យយ៉ាងពិតប្រាកដ និង ការអនុវត្តន៍យ៉ាងត្រឹមត្រូវទៅកាន់ក្រឹត្យវិន័យដែលព្រះបានប្រទានទៅកាន់លោកម៉ូសេ។ ព្រះយេស៊ូវមិនបានមកដើម្បីលើកចោលក្រឹត្យវិន័យ ឬ ផ្លាស់ប្តូរក្រឹត្យវិន័យនោះទេ តែទ្រង់បាននាំយកការតាំងសញ្ញាថ្មី ដែលជាការសរសេរក្រឹត្យវិន័យនៅក្នុងដួងចិត្តរបស់អ្នកជឿវិញ។

នេះគឺ ជាក្រឹត្យវិន័យនៃសេរីភាព ពីព្រោះក្រឹត្យវិន័យនេះធ្វើឱ្យមនុស្សមានសេរីភាព។ តើក្រឹត្យវិន័យនាំមកនូវសេរីភាពយ៉ាងដូចម្តេច? គឺតាមរយៈពេលដែលព្រះវិញ្ញាណបរិសុទ្ធដាក់ក្រឹត្យវិន័យនេះទៅលើដួងចិត្តរបស់អ្នកមានជំនឿណាម្នាក់ អ្នកនោះនឹងបានរួចផុតពីការជាប់ចំណងនៃអំពើបាប ហើយទទួលបានការ ប្រទានអំណាចអោយអាចស្តាប់បង្គាប់ព្រះជាម្ចាស់។ នេះគឺជាច្បាប់នៃសេរីភាព ដែលយើងមិនស្តាប់បង្គាប់តាមដោយព្រោះតែវាគឺជាកាតព្វកិច្ចសាសនានោះទេ ប៉ុន្តែដោយសារតែ យើងមានចិត្តដែលបានទទួលការផ្លាស់ប្រែ ហើយចង់ស្តាប់បង្គាប់ទៅកាន់ព្រះ។ នៅពេលដែលធ្វើការស្តាប់បង្គាប់តាមក្រឹត្យវិន័យរបស់ទ្រង់ យើងនឹងរកឃើញសេរីភាពយ៉ាងពិតប្រាកដ គឺជាសេរីភាពដែលរួចចេញពីអំពើបាប។ នេះធ្វើឲ្យយើងមានសេរីភាពក្នុងការរស់នៅសម្រាប់ព្រះ។

បើអ្នកណាស្មានថា ខ្លួនជាអ្នកកាន់សាសនា តែមិនចេះទប់អណ្តាតសោះ អ្នកនោះឈ្មោះថាបញ្ឆោតចិត្តខ្លួនហើយ ឯសាសនារបស់អ្នកនោះជាឥតប្រយោជន៍ទទេ ឯសាសនាដែលបរិសុទ្ធ ហើយឥតសៅហ្មង

នៅចំពោះព្រះដ៏ជាព្រះវរបិតា នោះគឺឲ្យទៅសួរពួកកំព្រា នឹងពួកមេម៉ាយ ក្នុងកាលដែលគេមានសេចក្ដីវេទនា ហើយឲ្យរក្សាខ្លួន មិនឲ្យប្រឡាក់ដោយលោកីយនេះឡើយ។

**១:២៦-២៧** លោកយ៉ាកុប ធ្វើការសន្និដ្ឋានដោយពិពណ៌នាពីបុរសម្នាក់ដែលធ្វើសកម្មភាពខាងសាសនា ប៉ុន្តែ មិនអាចគ្រប់គ្រងអ្វីដែលគាត់និយាយបានទេ។ ពាក្យសម្ដីរបស់យើងសំខាន់ណាស់ ពីព្រោះវាបង្ហាញពីសភាព ឬ លក្ខណៈនៃដួងចិត្តរបស់យើង(ម៉ាថាយ ១២:៣៤)។ បុរសនោះគោរពធ្វើតាមសាសនាតែសំបកក្រៅប៉ុណ្ណោះ  ប៉ុន្តែគាត់ពុំមានការផ្លាស់ប្ដូរនៅខាងក្នុងទេ។ ដូច្នេះគាត់បោកបញ្ឆោតខ្លួនឯង។ លទ្ធផលនៃការទទួលព្រះបន្ទូលរបស់ព្រះយ៉ាងពិតប្រាកដ គឺមិនមែនគ្រាន់តែជាសកម្មភាពសាសនាប៉ុណ្ណោះទេ តែវាជាការផ្លាស់ប្ដូរជីវិតដែលឆ្លុះបញ្ចាំងពីចិត្ត ដែលឲ្យអាទិភាពទីមួយទៅកាន់ព្រះ។

លោកយ៉ាកុបបានផ្ដល់ឧទាហរណ៍ពីរទាក់ទងនឹងសាសនា ដែលព្រះអង្គរាប់ថាជាសាសនាបរិសុទ្ធ និងឥតសៅហ្មង៖

- គឺជាការទៅរកក្មេងកំព្រា និងមេម៉ាយ ហើយទទួលយកពួកគេមកមើលថែ។ ព្រះជាម្ចាស់ គឺជា «ឯព្រះដែលគង់នៅក្នុងទីលំនៅបរិសុទ្ធ ទ្រង់ជាឪពុកដល់ពួកកំព្រានិងជាចៅក្រមដល់ពួកមេម៉ាយ» (ទំនុកតម្កើង ៦៨:៥)។ ព្រះទ្រង់មានព្រះទ័យរីករាយ នៅពេលដែលយើងមានការយកចិត្តទុកដាក់ចំពោះអស់អ្នកណាដែលងាយរងគ្រោះនៅក្នុងសង្គម ដោយសារតែនេះគឺជាការយកចិត្តទុកដាក់របស់ទ្រង់ដែរ។
- រក្សាខ្លួនយើងអោយ  “មិនឲ្យប្រឡាក់”  (ἄσπιλος  “គ្មានស្នាម” ) ដោយលោកកិយ៍ឡើយ។ អ្វីដែលលោកីយ៍ឲ្យតម្លៃ ជម្រុញ ចង់អោយមនុស្សប៉ងប្រាថ្នាចង់បានទ្រព្យសម្បត្តិ

ឋានៈបុណ្យសក្តិ និងភាពរីករាយ ដែលធ្វើឱ្យពួកគេធ្លាក់ក្នុងអំពើបាប (១ យ៉ូហាន ២:១៦)។ ប៉ុន្តែ ទ្រង់បានញែកយើងចេញជាបរិសុទ្ធ ដើម្បីឲ្យយើងបានបរិសុទ្ធដូចជាទ្រង់ដែរ។

សរុបសេចក្តីមកវាមិនគ្រប់គ្រាន់ទេក្នុងការ គ្រាន់តែការស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬចូលរួមក្នុងសកម្មភាពសាសនា។ ផ្ទុយទៅវិញ យើងត្រូវតែធ្វើតាមអ្វីដែលព្រះបន្ទូលទ្រង់បង្គាប់ឲ្យយើងធ្វើ។ នៅពេលយើងទទួលព្រះបន្ទូល ជីវិតរបស់យើងនឹងត្រូវផ្លាស់ប្តូរទៅជាជីវិតដែលមានការយកចិត្តទុកដាក់ទៅកាន់មនុស្សដែលខ្វះខាត និងរស់នៅក្នុងជីវិតដែលបរិសុទ្ធ។ ហើយតាមរយៈការរស់នៅ បែបនេះហើយដែលយើងអាចឆ្លុះបញ្ចាំងពីចរិកលក្ខណៈរបស់ព្រះ។

**សំណួរឆ្លុះបញ្ចាំង**

- តើខ្ញុំឆ្លើយតបទៅកាន់សេចក្តីពិត ដែលបានបើកសំដែងចេញពីព្រះបន្ទូលរបស់ព្រះដោយរបៀបណា?

## ការហាមឃាត់មិនឲ្យមានការរើសមុខ (ការមានភាពលម្អៀង)

បងប្អូនអើយ កុំឲ្យមានសេចក្ដីជំនឿ ជឿដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ដ៏ឧត្ដមនៃយើង ដោយរើសមុខអ្នកណាឡើយ

**២:១** គ្រីស្ទបរិស័ទត្រូវរួបរួមគ្នា ជាគ្រួសារតែមួយនៅក្នុងព្រះគ្រីស្ទ។ ទ្រង់គឺជាព្រះអម្ចាស់នៃសិរីល្អ។ នេះគឺជាមូលដ្ឋានគ្រឹះនៃការរួបរួមរបស់យើង។ ដូច្នេះ វាមិនមែនជាការត្រឹមត្រូវនោះទេ នៅពេលដែលអ្នកជឿបង្ហាញការរើសមុខ (ភាពលំអៀង)។

ដ្បិតបើសិនជាមានអ្នកណាចូលមកក្នុងសាលាប្រជុំរបស់អ្នករាល់គ្នា ទាំងពាក់ចិញ្ចៀនមាសនឹងសំលៀកបំពាក់ដ៏មានដំឡៃ ហើយមានអ្នកក្រម្នាក់ស្លៀកពាក់កខ្វក់ចូលមកដែរ

**២:២** លោយ៉ាកុប បានលើកឧទាហរណ៍អំពីការរើសមុខ (ភាពលំអៀង)។ គាត់ប្រាប់អ្នកអានរបស់គាត់ឱ្យស្រមៃមើលពីបុរសម្នាក់ស្លៀកសម្លៀកបំពាក់ល្អ និងពាក់ចិញ្ចៀនមាស ចូលមកក្នុងការជួបជុំរបស់ពួកគេ។ នេះបង្ហាញថាបុរសនោះជាអ្នកមានទ្រព្យសម្បត្តិ។ បន្ទាប់មកមានបុរសក្រីក្រម្នាក់ចូលមកដែរ។ ពាក្យ ដែលលោកយ៉ាកុប ប្រើរៀបរាប់ពីមនុស្សក្រីក្រលំបាក គឺជាពាក្យដែលរាប់បញ្ចូលទាំងអ្នកសុំទានដែរ។ បុរសកំសត់នោះមានតែអាវមួយ ដែលគាត់ពាក់គ្រប់ពេល។ សម្លៀកបំពាក់របស់គាត់ចាស់រហែកហើយកខ្វក់ទៀត។ សម្លៀកបំពាក់របស់បុរសទី១ ភ្លឺចិញ្ចាចចិញ្ចែង ចំនែកសម្លៀកបំពាក់របស់បុរសក្រីក្រគឺកខ្វក់។ បុរសម្នាក់មើលទៅស្អាតពីខាងក្រៅ ឯម្នាក់ផ្សេងទៀតមានសភាពយ៉ាប់យឺន។ តើក្រុមជំនុំគួរប្រព្រឹត្តយ៉ាងណាទៅកាន់បុរសទាំងពីរនេះ?

រួចអ្នករាល់គ្នាមើលទៅអ្នកដែលស្លៀកពាក់មានដំឡៃនោះ ក៏អញ្ជើញគេថា សូមអង្គុយនៅទីល្អនេះ រួចប្រាប់ទៅអ្នកក្រថា ចូរឈរនៅទីនុ៎ះចុះ ឬអង្គុយនៅទៀបកំណល់ជើងខ្ញុំនេះដូច្នេះ

**២:៣** បុរសអ្នកមាន ត្រូវបានគេស្វាគមន៍យ៉ាងពិសេស។ ពួកគេនាំគាត់ទៅកន្លែងអង្គុយយ៉ាងល្អ។ ប៉ុន្តែបុរសក្រីក្រវិញត្រូវបានគេប្រាប់ឱ្យឈរ ឬប្រហែលជាគាត់អាចអង្គុយនៅចុងជើងរបស់នរណាម្នាក់។ ពួកគេមិនអោយកៅអីទៅគាត់ទេ។ ពួកគេពិតជាមិនចង់អោយបុរសក្រីក្រចូលរួមជាមួយពួកគេទាល់តែសោះ។ បុរសអ្នកមានត្រូវបានគេទទួលអោយអង្គុយ "នៅទីនេះ" ខណៈដែលបុរសក្រីក្រត្រូវបានគេប្រាប់ឱ្យឈរនៅទីនោះ។ បុរសអ្នកមានត្រូវបានគេទទួលស្វាគមន៍ តែបុរសក្រីក្រមិនបានទទួលការស្វាគមន៍ឡើយ។ ប្រសិនបើបុរសទាំងពីរ អ្នកមាននិងអ្នកក្រ ចូលមកក្នុងក្រុមជំនុំរបស់លោកអ្នក តើលោកអ្នកនឹងប្រព្រឹត្តទៅកាន់ពួកគាត់ស្មើគ្នាដែរ ឬទេ?

នោះតើមិនមែនឈ្មោះថា បានយោគយល់នៅក្នុងពួកអ្នករាល់គ្នា ហើយបានត្រឡប់ជាអ្នករើសមុខដែលមានគំនិតអាក្រក់ទេឬអី

**២:៤** មានបញ្ហាដ៏ធ្ងន់ធ្ងរមួយបានកើតឡើង ដែលពាក់ព័ន្ធជាមួយអ្វីដែលក្រុមជំនុំបានធ្វើ។ វាកើតឡើងដោយសារតែពួកគេបានរើសអើង និងកាត់ទោស។ បុរសទាំងពីរនាក់ត្រូវបានគេទទួលយ៉ាងខុសគ្នាដោយសារតែសម្លៀកបំពាក់របស់ពួកគេ។ យើងត្រូវតែប្រាកដថា គ្មានការរើសអើងកើតឡើងនៅក្នុងក្រុមជំនុំរបស់យើងទេ។ ក្រុមជំនុំ គឺជារូបកាយរបស់ព្រះគ្រីស្ទ ហើយទ្រង់ជាសិរសា។ នេះគឺជាក្រុមជំនុំព្រះវិហាររបស់ទ្រង់ មិនមែនកន្លែងសម្រាប់តែការជួបជុំជាក្រុមរបស់យើងនោះទេ។ ទ្រង់បានសម្រេចថា យើងគឺជារូបកាយតែមួយ។ ដូច្នេះ យើងមិនត្រូវមានការបែងចែក ឬ ការរើសមុខនោះទេ។ យើងមិន

ត្រូវប្រព្រឹត្តខុសគ្នាទៅកាន់បងប្អូនប្រុស ស្រីរបស់យើងក្នុងព្រះគ្រីស្ទ ដោយសារតែទ្រព្យសម្បត្តិ រូបរាងមុខតំណែងរបស់ពួកគេក្នុងសង្គម ឬសមត្ថភាពនៃការជួយមកកាន់គោលដៅរបស់ យើងនោះទេ។

ចូរស្តាប់ចុះ បងប្អូនស្ងួនភ្ងាអើយ តើព្រះមិនបានរើសពួកអ្នកក្រនៅលោកីយនេះ ដែលជាអ្នកមានខាងសេចក្តីជំនឿ ហើយជាអ្នកគ្រងមរដកក្នុងនគរ ដែលទ្រង់បានសន្យាទុក ឲ្យពួកអ្នកដែលស្រឡាញ់ទ្រង់ទេឬអី

**២:៥** ការបង្ហាញការរើសមុខ លំអៀងប្រព្រឹត្តល្អទៅកាន់តែអ្នកមាន នោះគឺជាអំពើខុសឆ្គង។ លោកយ៉ាកុប បានប្រាប់ហេតុផលបីយ៉ាង។

**ទីមួយ ព្រះជាម្ចាស់បានជ្រើសរើសអ្នកក្រ។** នេះមិនមានន័យថាព្រះបានជ្រើសរើសតែអ្នកក្រទេ ប៉ុន្តែទ្រង់យកព្រះទ័យទុកដាក់ ជាពិសេសទៅលើអ្នកក្រលំបាក។ នៅក្នុងជំនាន់ក្រុមជំនុំដំបូង មិនសូវមានអ្នកមានប៉ុន្មានទេ។ ព្រះជាម្ចាស់បានជ្រើសរើសអ្នកក្រ អោយពួកគេក្លាយជា "អ្នកមានខាងសេចក្តីជំនឿ" ។ សេចក្តីជំនឿ គឺជាទ្រព្យសម្បត្តិដែលមានគុណតម្លៃពិត មិនមែនលុយ រឺទ្រព្យសម្បត្តិទេ។ ហេតុអ្វី? ព្រោះជំនឿជាមូលដ្ឋានគ្រឹះនៃទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់ ហើយទំនាក់ទំនងជាមួយព្រះជាម្ចាស់មានតម្លៃជាងទ្រព្យសម្បត្តិទាំងអស់ក្នុងភពផែនដីនេះ។ ដូច្នេះ អ្នកក្រដែលជឿលើព្រះយេស៊ូវ គឺជាអ្នកមានពិតប្រាកដ ជាអ្នកមានខាងជំនឿ។

អ្នកក្រដែលជាអ្នកមានក្នុងសេចក្តីជំនឿ មានសេចក្តីសន្យាដ៏អស្ចារ្យមកពីព្រះជាម្ចាស់។ ពួកគេជាអ្នកគ្រងមរតកនៃនគរព្រះ! អ្នកក្រដែលស្រឡាញ់ព្រះជាម្ចាស់ មានកន្លែងរបស់ខ្លួននៅក្នុងនគររបស់ព្រះជា

ម្ចាស់ ហើយមានចំណែកក្នុងទ្រព្យសម្បត្តិដ៏អស់កល្បជានិច្ចរបស់ទ្រង់! នេះគឺជាអ្វីដែលប្រសើរ ជាង ការមានចញ្ចៀនមាស និង សម្លៀក បំពាក់ល្អទៅទៀត។ ប្រសិនបើអស់អ្នកជឿ ជេរប្រមាថ អ្នកក្រ និង អែបអបអ្នកមាន នោះសកម្មភាពរបស់ ពួកគេបង្ហាញថា ពួកគេមិនដឹងពីគុណតម្លៃនៃសេចក្តីជំនឿ និង សេចក្តីសន្យារបស់ព្រះនោះឡើយ។

**២:៦-៧ ទីពីរ ពួកអ្នកមានកំពុងតែបៀតបៀនក្រុមជំនុំ។**

តែអ្នករាល់គ្នាបន្ទុះបង្អាប់អ្នកក្រនោះវិញ តើពួកអ្នកមានមិនសង្កត់សង្កិន ហើយអូសអ្នករាល់គ្នាទៅនៅមុខទីជំនុំជំរះទេឬអី តើគេមិនប្រមាថដល់ព្រះនាមល្អ ដែលបានឲ្យដល់អ្នករាល់គ្នាទេឬអី

ពួកអ្នកមានបានចាប់អ្នកជឿព្រះឲ្យចូលតុលាការ ហើយចោទប្រកាន់ពួកគេពីបទរល្មើសនឹងច្បាប់។ ចៅក្រមពុករលួយ យល់ព្រមជាមួយនឹង ការដែលពួកអ្នកមាននិយាយ។ ពួកអ្នកមានក៏និយាយប្រមាថ ប្រឆាំងនឹងព្រះនាមរបស់ព្រះយេស៊ូវ។ ព្រះនាមរបស់ព្រះយេស៊ូវគឺជាព្រះនាមដ៏ល្អពិសេស មានកិត្តិនាម និង កិត្តិយសដ៏ខ្ពង់ខ្ពស់ និងសក្តិសម ទទួលការសរសើរ។ វាជាការប្រមាថដល់ព្រះ នៅពេលដែល មនុស្សនិយាយទាស់ប្រឆាំងនឹងព្រះនាម របស់ទ្រង់។

បើអ្នករាល់គ្នាកាន់តាមក្រិត្យវិន័យដ៏ប្រសើរ ដូចមានបទគម្ពីរថា «ចូរឲ្យឯងស្រឡាញ់អ្នកជិតខាង ដូចជាខ្លួនឯង» នោះឈ្មោះថាប្រព្រឹត្តល្អហើយ ៩តែបើអ្នករាល់គ្នារើសមុខគេ នោះមានបាបវិញ ហើយ ក្រិត្យវិន័យក៏កាត់ទោសអ្នក ទុកដូចជាបានប្រព្រឹត្តរំលងដែរ

**២:៨-៩ ទីបី  ការរើសមុខ (ភាពលំអៀង)គឺជាការប្រព្រឹត្តរំលងទាស់នឹង “ក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់”** របស់ព្រះ។ លោកយ៉ាកុបហៅ ខគម្ពីរលេវីវិន័យ ១៩:១៨ ថា «ក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់» ពីព្រោះស្តេចរបស់យើងបានមានបន្ទូលថា បណ្តាក្រឹត្យវិន័យ និងអស់ទាំងទំនាយហោរាទាំងប៉ុន្មាន ក៏សំរេចនៅបទបញ្ញត្តនេះ និងក្រឹត្យវិន័យដែលបង្គាប់ឲ្យយើងស្រឡាញ់ព្រះអម្ចាស់ (ម៉ាថាយ ២២:៣៦-៤០)។ ក្រឹត្យវិន័យបានប្រទានមកកាន់យើងពួកយើង ដើម្បីបង្រៀនយើងឲ្យចេះស្រឡាញ់ព្រះ និង ស្រឡាញ់មនុស្ស។ បើយើងស្រឡាញ់គ្នាទៅវិញដូចជាអ្វីដែលយើងគួរ នោះមានន័យថា យើងបានសម្រេចគ្រប់ក្រឹត្យវិន័យទាំងអស់ (រ៉ូម ១៣:១០; កាឡាទី ៥:១៤) ។ ការបង្ហាញការរើសមុខ (ភាពលំអៀង) គឺជាការបរាជ័យក្នុងការស្តាប់បង្គាប់តាមក្រឹត្យវិន័យ ដែលបង្គាប់ឲ្យយើងស្រឡាញ់អ្នកជិតខាងរបស់យើង។

ដ្បិតអ្នកណាដែលកាន់ក្រិត្យវិន័យទាំងមូលតែភ្លាត់ជំពប់នឹងបទណាមួយ នោះក៏ត្រឡប់ជាមានទោសចំពោះក្រិត្យវិន័យទាំងមូលនោះហើយ

**២:១០** ក្រិត្យវិន័យរបស់ព្រះផ្ដុំមកតែមួយ ហើយមិនអាចបែងចែកបានទេ។ ការបរាជ័យក្នុងការស្តាប់បង្គាប់ទៅលើក្រឹត្យវិន័យណាមួយ នោះក៏ត្រឡប់ជាមានទោសចំពោះក្រឹត្យវិន័យទាំងមូល។ វាដូចជាការដែលយកញញួរទៅវាយបំបែក បង្អួចកញ្ចក់។ នៅពេលអ្នកវាយបំបែកនៅចំណុចមួយ បង្អួចទាំងមូលនឹងត្រូវបែកខ្ទេច។ យើងមិនអាចជ្រើសរើសផ្នែកណាមួយនៃក្រឹត្យដែលយើងយល់ស្រប និង ចង់ស្តាប់បង្គាប់តាម ហើយមិនអើពើនឹងផ្នែកដែលយើងមិនចូលចិត្តឡើយ។ ការស្តាប់បង្គាប់តែ ចំនុចខ្លះៗ គឺជាការមិនស្តាប់បង្គាប់។  បើអ្នករាល់គ្នាកាន់តាមក្រឹត្យវិន័យទាំងអស់ តែលោកអ្នក ប្រព្រឹត្តរំលងនឹងក្រឹត្យវិន័យណាមួយ លោកអ្នកនៅមានឈ្មោះថាជាអ្នកបំពានលើក្រឹត្យវិន័យ។

ពីព្រោះព្រះដែលមានបន្ទូលថា «កុំឲ្យផិតគ្នាឲ្យសោះ» ទ្រង់ក៏មានបន្ទូលថា «កុំឲ្យសំឡាប់មនុស្ស»ដែរ ដូច្នេះ បើអ្នកមិនបានប្រព្រឹត្តសេចក្តីកំផិតទេ តែបានសំឡាប់វិញ នោះឈ្មោះថាអ្នកបានប្រព្រឹត្តអំពើរំលងក្រិត្យវិន័យហើយ

**២:១១** ក្រឹត្យវិន័យរបស់ព្រះ មានសេចក្តីបង្គាប់បញ្ជាជាច្រើន តែគឺជាច្បាប់ក្រឹត្យវិន័យតែមួយមកពីព្រះ ។ យើងមិនអាចធ្វើការដោះសារចំពោះការបរាជ័យក្នុងការស្តាប់បង្គាប់ទៅលើក្រឹត្យវិន័យណាមួយឡើយ ទោះបីជាយើងបានស្តាប់បង្គាប់ទៅលើផ្នែកមួយផ្សេងទៀតនៃក្រឹត្យវិន័យក៏ដោយ។

ចូរឲ្យអ្នករាល់គ្នានិយាយ ព្រមទាំងប្រព្រឹត្តបែបដូចជាក្រិត្យវិន័យនៃសេចក្តីសេរីភាព រៀបនឹងជំនុំជំរះអ្នកហើយចុះ

**២:១២** មនុស្សទាំងអស់នឹងទទួលការជំនុំជំរះ រួមទាំងគ្រីស្ទបរិស័ទផងដែរ។ គ្រីស្ទបរិស័ទនឹងមិនត្រូវទទួលការជំនុំជំរះ ចំពោះអំពើបាបទេ ដោយសារតែការជំនុំជំរះនេះបានកើតឡើងទៅលើព្រះគ្រីស្ទរួចទៅហើយ នៅពេលដែលទ្រង់បានសុគតនៅលើឈើឆ្កាង។ ប៉ុន្តែឥរិយាបថរបស់យើង (រ៉ូម ១៤:១០-១២) សកម្មភាពរបស់យើង (២ កូរិនថូស ៥:៩-១០) ពាក្យសម្តីរបស់យើង (ម៉ាថាយ ១២:៣៦) និងភាពស្មោះត្រង់នៃការបម្រើរបស់យើង (ម៉ាថាយ ២៥:១៤-៣០) នឹងទទួលការជំនុំជំរះ។ ដូច្នេះ យើងគួរតែនិយាយ និងប្រព្រឹត្តដូចអស់អ្នកដែលដឹងថា យើងនឹងទទួលការជំនុំជំរះទៅលើ របៀបដែលយើងបង្ហាញសេចក្តីស្រឡាញ់របស់យើងទៅកាន់ព្រះ និង ទៅកាន់មនុស្ស។ សម្រាប់ការ អានកំណត់ត្រាអំពី “ច្បាប់នៃសេរីភាព” សូមមើល ១:២៥ ។

ដ្បិតអ្នកណាដែលប្រព្រឹត្តដោយឥតមេត្តា នោះនឹងត្រូវទោសឥតគេមេត្តាដែរ រីឯសេចក្ដីមេត្តា នោះរមែងឈ្នះសេចក្តីជំនុំជំរះវិញ។

**២:១៣** តើយើងអាចយកឈ្នះលើការជំនុំជំរះយ៉ាងដូចម្ដេច នៅពេលដែលយើងទាំងអស់គ្នាបាន ប្រព្រឹត្តរំលងទៅលើក្រឹត្យវិន័យរបស់ព្រះ? មានវិធីតែមួយគត់ គឺតាមរយៈសេចក្ដីមេត្តាករុណារបស់ ព្រះជាម្ចាស់។ ប្រសិនបើយើងចង់ទទួលបានមេត្តាករុណារបស់ព្រះជាម្ចាស់ ដែលជាអ្វីដែលយើងមិន សមនឹងទទួលនោះ យើងត្រូវតែបង្ហាញសេចក្ដីមេត្តាករុណាដល់អ្នកដទៃ ទោះបីជាពួកគេមិនសមនឹង ទទួលសេចក្ដីមេត្តាករុណានោះក៏ដោយ។ អស់អ្នកណាដែលមានចិត្តមេត្តាករុណា អស់អ្នកទាំងនោះ នឹង ទទួលបានសេចក្ដីមេត្តាករុណាវិញ (ម៉ាថាយ ៥:៧)។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើយើងមិន បង្ហាញសេចក្ដីមេត្តាករុណាដល់អ្នកដទៃទេ យើងនឹងមិនទទួលបានសេចក្ដីមេត្តាពីព្រះជាម្ចាស់បាន ឡើយ។ គ្រីស្ទបរិស័ទ្ធដែលបង្ហាញសេចក្ដីមេត្តាករុណាចំពោះអ្នកដទៃ គឺកំពុងតែធ្វើអ្វីដែលក្រឹត្យវិន័យ នៃសេចក្ដីស្រឡាញ់តម្រូវឱ្យធ្វើ ហើយមិនគួរមានការភ័យខ្លាចការជំនុំជំរះនោះឡើយ។

**សំណួរឆ្លុះបញ្ចាំង**

- តើខ្ញុំបង្ហាញការរើសមុខ (ភាពលម្អៀង) ទៅកាន់មនុស្សផ្សេងៗដែរឬទេ?

## ជំនឿ និង ការប្រព្រឹត្ត

ជំនឿគឺជាចំនុចចាំបាច់ណាស់នៅក្នុងជីវិតគ្រីស្ទបរិស័ទ។ យើងត្រូវបានសង្គ្រោះដោយសារព្រះគុណតាម រយៈសេចក្តីជំនឿ (អេភសូ ២:៨-៩) ហើយបន្ទាប់មកយើងដើរដោយសេចក្តីជំនឿ (២ កូរិនថូស ៥:៧)។ គឺជាដោយសារតែសេចក្តីជំនឿនោះឯង ដែលរាស្ត្ររបស់ព្រះអាចធ្វើកិច្ចការដែលព្រះអង្គបានបង្គាប់ឲ្យពួកគេធ្វើ ហើយមនុស្សនឹងនឹកចាំពីសេចក្តីជំនឿរបស់ពួកគេ (ហេព្រើរ ១១)។ តែបើឥតមានសេចក្តីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ (ហេព្រើរ ១១:៦) ដ្បិតការទាំងប៉ុន្មានដែលយើងធ្វើ ដោយឥតមានសេចក្តីជំនឿនោះសុទ្ធជាតែអំពើបាបហើយ (រ៉ូម ១៤:២៣)។ នៅក្នុងអត្ថបទនេះ យ៉ាកុបកំពុងពិភាក្សាពីទំនាក់ទំនងរវាង សេចក្តីជំនឿ ការប្រព្រឹត្ត និងសេចក្តីសង្គ្រោះ ។

បងប្អូនអើយ បើអ្នកណាថាខ្លួនមានសេចក្តីជំនឿ តែមិនប្រព្រឹត្តតាម នោះតើមានប្រយោជន៍អ្វី តើសេចក្តីជំនឿអាចនឹងជួយសង្គ្រោះអ្នកនោះបានដែរឬ

**២:១៤** លោកយ៉ាកុបចាប់ផ្តើមដោយឲ្យឧទាហរណ៍មួយ។ បុរសម្នាក់អះអាងថាគាត់មានសេចក្តីជំនឿ ប៉ុន្តែ គាត់មិនមានការប្រព្រឹត្តការល្អនោះទេ។ លោកយ៉ាកុបសួរថា តើសេចក្តីជំនឿបែបនេះអាចជួយសង្គ្រោះគាត់បានឬទេ? ហើយនេះ គឺជាសំណួរដែលគាត់នឹងឆ្លើយនៅក្នុងផ្នែកនេះ។ ដូច្នេះបញ្ហាគឺថាតើចាំបាច់ត្រូវមានសេចក្តីជំនឿប្រភេទណា ដើម្បីឲ្យអាចទទួលបានសេចក្តីសង្គ្រោះ។

ចុះបើមានបងប្អូនប្រុសស្រីណានៅអាក្រាត ព្រមទាំងខ្វះអាហារបរិភោគរាល់តែថ្ងៃ ហើយអ្នករាល់គ្នាណាមួយនិយាយទៅអ្នកនោះថា អញ្ជើញទៅឲ្យសុខសាន្ត សូមឲ្យបានកក់ក្តៅ ហើយឆ្អែតចុះ តែគ្មានឲ្យអ្វីដល់អ្នកដែលត្រូវការខាងរូបសាច់នោះសោះ នោះតើមានប្រយោជន៍អ្វី

**២:១៥-១៦** លោកយ៉ាកុប លើកឧទាហរណ៍អំពីភាពពុតត្បុតក្នុងពាក្យសំដីរបស់មនុស្សដែលគ្មានការប្រព្រឹត្តសកម្មភាពអ្វីទាំងអស់។ មនុស្សម្នាក់ មើលឃើញ បងប្អូនប្រុសស្រីនៅក្នុងព្រះគ្រីស្ទដែលកំពុងត្រូវការជំនួយ។ គាត់និយាយពាក្យសម្ដី ដែលវាហាក់បីដូចជាថាគាត់មានការយកចិត្តទុកដាក់ប៉ុន្តែគាត់បានឲ្យពួកទៅ ដោយមិនបានឲ្យអ្វីសោះទៅកាន់ពួកគាត់។ លោកយ៉ាកុបសួរថា តើមានប្រយោជន៍អ្វី? ចម្លើយគឺ "គ្មានប្រយោជន៍ទេ" ពីព្រោះពាក្យទាំងនេះមិនអាចផ្ដល់ផលប្រយោជន៍អ្វីដល់បងប្អូនប្រុសស្រីដែលមានខ្វះខាតនោះទេ។ ពួកគេនៅតែរងា និង ស្រេកឃ្លាន។ចំណុចដែល លោកយ៉ាកុបចង់ចង្អុលបង្ហាញនោះគឺថា ការដែលមានតែពាក្យសំដី តែគ្មានការបង្ហាញចេញ ជាសកម្មភាពមិនអាចបង្កើតឲ្យមានអ្វីដែលល្អបាននោះឡើយ។

ឯសេចក្ដីជំនឿក៏បែបដូច្នោះដែរ បើគ្មានការប្រព្រឹត្តតាមទេ នោះក៏ស្លាប់នៅតែឯង

**២:១៧** ដូចគ្នាដែរ ប្រសិនបើយើងនិយាយថា យើងមានជំនឿតែយើងមិនធ្វើតាមជំនឿនោះទេ នេះក៏គ្មានប្រយោជន៍ដែរ មិនថាមកកាន់យើង ឬ អ្នកដទៃ។ លោកយ៉ាកុប ប្រើពាក្យថា សេចក្ដីជំនឿដែល "ស្លាប់" ។ សេចក្ដីជំនឿស្លាប់ មិនមែនមានន័យថាជំនឿបានស្លាប់ទេ។ តែវាមានន័យថាវាគឺជាសេចក្ដីជំនឿដែល មិនដែលមិនជីវិតតាំងពីមុនមក។

តែអ្នកខ្លះនឹងនិយាយថា អ្នកមានសេចក្ដីជំនឿ ហើយខ្ញុំមានការប្រព្រឹត្ត ដូច្នេះ ចូរអ្នកបង្ហាញសេចក្ដីជំនឿរបស់អ្នក ក្រៅពីការដែលអ្នកប្រព្រឹត្តឲ្យខ្ញុំឃើញផង នោះខ្ញុំនឹងបង្ហាញសេចក្ដីជំនឿខ្ញុំ ដោយសារការដែល ខ្ញុំប្រព្រឹត្តដែរ

**២:១៨** លោកយ៉ាកុបបានចាប់ផ្ដើមលើកឡើងថា មានបុរសម្នាក់ដែលនិយាយថាគាត់មានជំនឿ តែគ្មានគ្មានការប្រព្រឹត្តនោះទេ។ ឥឡូវនេះ លោកយ៉ាកុបស្រមៃថា មានអ្នកជឿម្នាក់ប្រឈមជំរុញឲ្យបុរសម្នាក់នោះ ធ្វើការអះអាង បង្ហាញពីសេចក្ដីជំនឿរបស់គាត់។ តើត្រូវធ្វើយ៉ាងណា ដើម្បីបង្ហាញពីសេចក្ដី ជំនឿ? គឺតាមរយៈសកម្មភាពការប្រព្រឹត្តរបស់យើង ដែលបង្ហាញពីការទុកចិត្តលើព្រះ។ ប៉ុន្តែបើសិនជា នរណាម្នាក់គ្មានការប្រព្រឹត្តនោះទេ តើគាត់អាចបង្ហាញពីសេចក្ដីជំនឿរបស់គាត់ដោយរបៀបណា? នេះជាការសំដែងឲ្យឃើញថា សេចក្ដីជំនឿរបស់គាត់គឺជាជំនឿដែលស្លាប់។

អ្នកជឿថា មានព្រះតែ១ នោះត្រូវហើយ ទោះទាំងពួកអារក្សក៏ជឿដូច្នោះ ព្រមទាំងព្រឺខ្លាចដែរ

**២:១៩** មនុស្សដែលមានជំនឿស្លាប់ មិនចង់រស់នៅក្នុងការស្ដាប់បង្គាប់ដល់ព្រះជាម្ចាស់ទេ។ ដូច្នេះពួកគេច្រើនតែនិយាយថាគ្រាន់តែជឿលើព្រះពិតតែមួយ គឺគ្រប់គ្រាន់ហើយ។ វាគឺជាការពិតដែលមានតែព្រះពិតតែមួយ ហើយវាជាការល្អដែលដឹង និងជឿលើសេចក្ដីពិតនេះ។ ប៉ុន្តែ ការជឿថាមានព្រះតែមួយគឺមិនដូចគ្នា ជាមួយនឹងការមានជំនឿលើព្រះអង្គនោះទេ។ សូម្បីតែអារក្ស ក៏ដឹងដែរថាព្រះជាម្ចាស់ គឺជាព្រះពិតតែមួយ។ ពួកវាដឹងថាពួកវានឹងទទួលការជំនុំជំរះ ហើយពេលវេលា និងទីកន្លែង សម្រាប់ការដាក់ទណ្ឌកម្មរបស់ពួកវា ត្រូវបានកំណត់ហើយ។ ដោយសារតែរឿងនេះ ពួកវាខ្លាចញាប់ញ័រយ៉ាងខ្លាំង។ ប៉ុន្តែចំណេះដឹងអំពីព្រះមិនដូចគ្នានឹងការដាក់សេចក្ដីជំនឿលើព្រះអង្គនោះទេ។

ឱមនុស្សកំឡៅអើយ អ្នកចង់ដឹងពិតឬទេថា សេចក្ដីជំនឿដែលឥតមានការប្រព្រឹត្តតាម នោះឈ្មោះថាស្លាប់ហើយ

**២:២០** ជំនឿ "ស្លាប់" នេះគឺទាក់ទងនឹងពាក្យសម្តី និងជំនឿរបស់យើង ប៉ុន្តែវាមិននាំឆ្ពោះទៅកាន់ការមានភាពសកម្មក្នុងការទុកចិត្តទៅកាន់ព្រះ នេះហើយគឺជាការដែលគ្មានប្រយោជន៍ទាល់តែសោះ ។ បុគ្គលណាដែលមិនយល់ឃើញថា សេចក្តីជំនឿនាំឆ្ពោះទៅកាន់ការប្រព្រឹត្តល្អ អ្នកនោះគឺជាមនុស្ស "ល្ងីល្ងើ" ។ ពាក្យក្រិកសម្រាប់ពាក្យ "ល្ងីល្ងើ" មានន័យថា "ទទេ ឬ គ្មាន" ដែលការនេះសំដៅទៅលើ ការខ្វះការយល់ដឹង។

ចុះលោកអ័ប្រាហាំ ជាព្ធយុកោយើង តើមិនបានរាប់ជាសុចរិត ដោយការលោកប្រព្រឹត្ត ក្នុងកាលដែលលោកបានថ្វាយអ៊ីសាក ជាកូនលោក នៅលើអាសនាទេឬអី

**២:២១** បន្ទាប់ពីបានពិពណ៌នាថា ជំនឿស្លាប់គ្មានប្រយោជន៍ទាល់តែសោះ ឥឡូវនេះលោកយ៉ាកុបបានផ្តល់ឧទាហរណ៍ពីរ អំពីមនុស្សដែលមានសេចក្តីជំនឿ ដែលមានភាពរស់រវើក និង មានប្រយោជន៍ គឺលោក អ័ប្រាហាំ និង នាងរ៉ាហាប។

ព្រះជាម្ចាស់បានសន្យាថានឹងធ្វើឲ្យលោកអ័ប្រាហំ ក្លាយទៅជាប្រជាជាតិ (នគរ) ដ៏ធំមួយ (លោកុប្បត្តិ ១២:២) ដែលមានពូជពង់កូនចៅច្រើនដូចផ្កាយ (លោកុប្បត្តិ១៥:៤-៥)។ ទោះបីគាត់ជាមនុស្សចាស់ហើយគ្មានកូនក៏ដោយ អ័ប្រាហាំជឿថាព្រះជាម្ចាស់នឹងធ្វើតាមអ្វីដែលទ្រង់បានសន្យា។ ដោយសារតែការនេះ ទ្រង់រាប់សេចក្តីជំនឿនោះ ទុកជាសេចក្តីសុចរិតដល់គាត់ (លោកុប្បត្តិ១៥:៦)។ ក្នុងកំឡុងពេលនោះមិនមានលើកឡើងនិយាយពីការប្រព្រឹត្តនោះឡើយ។ ព្រះជាម្ចាស់បានរាប់អ័ប្រាហាំ ជាសុចរិតដោយសារសេចក្តីជំនឿរបស់របស់គាត់។

ក្រោយមក យើងឃើញភស្តុតាងបញ្ជាក់ពីសេចក្តីជំនឿរបស់លោកអ័ប្រាហាំ។ ជំនឿរបស់អាប្រាហាំបានទទួលការល្បងលដ៏លំបាកបំផុត នៅពេលដែលព្រះជាម្ចាស់ បានមានបន្ទូលឲ្យគាត់ថ្វាយ អ៊ីសាកដែលជាកូនប្រុសរបស់គាត់ ជាយញ្ញបូជា ។ ពីមុនព្រះអង្គបានមានបន្ទូលថាសេចក្តីសន្យា របស់ទ្រង់ អំពីនគរ(ប្រជាជាតិ)ដ៏ធំមួយ នឹងបានសម្រេចតាមរយៈជីវិតរបស់លោកអ៊ីសាក (លោកុប្បត្តិ ២១:១២-១៣)។ ឥឡូវនេះទ្រង់កំពុងតែមានបន្ទូលប្រាប់លោកអ័ប្រាហាំថ្វាយអ៊ីសាកជាយញ្ញបូជា (លោកុប្បត្តិ ២២:១-២)! ដូច្នេះ តើសេចក្តីសន្យារបស់ទ្រង់ នឹងសម្រេចបានដោយរបៀបណា?លោកអ័ប្រាហាំ មិនបានដឹងទេ ប៉ុន្តែគាត់នៅតែបន្តទុកចិត្តលើព្រះជាម្ចាស់។ គាត់បានត្រៀមខ្លួនធ្វើអ្វីដែលផ្ទុយពីចិត្ត និង ប្រាជ្ញារបស់គាត់ គាត់ធ្វើការនេះ ដោយគ្រាន់តែគាត់ដឹងថាវាជាអ្វីដែលព្រះអង្គមានបន្ទូលឲ្យគាត់ធ្វើ។ យើងឃើញថាជំនឿ មានន័យថាមនុស្សម្នាក់សុខចិត្តធ្វើតាមអ្វីដែលព្រះជាម្ចាស់មានបន្ទូលឲ្យធ្វើ។ គាត់ជឿជាក់ថាព្រះជាម្ចាស់នឹងនៅតែសម្រេចតាមការសន្យារបស់ទ្រង់តាមរយៈ អ៊ីសាក (ហេព្រើរ ១១:១៧-១៩)។ ការប្រព្រឹត្តរបស់គាត់បានរាប់ជាសុចរិតដោយសារ ការប្រព្រឹត្តទាំងនោះបានបង្ហាញពី ការមានសេចក្តីជំនឿនៅទៅលើព្រះអម្ចាស់។

ដូច្នេះ អ្នកឃើញថា សេចក្តីជំនឿបានរួមជាមួយនឹងការដែលលោកប្រព្រឹត្ត ហើយសេចក្តីជំនឿបានគ្រប់លក្ខណ៍ ដោយសារការនោះឯង

**២:២២** សេចក្តីជំនឿ និង ការប្រព្រឹត្ត គឺផ្សារភ្ជាប់គ្នា មិនមែនដាច់ដោយឡែកពីគ្នាទេ។ ការប្រព្រឹត្តគឺជាលទ្ធផល និងការបង្ហាញពីសេចក្តីជំនឿ។ ជំនឿពិតមាន "ការប្រព្រឹត្ត" (ខ ១៤, ១៧) គឺ "សេចក្តីជំនឿ បានរួមជាមួយនឹងការដែលលោកប្រព្រឹត្ត" (ខ ២២) ហើយ "បានគ្រប់លក្ខណ៍ដោយការប្រព្រឹត្ត" (ខ ២២)។ "ដែលពេញលេញ" (ἐτελειώθη)

មានន័យថានឹងនាំអ្វីម្យ៉ាងឲ្យទៅដល់គោលដៅ។ ដូចនេះ សេចក្តីជំនឿរបស់យើងមានគោល។ ហើយគោលដៅនៃសេចក្តីជនឿរបស់យើង គឺជាការដែល ប្រឹងប្រែងឆ្ពោះទៅរកជីវិត ដែលរស់នៅស្តាប់បង្គាប់ព្រះ។

នោះទើបបានសំរេចបទគម្ពីរ ដែលថា «អ័ប្រាហាំបានជឿដល់ព្រះ ហើយសេចក្តីនោះ បានរាប់ជាសេចក្តីសុចរិតដល់លោក» ព្រះក៏ហៅលោកជាសំឡាញ់របស់ទ្រង់ដែរ

**២:២៣** ព្រះបានប្រកាសរាប់ លោកអាប្រាហាំថា ជាមនុស្សសុចរិត នៅយប់ដែលគាត់បានជឿលើការសន្យារបស់ទ្រង់។ ច្រើនឆ្នាំក្រោយមក គាត់បានត្រៀមខ្លួនក្នុងការថ្វាយអ៊ីសាកជាយញ្ញបូជាដល់ព្រះជាម្ចាស់។ ក្នុងការធ្វើដូចនេះ បទគម្ពីរដែលបាននិយាយថាលោកអាប្រាហាំត្រូវបានរាប់ជាសុចរិតដោយសារជំនឿរបស់គាត់ (លោកុប្បត្តិ ១៥:៦) ហើយវាត្រូវបានសម្រេចជាច្រើនឆ្នាំក្រោយមកដោយសារការប្រព្រឹត្ត របស់គាត់ដែលបង្ហាញពីជំនឿនេះ (លោកុប្បត្តិ ២២) ។

វាគឺជាការដូចគ្នាដែរ សម្រាប់អស់អ្នកណាដែលបានទទួលសេចក្តីសង្គ្រោះហើយ។ ព្រះអង្គបានរាប់យើងជាសុចរិត ដោយសារជំនឿ បន្ទាប់មកយើងធ្វើការប្រព្រឹត្តដែលបង្ហាញអោយឃើញ និង បំពេញជំនឿរបស់យើង។ នៅពេលដែលយើងប្រព្រឹត្តដោយសេចក្តីជំនឿ នោះយើងនឹងទទួលបានសេចក្តីជំនឿកាន់តែច្រើន។ លទ្ធផលនៃសេចក្តីជំនឿរបស់យើងនៅក្នុងព្រះអង្គ មានការលូតលាស់កាន់តែជ្រាលជ្រៅ ហើយកាន់តែរឹងមាំជាងពីមុន។ ដូចជាអាប្រាហាំមានជំនឿកាន់តែខ្លាំង នៅពេលគាត់ដើរជាមួយព្រះជាម្ចាស់។ ដូចគ្នាដែរ ជំនឿរបស់យើងក៏កាន់តែប្រពៃឡើង នៅពេលដែលយើងដាក់ភ្នែក

រំពឹងមើលដល់ព្រះ (ហេព្រើរ ១២:២)។ មិត្តភាពជាមួយព្រះជាម្ចាស់ គឺកើតចេញពីការស្តាប់បង្គាប់យ៉ាងស្មោះត្រង់។

ដូច្នេះ អ្នករាល់គ្នាឃើញថា មនុស្សបានរាប់ជាសុចរិត មិនមែនដោយសារតែសេចក្តីជំនឿប៉ុណ្ណោះទេ គឺដោយសារការប្រព្រឹត្តដែរ

**២:២៤** លោកយ៉ាកុបមិនកំពុងនិយាយថា ការរាប់ជាសុចរិតមិនចាំបាច់ទាមទារឲ្យមានសេចក្តីជំនឿនោះទេ ប៉ុន្តែគាត់កំពុងបង្រៀនថា ជំនឿពិតតែងតែត្រូវបានអមដោយការប្រព្រឹត្តល្អត្រឹមត្រូវ។ ការប្រព្រឹត្តមិនមែនកើតឡើង ដើម្បីជំនួសសេចក្តីជំនឿនោះទេ តែការប្រព្រឹត្តកើតឡើងដោយសារសេចក្តីជំនឿវិញ។ ការប្រព្រឹត្ត គឺជាសញ្ញាមួយ ដែលបង្ហាញថាជំនឿដែលនាំឲ្យមានសេចក្តីសង្គ្រោះកំពុងមានវត្តមាននៅក្នុងជីវិត របស់បុគ្គលម្នាក់។ ប្រសិនបើបុគ្គលណាម្នាក់ទទួលបានសេចក្តីសង្គ្រោះដោយសារព្រះគុណរបស់ព្រះ នោះគាត់នឹងដើរក្នុងការប្រព្រឹត្តល្អ ដែលព្រះទ្រង់បានរៀបចំសម្រាប់អោយគាត់ធ្វើ (អេភេសូ ២:៨-១០)។ ប្រភេទនៃសេចក្តីជំនឿដែលគ្មានការប្រព្រឹត្ត (សំដៅទៅលើអស់អ្នកណាដែលមានសេចក្តីជំនឿលើព្រះ ប៉ុន្តែសេចក្តីជំនឿរបស់គាត់មិនឥទ្ធិពលមកកាន់ជីវិតរបស់គាត់ឡើយ) គឺជាជំនឿដែលមិនមានភាពដូចគ្នាជាមួយនឹងជំនឿរបស់អស់អ្នកដែលបានសេចក្តីសង្គ្រោះនោះទេ។

អ្នកខ្លះគិតថា ការបង្រៀនរបស់ លោកប៉ុល និង លោកយ៉ាកុបលើប្រធានបទនេះមានភាពផ្ទុយគ្នា ប៉ុន្តែវាមិនពិតទេ។ ប៉ុលបង្រៀនថាយើងត្រូវបានសង្គ្រោះដោយសេចក្តីជំនឿ។ ហើយលោកយ៉ាកុបបានបង្រៀនយើងពីសេចក្តីជំនឿដែលនាំឲ្យមានសេចក្តីសង្គ្រោះមានលក្ខណៈយ៉ាងណា។ លោកប៉ុលបានបង្រៀនយើងថា ការទុកចិត្តទៅលើការប្រព្រឹត្តរបស់យើងដើម្បីឲ្យបានសេចក្តីសង្គ្រោះគឺជា ការគ្រោះ

ថ្នាក់យ៉ាងធំ។ លោកយ៉ាកុបបានបង្រៀនយើងថា ការទុកចិត្តទៅលើសេចក្តីជំនឿដែលស្លាប់ គឺជាការគ្រោះថ្នាក់ យ៉ាងធំដែរ។ ម្នាក់ៗកំពុងបង្រៀនសេចក្តីពិតដ៏សំខាន់មួយ។ ពួកគាត់ទាំងពីរ យល់ស្របថាសេចក្តីសង្គ្រោះគឺ ជាអំណោយទានមកពីព្រះជាម្ចាស់ (យ៉ាកុប១: ១៧-១៨; អេភេសូ ២:៨) ទទួលបានដោយសារសេចក្តីជំនឿ (យ៉ាកុប ១:២១; កាឡាទី៣:២៨) ហើយជំនឿពិតត្រូវបានអមដោយការប្រព្រឹត្តល្អត្រឹមត្រូវ (យ៉ាកុប ២:២២; កាឡាទី ៥:៦)។

ឯនាងរ៉ាហាប ជាស្រីសំផឹង ក៏ដូច្នោះដែរ តើនាងមិនបានរាប់ជាសុចរិត ដោយសារការនាងប្រព្រឹត្តទេឬអី គឺក្នុងកាលដែលនាងទទួលពួកអ្នក ដែលគេចាត់មកនោះ ហើយនាងបានឲ្យគេចេញទៅវិញតាមផ្លូវ១ទៀត

**២:២៥** លោកយ៉ាកុប ប្រើនាងរ៉ាហាប ជាឧទាហរណ៍មួយទៀត។ រ៉ាហាប ជាជនជាតិសាសន៍កាណានដែលរស់នៅក្នុងទីក្រុងយេរីខូរ។ យ៉ូស្វេ ដែលជាមេដឹកនាំជនជាតិអ៊ីស្រាអែល បានចាត់អ្នកស៊ើបការណ៍ពីរនាក់ ឲ្យទៅស៊ើបអង្កេតពីទីក្រុង។ រ៉ាហាបជឿថាព្រះជាម្ចាស់ជាព្រះមួយពិត (យ៉ូស្វេ ២:១១) ដូច្នេះនាងបានជួយអ្នកស៊ើបការណ៍ទាំងពីរនោះ (យ៉ូស្វេ ២:២-៥; ហេព្រើរ ១១:៣១)។ ជំនឿរបស់នាងនាំឲ្យនាងធ្វើចេញជាសកម្មភាព។ នេះបានបង្ហាញថា នាងមានជំនឿពិតលើព្រះជាម្ចាស់។ ការមានសេចក្តីជំនឿគឺជាការរស់នៅស្របតាមសេចក្តីពិត ដែលយើងស្គាល់អំពីព្រះ។

នាងរ៉ាហាបមានលក្ខណៈជាច្រើនដែល ខុសប្លែកពីលោកអ័ប្រាហាំ។ នាងជាស្ត្រី ជាសាសន៍ដ៏ទៃនិងជាស្រីពេស្យា។ ប៉ុន្តែពួកគេមានចំណុចរួមមួយ គឺសេចក្តីជំនឿលើព្រះ។ លោកយ៉ាកុប លើកពីមនុស្ស

ពីរនាក់ដែលមានលក្ខណៈខុសគ្នាធ្វើជាឧទាហរណ៍ ដើម្បីបង្រៀនពីសេចក្ដីពិតដ៏អស្ចារ្យមួយនេះ គឺៈ ព្រះអង្គនឹងរាប់ជាសុចរិតអស់អ្នកណាដែលមានសេចក្ដីជំនឿដ៏រស់នៅក្នុងទ្រង់។

ពីព្រោះសេចក្ដីជំនឿ បើគ្មានការប្រព្រឹត្តតាម នោះឈ្មោះថាស្លាប់ហើយ ប្រៀបដូចជារូបកាយ បើឥតមានព្រលឹងវិញ្ញាណទេ នោះក៏ស្លាប់ហើយដែរ។

**២:២៦** ជំនឿដែលគ្មានការប្រព្រឹត្ត គឺប្រៀបដូចជារូបកាយដែលគ្មានវិញ្ញាណ។ គឺជាអ្វីដែលស្លាប់ហើយ។ លោកយ៉ាកុបបានពណ៌នាពីជំនឿគ្មានការប្រព្រឹត្ត គឺជាដូចជំនឿរបស់អារក្ស (ខ ១៩) គ្មានប្រយោជន៍ (ខ ២០) និងស្លាប់ (ខ ១៧, ២៦) ។ គាត់មិនបានបដិសេធថានេះមិនមែនជាជំនឿ នោះទេ ប៉ុន្តែគាត់និយាយថានេះមិនមែនជាជំនឿដែលត្រឹមត្រូវ។ សំនួរដែលលោកអ្នកយ៉ាកុបបានពិចារណានៅក្នុងអត្ថបទនេះគឺថា តើជំនឿប្រភេទណាដែលអាចសង្គ្រោះមនុស្សបាន? ចម្លើយរបស់គាត់ គឺជាជំនឿដែលមិនមែនគ្រាន់តែពាក្យសំដី (ខ ១៤-១៧) ឬ គ្រាន់តែជឿនោះទេ(ខ ១៨-២០) ប៉ុន្តែគឺជាសេចក្ដីជំនឿដែលមានភាពរស់រវើក ហើយបានសម្រេចដោយការប្រព្រឹត្ត។ ជំនឿបែបនេះមានការទុកចិត្ត យ៉ាងអស់ពីចិត្តទៅកាន់ព្រះអង្គ ដោយសារតែដឹងថា មានតែទ្រង់ទេ ដែលអាចសង្គ្រោះបាន (យ៉ូហាន ៦៖៦៦-៦៩)។

**សំណួរឆ្លុះបញ្ចាំង**

- តើជីវិតរស់នៅរបស់ខ្ញុំបានបង្ហាញថាខ្ញុំមានជំនឿដ៏រស់ទៅលើព្រះអម្ចាស់ ដែរឬទេ?

## អណ្ដាត

បងប្អូនអើយ កុំឲ្យធ្វើជាគ្រូច្រើនគ្នាពេកឡើយ ពីព្រោះដឹងហើយថា យើងនឹងត្រូវទោសធ្ងន់ជាងគេ

**៣:១** លោកយ៉ាកុបព្រមានថា វាជាការទទួលខុសត្រូវដ៏ធំ ក្នុងការបង្រៀនក្រុមជំនុំ។ ពាក្យសម្ដីរបស់យើងមានអានុភាពខ្លាំងទៅកាន់អ្នកដទៃ។ ដូច្នេះ គ្រូបង្រៀនត្រូវតែប្រយ័ត្នប្រយែងក្នុងការបង្រៀនសេចក្ដីពិតរបស់ព្រះជាម្ចាស់ មិនមែនបង្រៀនពីគំនិតផ្ទាល់ខ្លួនទេ។ ដើម្បីធ្វើដូចនេះបាន ពួកគេត្រូវចំណាយពេលច្រើនឆ្នាំសិក្សាព្រះគម្ពីរ ហើយត្រូវការជំនួយពីព្រះវិញ្ញាណបរិសុទ្ធដើម្បីយល់ពីព្រះបន្ទូលរបស់ព្រះ។ បន្ទាប់មកនៅពេលបង្រៀន ពួកគេត្រូវរៀបចំមេរៀនរបស់ពួកគេដោយមានការប្រុងប្រយ័ត្ន និង យកចិត្តទុកដាក់។

គ្រូបង្រៀនត្រូវតែរស់នៅឆ្លុះបញ្ចាំងបង្ហាញពីសេចក្ដីពិត ដែលពួកគាត់បង្រៀន តាមរយៈការរស់នៅរបស់ពួកគាត់។ ព្រះជាម្ចាស់ទ្រង់ រំពឹងឲ្យគ្រូបង្រៀនឲ្យមានស្តង់ដាខ្ពស់ចំពោះអាកប្បកិរិយា និង ឥរិយាបថរបស់ពួកគាត់។ ព្រះទ្រង់នឹងមានភាពតឹងរឹងក្នុងការជំនុំជំរះទៅកាន់ ពួកគាត់ ជាងការដែលទ្រង់ជំនុំជំរះ ទៅកាន់មនុស្សឯទៀត។ គ្រូបង្រៀនមានឱកាសល្អ ដើម្បីជួយអោយមនុស្សមានរីកចម្រើននៅក្នុងព្រះជាម្ចាស់។ ប៉ុន្តែប្រសិនបើពួកគាត់ដឹកនាំមនុស្សឲ្យវង្វេង ដោយសារ ការបង្រៀនខុសឆ្គង ឬបង្រៀន ដោយមានចិត្តអាត្មានិយម និង មហិច្ឆតាដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ពួកគាត់នឹងទទួលការជំនុំជំរះ ដោយព្រោះការទាំងនេះ។ នៅពេលដែលយើងយល់ពីការបង្រៀននៅក្នុងក្រុមជំនុំមានការពាក់ព័ន្ធនឹង អ្វីខ្លះ នោះយើងអាចឃើញពីហេតុផលដែលមានមនុស្សតែមួយចំនួនតូចប៉ុណ្ណោះគួរតែធ្វើការនេះ។

ដ្បិតយើងទាំងអស់គ្នាក៏ជំពប់ជាញយៗដែរ បើអ្នកណាមិនបានជំពប់ដោយពាក្យសំដី នោះជាមនុស្ស គ្រប់លក្ខណ៍ហើយ ដែលអាចនឹងទប់រូបកាយទាំងមូលបានដែរ

**៣:២** មូលហេតុមួយទៀតដែលមានមនុស្សមួយចំនួនតូច គួរធ្វើជាគ្រូបង្រៀនព្រះបន្ទូលនៅក្នុង ក្រុមជំនុំនោះថា គ្រូបង្រៀនត្រូវតែឧបករណ៍ដ៏គ្រោះថ្នាក់។ នោះគឺជាអណ្តាត! វាតូច តែមានអំណាច ហើយវាពិបាកក្នុងការគ្រប់គ្រង។ យើងទាំងអស់គ្នាបានធ្វើបាប ដោយសារការនិយាយខុស។ ដោយសារតែអណ្តាត គឺជាផ្នែកមួយដែលពិបាកគ្រប់គ្រងបំផុតនៅក្នុងរាងកាយ ប្រសិនបើនរណាម្នាក់ អាចគ្រប់គ្រងអណ្តាតរបស់ពួកគេ នោះពួកគេក៏អាចគ្រប់គ្រងរាងកាយទាំងមូលរបស់ពួកគេបានដែរ។ ការបកប្រែនៃពាក្យ "គ្រប់គ្រង" (χαλιναγωγῆσαι) មានន័យថា "ដើម្បីទប់" ។ នេះធ្វើឱ្យលោកយ៉ាកុប គិតពីឧទាហរណ៍ អំពីសត្វសេះ។

មើលយើងដាក់ដែកបង្ខាំចុះក្នុងមាត់សេះ ឲ្យវាស្តាប់បង្គាប់តាម ហើយយើងញាក់រូបកាយវាទាំងមូលទៅ បាន

**៣:៣** អ្នកជិះសេះអាចគ្រប់គ្រងទៅកាន់សត្វសេះដោយសារ តែដែកបង្ខាំតូចមួយដាក់ទៅក្នុងមាត់សេះ ។ ដោយសារការដែលគាត់អាចគ្រប់គ្រងមាត់របស់វា ធ្វើឲ្យគាត់គ្រប់គ្រងទៅកាន់រូបកាយទាំងមូល របស់ សេះនោះបាន។ គាត់អាចបញ្ជាសេះអោយទៅតាមទិសដៅដែលគាត់ចង់អោយវាទៅ។

វាជាការស្រដៀងគ្នានេះដែរ ប្រសិនបើមនុស្សម្នាក់អាចគ្រប់គ្រងអណ្តាតផ្ទាល់ខ្លួនបាន គាត់ក៏អាច គ្រប់គ្រងរាងកាយទាំងមូល និងទិសដៅនៃជីវិតរបស់គាត់ដែរ។ ប៉ុន្តែប្រសិនបើគាត់មិនអាច្រប់គ្រង

អណ្តាតរបស់គាត់បានទេ គាត់នឹងនិយាយការដែលខុសឆ្គង ហើយជីវិតរបស់គាត់នឹងដើរឆ្ពោះទៅកាន់ផ្លូវខុស។ ដែកបង្ខាំមានទំហំតូច ប៉ុន្តែមានឥទ្ធិពលយ៉ាងធំទៅកាន់សេះ។ ស្រដៀងគ្នាដែរ អណ្តាតតូច ប៉ុន្តែអ្វីដែលអណ្តាតនិយាយ មានឥទ្ធិពលមកកាន់មនុស្សទាំងស្រុង។

សូមគិតមើលពីសំពៅដែរ វាធំដល់ម្ល៉េះ ហើយមានខ្យល់គំហុកបក់ផាត់ទៅផង តែតែកុងបើកទៅមកបានតាមចិត្ត ក៏ដោយសារតែចង្កូតយ៉ាងតូចប៉ុណ្ណោះ

**៣:៤** លោកយ៉ាកុប ប្រើសំពៅជាឧទាហរណ៍មួយទៀត ដើម្បីបង្ហាញពីរបៀបដែលវត្ថុតូចមួយអាចគ្រប់គ្រងវត្ថុធំមួយបាន ហើយក៏អាចកំណត់ទិសដៅដែលវាត្រូវទៅ។ ចង្កូតក្រោមនៃសំពៅ គឺជាដុំឈើមួយ ឬ ច្រវានៅក្រោមសំពៅ។ នៅពេលអ្នកបើកសំពៅ បែរចង្កូតសំពៅ នោះសំពៅទាំងមូលនឹងបែរទៅតាម។ សំពៅអាចមានទំហំធំ ហើយត្រូវបានរសាត់ដោយកម្លាំងខ្យល់បក់យ៉ាងខ្លាំង ប៉ុន្តែអ្នកបើកសំពៅប្រើ ចង្កូតដ៏តូចមួយ ដើម្បីកំណត់ទិសដៅដែលសំពៅទាំងមូលត្រូវទៅ។ វាក៏មានភាពស្រដៀងគ្នានឹង អណ្តាតដ៏តូចរបស់យើងដែរ ដោយសារតែអណ្តាតយើងអាចកំណត់ពីទិសដៅនៃជីវិតរបស់យើងតាមរយៈ ការដែលយើងនិយាយ ឬ មិននិយាយ។

ឯអណ្តាតក៏ជាអវយវៈ១យ៉ាងតូចដូច្នោះដែរ ប៉ុន្តែ ចេះអួតអាងយ៉ាងសំបើមណាស់ មើលចុះ ភ្លើងតែបន្តិចទេ អាចនឹងឆេះព្រៃធំៗទៅបាន

**៣:៥** អណ្តាតមានមាឌតូចតែមានសមត្ថភាពធំ។ ពាក្យសម្តីរបស់យើងអាចបណ្តាលឱ្យមានរឿងល្អ ឬ គ្រោះថ្នាក់។ នារដូវក្តៅក្នុងប្រទេសអ៊ីស្រាអែល វាលស្មៅ និង គុម្ពោតស្ងួតដូចចំបើង។ អណ្តាតភ្លើងតូច

មួយអាចធ្វើឲ្យវាលទាំងនោះឆាបឆេះបាន។ ហើយអណ្ដាតភ្លើងនោះក៏អាចឆាបឆេះរាលដាលដុត បំផ្លាញ អ្វីៗដែលនៅក្បែរៗនោះផងដែរ។ នៅពេលដែលភ្លើងចាប់ផ្ដើមឆេះហើយ វាពិបាកក្នុងការពន្លត់ណាស់។ មិនយូរប៉ុន្មានវានឹងលែងជាអ្វីដែលអាចទប់ស្កាត់បាន។ នេះបង្ហាញឲ្យឃើញថាភ្លើងតូច អាចឆាបឆេះបំផ្លាញព្រៃដ៏ធំបាន។

ហើយអណ្ដាតក៏ជាភ្លើងដែរ គឺជាលោកីយដ៏ពេញដោយសេចក្ដីទុច្ចរិត ជាគ្រឿងរាប់បញ្ចូលជា ១ នឹងអវយវៈឯទៀតរបស់យើង ជារបស់ដែលធ្វើឲ្យរូបកាយទាំងមូលស្មោកគ្រោក ក៏បញ្ឆេះទាំងផ្លូវជីវិតផង ហើយភ្លើងឆេះនោះមកពីស្ថាននរកដែរ

**៣:៦** ពាក្យសម្ដីរបស់យើងអាចបង្កគ្រោះថ្នាក់ដូចភ្លើងនោះដែរ។ យើងអាចនិយាយពាក្យសម្ដី ដែលបង្កឲ្យមានសេចក្ដីវិនាសដែលរាលដាលដូចជាភ្លើងឆេះព្រៃ។ ...វានឹងរាលដាល យ៉ាងឆាប់រហ័សរហូតដល់យើងលែងអាចគ្រប់គ្រងវាបាន។ អណ្ដាតរបស់យើងអាចចាប់ផ្ដើមការអាក្រក់ ដែលអាចរាលដាល និង ប៉ះពាល់ដល់ជីវិតមនុស្សជាច្រើន។ ពាក្យសម្ដីល្អអាចជាកត្តាជម្រុញលើកទឹកចិត្តទៅជីវិតរបស់នរណាម្នាក់ អស់មួយជីវិត។ ពាក្យសម្ដីមិនល្អ អាចធ្វើឱ្យអ្នកដទៃឈឺចាប់ជាច្រើនឆ្នាំ។ លោកយ៉ាកុបនិយាយថា អណ្ដាតគឺជា "លោកីយ៍ដ៏ពេញដោយសេចក្ដីទុច្ចរិត" ។ គាត់មានន័យថា វាអាចមានសេចក្ដីអាក្រក់គ្រប់ បែបយ៉ាងនៅក្នុងពាក្យសម្ដីរបស់យើង។

លោកយ៉ាកុបបានប្រើរូបភាពជាបន្តបន្ទាប់ដើម្បីឆ្ពោះទៅដល់ចំនុចកំពូលនៃសេចក្ដីបង្រៀនរបស់គាត់។ ដូចជា ភ្លើងឆេះព្រៃដែលកើតពីផ្កាភ្លើងដ៏តូចមួយ នោះភាពទុច្ចរិតចក៏កើតពីអណ្ដាតដ៏តូចរបស់យើងដែរ។ អណ្ដាតដ៏តូចរបស់យើងអាចធ្វើឲ្យ បញ្ហាមានការីករាលដាល។ មនុស្សខ្លះមានការប្រលាក់

ប្រលោះនៅក្នុងជីវិតរបស់ពួកគេ ដោយសារតែពួកគាត់មិនចេះគ្រប់គ្រងអណ្ដាតរបស់ខ្លួន។ ការនេះនឹងជះឥទ្ធិពលដល់ដំណើរជីវិតទាំងមូលរបស់ពួកគេ។ ហើយទីបំផុតអណ្ដាតដែលមិនអាចគ្រប់គ្រងបានបង្កាត់ជាភ្លើងដុតបំផ្លាញអ្វីគ្រប់យ៉ាងដែលនៅជុំវិញខ្លួន ហើយទីបំផុត អណ្ដាតនោះនឹងត្រូវឆាបឆេះដុតឆេះដោយភ្លើងនរក។

រីឯគ្រប់ទាំងពូជសត្វព្រៃ សត្វស្លាប សត្វលូនវារ នឹងសត្វនៅក្នុងសមុទ្រ នោះគេអាចនឹងផ្សាំបាន ក៏មានមនុស្សបានផ្សាំងហើយដែរ ៩តែឯអណ្ដាតវិញ នោះគ្មានអ្នកណាអាចនឹងផ្សាំងបានឡើយ គឺជារបស់អាក្រក់ ដែលទប់មិនបាន ក៏មានពេញដោយពិសដែលនាំឲ្យស្លាប់

**៣:៧-៨** យើងផ្សាំងសត្វបាន ប៉ុន្តែយើងមិនអាចផ្សាំងអណ្ដាតរបស់យើងបានទេ។ អណ្ដាតរបស់យើងអាចនិយាយអាក្រក់ ទោះបីយើងមិនបំណងចង់និយាយការអាក្រក់នោះក៏ដោយ។ អណ្ដាតគឺជារបស់អាក្រក់ ដែលទប់មិនបាន។ វាត្រៀមជានិច្ចក្នុងទំលាយការអាក្រក់ចេញមក។ វាប្រៀបដូចជាពស់ដែលមានពិស អាចសំលាប់មនុស្សបាន។

ដោយសារអណ្ដាត នោះយើងសរសើរដំកើងដល់ព្រះអម្ចាស់ដ៏ជាព្រះវរបិតាផង ហើយដាក់បណ្ដាសាដល់មនុស្ស ដែលកើតមកតាមរូបអង្គព្រះផង

**៣:៩** របៀបល្អបំផុតក្នុងការប្រើប្រាស់អណ្ដាតរបស់យើង គឺយើងត្រូវប្រើប្រាស់វាសម្រាប់ការសរសើរតម្កើងព្រះ។ យ៉ាងណាមិញ យើងក៏ប្រើអណ្ដាតដដែលនោះក្នុងការដាក់បណ្ដាសា។ ការដាក់បណ្ដាសា

គឺជាការបួងសួងកោះហៅឫទ្ធានុភាពខាងវិញ្ញាណ សូមឲ្យមានការអាក្រក់កើតឡើងទៅកាន់នរណាម្នាក់។ ការដាក់បណ្ដាសាទៅកាន់មនុស្សគឺជាអំពើខុសឆ្គង ពីព្រោះមនុស្សត្រូវបានបង្កើតចេញពីរូបអង្គព្រះ។ ដូច្នេះ យើងគួរឲ្យពរទៅកាន់មនុស្ស រួមទាំងខ្មាំងសត្រូវរបស់យើងផងដែរ។

មានទាំងពាក្យសរសើរ នឹងពាក្យប្រទេចផ្ដាសា ចេញមកពីមាត់តែ១នោះឯង បងប្អូនអើយ មិនគួរគប្បីឲ្យមានដូច្នោះឡើយ តើរន្ធទឹកតែ១នឹងអាចចេញជាទឹកសាប ហើយភ្លាវផងបានឬទេ

**៣:១០-១១** លោកយ៉ាកុបបានភ្ញាក់ផ្អើលយ៉ាងខ្លាំងដែល ពាក្យសរសើរ និង ពាក្យបណ្ដាសាចេញពីមាត់តែមួយ។ លោកបានរស់នៅក្នុងប្រទេសអ៊ីស្រាអែល ជាកន្លែងដែលមិនមានភ្លៀងធ្លាក់ច្រើន។ ប្រជាជននៅពីនោះពឹងផ្អែកលើក្បាលទឹកផ្សេងៗ ក្នុងការធ្វើជាប្រភពទឹកសម្រាប់ពួកគេ។ ទឹកសាប (តាមន័យត្រង់ "ទឹកផ្អែម" ) គឺជាទឹកដែលល្អសម្រាប់ការទទួលទាន។ ទឹកល្វីង ឬទឹកអំបិលមិនល្អ សម្រាប់ការទទួលទានទេ។ ទឹកសាប (ផ្អែម) និង ទឹកល្វីង (ភ្លាវ) មិនអាចចេញមកពីប្រភពក្បាលទឹកតែមួយនោះទេ។ ប៉ុន្តែ អណ្ដាតរបស់យើងបញ្ចេញទាំងពាក្យផ្អែម និងពាក្យល្វីងជូរចត់។ ពាក្យសំដីពីរប្រភេទផ្ទុយគ្នា ចេញមកពីអណ្ដាតតែមួយ! លោកយ៉ាកុបកំពុងនិយាយថានេះមិនមែនជាការត្រឹមត្រូវធម្មតានោះទេ។

បងប្អូនអើយ តើដើមល្វាអាចនឹងបង្កើតផ្លែជាអូលីវ ឬដើមទំពាំងបាយជូរបង្កើតផ្លែជាល្វាបានឬទេ ដូច្នេះ គ្មានរន្ធទឹកណាចេញទឹក ជាប្រៃផង សាបផងបានឡើយ។

**៣:១២** ដើមឈើនីមួយៗ អាចបង្កើតផលផ្លែទៅតាម ប្រភេទដើមរបស់ខ្លួនតែប៉ុណ្ណោះ។ ផ្លែរបស់វាចេញមកពីធម្មជាតិរបស់វា។ វាជាការស្រដៀងគ្នាជាមួយនឹង ការដែលក្បាលទឹក មានប្រភេទទឹកតែមួយប៉ុណ្ណោះ។ វាអាចមានទឹកផ្អែម (សាប) ឬ ទឹកល្វីង (ភ្លាវ) តែមិនអាចមានទាំងពីរបានទេ។ ប្រសិនបើលោកអ្នកចង់បង្កើតឲ្យមានទឹកផ្អែម (សាប) យើងមិនត្រូវធ្វើជាក្បាលទឹកដែលល្វីងជូចត់ ឬ ភ្លាវនោះទេ។ ពាក្យសំដីរបស់យើងគឺហូរចេញពីចិត្តរបស់យើង ដូចនេះបើពាក្យសម្ដីរបស់យើងតែងតែរមិនល្អសមរម្យ យើងត្រូវទូលសូមឲ្យព្រះអង្គធ្វើការសំអាតចិត្តរបស់យើង។ គោលដៅរបស់យើងគួរតែជាការដែលយើងចង់និយាយតែពាក្យល្អៗ។

**សំណួរឆ្លុះបញ្ចាំង**

- តើអណ្តាតរបស់ខ្ញុំបង្កើតឲ្យមានពាក្យ ដែលល្អដូចជាទឹកសាប (ផ្អែម) ឬ បង្កើតឲ្យមានពាក្យអាក្រក់ដូចជាទឹកល្វីង (ភ្លាវ) ?

## ប្រាជ្ញាមាន ២ ប្រភេទ

ក្នុងពួកអ្នករាល់គ្នា បើមានអ្នកណាមានប្រាជ្ញា នឹងយោបល់ ត្រូវឲ្យអ្នកនោះសំដែងចេញជាកិរិយាល្អ ដោយសារការដែលខ្លួនប្រព្រឹត្ត ដោយសេចក្តីសុភាពនៃប្រាជ្ញាចុះ

**៣:១៣** ប្រាជ្ញា និងការយល់ដឹង ដូចជាសេចក្ដីជំនឿដែរ យើងត្រូវបង្ហាញពីការនេះតាមរយៈការប្រព្រឹត្តរបស់យើង។ មនុស្សដែលមានប្រាជ្ញា ដឹងពីរបៀបអនុវត្តសេចក្ដីពិតរបស់ព្រះជាម្ចាស់នៅក្នុងជីវិត ប្រចាំថ្ងៃ។ ដូច្នេះ ភ័ស្តុតាងដែលបញ្ជាក់ពីជីវិតមានប្រាជ្ញា គឺជាការរស់នៅប្រចាំថ្ងៃ ដែលមានពេញដោយការចរិយាមាយាទល្អ និង អាកប្បកិរិយាល្អ។ មនុស្សដែលមានប្រាជ្ញាតែងធ្វើការប្រព្រឹត្តរបស់ខ្លួនដោយការសុភាពរាបសារ។ ភាពសុភាពរាបសារ (π ρᾳΰτης) គឺកម្លាំងសុភាព។ នេះគឺជាសមត្ថភាពក្នុងការមានភាពរឹងមាំ ដោយមានការបន្ទាបខ្លួន។ វាគឺ ជាចរិកលក្ខណៈរបស់ព្រះយេស៊ូវ (ម៉ាថាយ ១១: ២៩, ២១:៥) ហើយ ក៏ជាផលផ្លែនៃព្រះវិញ្ញាណ (កាឡាទី ៥:២៣) ផងដែរ ។

បើមានសេចក្តីច្រណែនដ៏ជូរល្វីង នឹងសេចក្តីគំនុំក្នុងចិត្ត នោះកុំឲ្យអួតខ្លួន ឬកុហកទទឹងនឹងសេចក្តីពិតឡើយ

**៣:១៤** ផ្ទុយពីភាពស្លូតបូតនៃប្រាជ្ញា គឺការច្រណែនឈ្នានីស សេចក្តីគំនុំក្នុងចិត្ត និង មហិច្ឆតា អាត្មានិយម។ បុគ្គលដែលច្រណែនអ្នកដទៃ ឬមានសេចក្តីប៉ងប្រាថ្នាអាត្មានិយម ដើម្បីឲ្យតែខ្លួនឯង

បានទទួលសិរីរុងរឿង មិនត្រូវអួតខ្លួនថាមានប្រាជ្ញាឡើយ ព្រោះប្រាជ្ញាដែលពួកគេមានមិនមែនមកពី ព្រះជាម្ចាស់ទេ។

ប្រាជ្ញាយ៉ាងនោះមិនមែនមកពីស្ថានលើទេ គឺជារបស់ផងលោកីយនេះ ហើយក៏ខាងសាច់ឈាម នឹងខាងអារក្សវិញទេតើ

**៣:១៥** ព្រះទ្រង់ គឺជាប្រភពនៃប្រាជ្ញាដ៏ពិត។ ប៉ុន្តែគឺមានប្រាជ្ញាខុសឆ្គងដែលមិនមែនមកពីព្រះជាម្ចាស់ទេ។ "គឺមិនមែនមកពីស្ថានលើនោះទេ"។ លោកយ៉ាកុបបានប្រាប់យើង៣ចំនុចអំពីប្រាជ្ញាខុសឆ្គង (ក្លែងក្លាយ)។

- វាគឺជា "**ប្រាជ្ញាលោកីយ៍**" ។ ប្រាជ្ញាក្លែងក្លាយនេះ សំលឹងមើលទៅកាន់ជីវិត ដោយប្រើប្រាស់ទស្សនៈដែលមានដែនកំណត់របស់លោកីយ៍នេះ។ ប្រាជ្ញានេះមានការផ្តោតទៅលើអ្វីៗ ដែលនៅក្នុងលោកីយ៍នេះ គឺគិតធ្វើយ៉ាងណាឲ្យបានជោគជ័យស្របតាមគុណតម្លៃរបស់ លោកីយ៍នេះ (ភីលីព ៣:១៨-១៩) ។ នេះគឺជាប្រាជ្ញាដែល មិនមានទស្សនៈអស់កល្បជានិច្ច ដែលមកពីស្ថានសួគ៌នោះទេ។
- វាគឺជា "**ប្រាជ្ញាខាងសាច់ឈាម**" ។ "ខាងសាច់ឈាម" ក្នុងពាក្យក្រិក(ψυχική) មានន័យថា ចេញពី "ព្រលឹង ឬគំនិត" ។ វាជាគំនិតរបស់មនុស្ស មិនមែនជាសេចក្តីពិតរបស់ព្រះជាម្ចាស់ ទេ។ ប្រាជ្ញាក្លែងក្លាយមិនមានទស្សនវិស័យខាងវិញ្ញាណទេ ហើយវាផ្តោតតែលើអ្វីដែលបានដឹងតាមរយៈញ្ញាណទាំងប្រាំរបស់យើងតែប៉ុណ្ណោះ។ មនុស្សខាងវិញ្ញាណបានទទួលព្រះវិញ្ញាណ

របស់ព្រះ ប៉ុន្តែមនុស្សខាងសាច់ឈាមមិនបានទទួលឡើយ។ ដូច្នេះពួកគេមិនអាចយល់ពីសេចក្តីពិតខាងវិញ្ញាណនោះទេ។

- វាជា "**ប្រាជ្ញាខាងអារក្ស**" ។ ប្រាជ្ញាក្លែងក្លាយកើតចេញមកពីខ្មាំងសត្រូវ។ នៅក្នុងលោកុប្បត្តិជំ ពូក ៣ យើងឃើញថា សាតាំង ល្បួងមនុស្សដោយពាក្យភូតកុហកដែលទាក់ទាញដល់ ភាពអំនួតរបស់មនុស្ស (ដូចជា "អ្នកមិនស្លាប់ជាពិតមែនទេ" ហើយ "អ្នកនឹងបានដូចជាព្រះ ដែរ" )។ ប្រាជ្ញារបស់អារក្ស គឺជាការកុហកបោកបញ្ឆោតដែលទាក់ទាញទៅកាន់អំនួតរបស់ មនុស្ស ដើម្បីបំផ្លាញពួកគេ។

ដ្បិតកន្លែងណាដែលមានសេចក្តីច្រណែន នឹងសេចក្តីគំនុំ នោះក៏មានវឹកវរ នឹងសេចក្តីអាក្រក់គ្រប់យ៉ាងដែរ

**៣:១៦** ប្រាជ្ញាក្លែងក្លាយ តែងតែនាំទៅរកភាពវឹកវរ និងការអាក្រក់។ នៅពេលដែលយើងច្រណែនអ្នកដទៃ ឬមានមហិច្ឆតាអាត្មានិយម សេចក្តីគំនុំ ការទាំងនោះនឹងបង្វែរយើងចេញពីការផ្តោតលើព្រះអង្គ។ ហើយយើងក៏ធ្វើការសម្រេចចិត្តខុស។ ពាក្យដែលបកប្រែថា "វឹកវរ" មានន័យថា អស្ថិរភាព និងការភាន់ច្រឡំ។ នេះមិនមែនមកពីព្រះជាម្ចាស់ទេ។ លោកប៉ុល បានប្រើពាក្យដូចគ្នា នៅពេលគាត់ សរសេរថា ព្រះអង្គមិនមែនជាព្រះនៃ សេចក្តីវឹកវរទេ (១កូរិនថូស ១៤:៣៣) ។ ប្រាជ្ញាក្លែងក្លាយ នាំអោយមានភាពវឹកវរ អស្ថិរភាព ការប្រកួតប្រជែង និងការបែងបាក់ក្នុងចំណោមមនុស្ស។

តែប្រាជ្ញាដែលមកពីស្ថានលើ នោះមុនដំបូងហៅថាបរិសុទ្ធ រួចមកមានមេត្រីចិត្ត សេចក្ដីសំឡូត ចិត្តទន់ ក៏ពេញដោយសេចក្ដីមេត្តាករុណា នឹងផលល្អ ឥតរើសមុខ ហើយឥតពុតមាយាផង

**៣:១៧** ប៉ុន្តែ ប្រាជ្ញាដែលមកពីព្រះជាម្ចាស់ គឺខុសគ្នាពីប្រាជ្ញាទាំងនោះឆ្ងាយណាស់។ លក្ខណៈសំខាន់នៃប្រាជ្ញារបស់ព្រះជាម្ចាស់ គឺថាប្រាជ្ញារបស់ទ្រង់មានភាពបរិសុទ្ធ។ ប្រាជ្ញាទ្រង់មិនមានឥរិយាបថនៃអំពើបាប។ លោកយ៉ាកុបបានរៀបរាប់ពីគុណ សម្បត្តិនៃប្រាជ្ញាដែលមកពីស្ថានសួគ៌។ គួរកត់សម្គាល់ថា គុណសម្បត្តិនីមួយៗ បង្កើតឲ្យមានភាពចុះ សម្រុងគ្នារវាងមនុស្សនិងមនុស្ស។

**មានមេត្រីចិត្ត៖** វានាំទៅរក ការចុះសម្រុងគ្នា និងសន្តិភាព

**សេចក្ដីសំឡូត៖** វាមានលក្ខណៈគួរសម និងចិត្តល្អ។ គឺជាការយល់ពីចំណុចខ្វះខាតរបស់មនុស្ស ហើយមានការអត់ធ្មត់ជាមួយពួកគេ។

**ចិត្តទន់៖** ទទួលការបង្រៀន ហើយចុះចូលជាមួយក្រមសីលធម៌។ គឺជាការស្ដាប់តាមគំនិតរបស់អ្នកដទៃ ហើយ ឆ្លើយតបយ៉ាងសមរម្យ ដោយគ្មានភាពអាត្មានិយម ។ គឺជាការសុខចិត្តចុះចូលស្រប តាម នៅពេលដែលវាគឺជាអ្វីដែលល្អបំផុត។

**ពេញដោយសេចក្ដីមេត្តាករុណា និងផលល្អ៖** វាជាការអាណិតអាសូរ ការអត់ទោស ហើយតែងតែត្រៀមខ្លួនជានិច្ចក្នុងការជួយដល់ មនុស្សដែលខ្វះខាត។ ការនេះបង្កើតឲ្យមានជីវិតមួយដែលថ្វាយកិត្តិយសដល់ព្រះជាម្ចាស់ គឺជាជីវិតដែលពេញដោយសេចក្ដីស្រឡាញ់ និង ការប្រព្រឹត្តល្អ។

**ឥតរើសមុខ៖** គឺជាការមិនបង្ហាញការរើសអើង ឬ ប្រកាន់បក្សពួកឡើយ។ គឺជាការដែលមានភាពច្បាស់លាស់ពីអ្វីដែលពិតត្រង់ ហើយមានស្តង់ដាត្រឹមត្រូវដែលមានមិនមានភាពផ្លាស់ប្តូរ។

**ឥតពុតមាយា៖** មនុស្សកំពុត បៀបដូចជាតួអង្គពាក់ម៉ាសមុខ ហើយសំដែងជាតួអង្គច្រើនក្នុងការសំដែង។ តែសម្រាប់ ប្រាជ្ញាដែលមកពីព្រះជាម្ចាស់ មិនលាក់ពុត ឬសម្តែងឡើយ តែគឺជាការដែលធ្វើចេញពី ចិត្តទៀងត្រង់នៅគ្រប់ទាំងការដែលខ្លួនធ្វើ។

រីឯផលនៃសេចក្ដីសុចរិត នោះបានព្រោះចុះដោយសេចក្ដីមេត្រី សំរាប់ពួកអ្នកដែលរកសេចក្ដីមេត្រីនោះឯង។

**៣:១៨** លោកយ៉ាកុប សរុបសេចក្ដី ដោយបង្ហាញការប្រៀបធៀបមួយ។ ស្រមៃមើលវាលមួយដែលត្រៀមរួចជាស្រេចសម្រាប់ការប្រមូលផល។ ដំណាំនៅលើវាលនោះ ដាំដុះបង្កើតឲ្យមានសេចក្ដីសុចរិត។ សេចក្ដីសុចរិតបានដុះឡើង នៅលើដីនៃសេចក្ដីមេត្រី។ ព្រះអង្គចង់ឲ្យយើងរស់នៅជីវិត ដែលមានសេចក្ដីសុចរិត ដែលកើតចេញពីសេចក្ដីមេត្រី ដែលមិនមែន កើតចេញពីកំហឹងក្ដៅក្រហាយ ឬ ភាពរឹករវ នោះទេ។ ប្រាជ្ញាដែលមកពីព្រះជាម្ចាស់ជួយអោយយើងក្លាយជាមនុស្សដែលមានសេចក្ដី មេត្រី។

គ្រាប់ពូជនេះត្រូវបានសាបព្រោះដោយពួកអ្នកដែលស្វែងរក សេចក្ដីមេត្រីនោះឯង។ ការធ្វើជាអ្នកដែលស្វែងរកសេចក្ដីមេត្រី នោះគឺជាចរិតលក្ខណៈរបស់អស់អ្នកដែលជាកូនព្រះ។ ពួកអ្នកដែលស្វែងរកសេចក្ដីមេត្រី មានសេចក្ដីស្រឡាញ់ទៅកាន់សេចក្ដីមេត្រី រស់នៅក្នុងសេចក្ដីមេត្រី ហើយបង្កើតបរិយាកាសដែលពោរពេញដោយសេចក្ដីមេត្រី។ ហើយចម្រូត ដែលបានជួយសាងឡើង ដោយពួកអ្នកស្វែងរកសេចក្ដីមេត្រី នឹងបង្កើតឲ្យមានសហគមន៍ ដែលមានសន្តិភាព និង មេត្រីភាព ហើយការប្រព្រឹត្តរបស់ពួកគាត់មានពេញដោយសេចក្ដីសុចរិត។

**សំណួរឆ្លុះបញ្ចាំង៖**

- តើជីវិតរបស់ខ្ញុំឆ្លុះបញ្ចាំងពី សេចក្ដីសុភាពរាបសា និង សេចក្ដីមេត្រី ដែលបានមកពីប្រាជ្ញារបស់ស្ថានសួគ៌ ឬ ជីវិតរបស់ខ្ញុំឆ្លុះបញ្ចាំងពី មហិច្ឆតាអាត្មានិយម សេចក្ដីគំនុំ ភាពរឹករវ

ដែលបានមកពីប្រាជ្ញាក្លែងក្លាយរបស់លោកីយ៍នេះ?

## សេចក្តីប៉ងប្រាថ្នា (សេចក្តីសំរើប)បង្កើតឲ្យ មានភាពរឹករវ។ ព្រះជាម្ចាស់ទ្រង់ប្រទានព្រះគុណ

ឯសេចក្តីទាស់ទែង នឹងសេចក្តីឈ្លោះប្រកែក ក្នុងពួកអ្នករាល់គ្នា នោះមកពីណា តើមិនមែនមកពីសេចក្តីសំរើប ដែលច្បាំងក្នុងអវយវៈរបស់អ្នករាល់គ្នាទេអី

**៤:១** លោកយ៉ាកុបចង់ឲ្យអ្នកអានមានសេចក្តីមេត្រីជាមួយនឹងគ្នា (សុខសន្តិភាព) ព្រោះថា សេចក្តីមេត្រីគឺជាដី ដែលអាចធ្វើឲ្យសេចក្តីសុចរិតអាចលូតលាស់ឡើងបាន។ យ៉ាងណាមិញ ការនេះមិនបានកើតឡើងឡើយ។ លោកយ៉ាកុបបានប្រើពាក្យយោធាពីរពាក្យ ដើម្បីពិពណ៌នា ពីអាកប្បកិរិយារបស់ពួកគេ។ ពាក្យទីមួយគឺ ចម្បាំង ឬ ច្បាំង (សង្គ្រាម) ( π όλεμοι) ពាក្យទីពីរ តយុទ្ធ (μάχαι)។ នៅពេលដែលពួកអ្នកជឿមិនប្រព្រឹត្តខ្លួនឲ្យល្អទៅតាមប្រាថ្នារបស់ព្រះ ក្រុមជំនុំអាចក្លាយទៅជាកន្លែងមួយ ដែលមានលក្ខណៈដូចជាសមរភូមិ ជាកន្លែងដែលមនុស្សអាចធ្វើ ឲ្យគ្នាឈឺចាប់។

លោកយ៉ាកុបសូមឲ្យ ពួកគាត់គិតអំពី តើអ្វីដែលបណ្តាលឲ្យពួកគាត់មានសេចក្តីទាស់ទែង និងសេចក្តីឈ្លោះប្រកែកគ្នា។ ការទាំងនេះកើតឡើងបណ្តាលមកពី សេចក្តីសំរើប (សេចក្តីប៉ងប្រាថ្នា) ដែលច្បាំងនៅក្នុងអវៈយវៈ របស់ពួកគាត់រាល់គ្នា។ សេចក្តីប៉ងប្រាថ្នា នៅក្នុងពាក្យក្រិក (ἡδονή) មានអត្ថន័យអវិជ្ជមាន ហើយ សំដៅទៅលើបំណងប្រាថ្នាដែលស្វែងរកការសប្បាយរីករាយលើសជាងអ្វីៗទាំងអស់។ សេចក្តីប៉ងប្រាថ្នានេះ ទាស់ប្រឆាំងជាមួយនឹងព្រលឹងផ្ទាល់ខ្លួន របស់មនុស្សម្នាក់។ ប្រសិន បើយើងមិន មានសេចក្តីមេត្រីនៅក្នុងយើងនោះទេ យើងក៏មិនអាចមានសេចក្តីមេត្រីជាមួយនឹងអ្វី ដែលនៅជុំវិញ ខ្លួន បានដែរ។ នៅពេលដែលមនុស្សមានសេចក្តីប៉ងប្រាថ្នា នៅក្នុងពួកគេ

វាតែងតែរ នាំឆ្ពោះ ទៅកាន់ ការឈ្លោះប្រកែក និង ការតយុទ្ធគ្នា។ សេចក្តីបងប្រាថ្នា ដែលមានពេញដោយភាពអាត្មានិយម  សេចក្តីច្រណែន ធ្វើឲ្យមនុស្សគ្រប់គ្នាមានការប្រកួតប្រជែងជាមួយគ្នាចង់ឈ្នះចង់ចាញ់ បង្កើតឲ្យ មានសត្រូវ ការសម្លប់គ្នា នៅកន្លែងដែលគួរតែមានសេចក្តីរួបរួមសាមគ្គីជំនួសឲ្យមានការ អរិជ្ជមាន ទាំងអស់នេះ។ អ្នកអានសំបុត្ររបស់លោកយ៉ាកុប គឺជាពួកអ្នកជឿ ប៉ុន្តែពួកគេដើរតាម តាមប្រាជ្ញា  ប្រាជ្ញាសាច់ឈាម និង ប្រាជ្ញារបស់អារក្ស ដែលប្រាជ្ញាទាំងនេះបង្កើតឲ្យមានសេចក្តីច្រណែនឈ្នានីស និង មហិច្ឆតាអាត្មានិយម។

អ្នករាល់គ្នាសង្វាតចង់បាន តែមិនបានទេ អ្នករាល់គ្នាសំឡាប់គេ ហើយមានចិត្តច្រណែន តែពុំអាចនឹងបានឡើយ ក៏ឈ្លោះប្រកែក ហើយតយុទ្ធគ្នា តែមិនបានអ្វីសោះ ពីព្រោះមិនសូម

**៤:២** លោកយ៉ាកុបបង្ហាញពីទំនាក់ទំនងរវាង សេចក្តីប្រាថ្នា សង្វាតចង់បាន (ហេតុ) និង ភាពរីកវរ (ផល)។

| **ហេតុ** | | **ផល** |
|---|---|---|
| អ្នករាល់គ្នាសង្វាតចង់បាន តែមិនបាទេ | → | ដូច្នេះអ្នករាល់គ្នាសំឡាប់គេ |
| ហើយមានចិត្តច្រណែនតែពុំអាចបានឡើយ | → | ដូច្នេះក៏ ឈ្លោះប្រកែក ហើយតយុទ្ធគ្នា |

លោកយ៉ាកុបបានពណ៌នាអំពីអាកប្បកិរិយារបស់ពួកគេថា ដូចជា  "ចម្បាំង"  និង  "ការតយុទ្ធគ្នា" (ខ១) ដូច្នេះវាទំនងជា  "អ្នករាល់គ្នាសំឡាប់"  មានន័យថាមាន  "កំហឹង និងការស្អប់" ដែលមានន័យការ សំឡាប់មនុស្ស ដែលបានកើតឡើងនៅក្នុងចិត្ត (ម៉ាថាយ ៥:២១-២២) ។

ដើម្បីចៀសវាងការឈ្លោះប្រកែក និង ការប្រយុទ្ធនឹងគ្នា (តយុទ្ធគ្នា) យើងត្រូវយកឈ្នះបង្ក្រាបទៅលើសេចក្ដីប៉ងប្រាថ្នា អាត្មានិយមរបស់យើង។ វាគឺជាបំណងប្រាថ្នារបស់យើង ដែលយើងត្រូវតែយកឈ្នះ មិនមែនយកឈ្នះលើគ្នាទៅវិញទៅមកនោះទេ។

មូលហេតុដែលពួកគេមិនអាចទទួលបានអ្វីដែលពួកគេចង់បាន គឺដោយសារតែពួកគេកំពុងព្យាយាមស្វែងរកការទាំងនោះ នៅក្នុងផ្លូវខុស។ ជំនួសឱ្យការទូលសូមទៅកាន់ព្រះ និងការទុកចិត្តទៅ លើការផ្គត់ផ្គង់របស់ទ្រង់ ពួកគេបែរជាមានពេញដោយការច្រណែនលោភលន់ និង ការច្បាំងប្រយុទ្ធប្រឆាំងនឹងគ្នា។

អ្នករាល់គ្នាក៏សូមដែរ តែមិនបានទេ ដ្បិតសេចក្ដីសំណូមនោះបែបអាក្រក់ សំរាប់នឹងចាយបំពេញសេចក្ដីសំរើបរបស់អ្នករាល់គ្នាវិញ

**៤:៣** ព្រះជាម្ចាស់នឹងមិនប្រទានមកយើងតាមការសូមរបស់យើងនោះទេ ប្រសិនយើងមានសេចក្ដីសំណូមបែបអាក្រក់ (សំណូមខុសឆ្គង) ។ លោកយ៉ាកុបបាន ពន្យល់អំពីអ្វីដែលសំណូមបែបអាក្រក់របស់ពួកគេ។ សំណូមអាក្រក់ទាំងនោះគឺជាការដែលពួកចង់បាន សម្រាប់ជាការបំពេញ សេចក្ដីសំរើបរបស់ពួកគេ ដែលជាការចាយ បង្ហិនដើម្បីបំពេញទៅកាន់បំណងប្រាថ្នាអាត្មានិយម ដើម្បីឲ្យបានសេចក្ដីស្រើបស្រាល និង ភាពរីករាយ។

ឱពួកកំផិតទាំងប្រុសទាំងស្រីអើយ តើមិនដឹងទេឬអីថា ដែលស្រឡាញ់ដល់លោកីយ នោះគឺជាស្អប់ដល់ព្រះហើយ ដូច្នេះ អ្នកណាដែលចូលចិត្តចង់ធ្វើជាមិត្រសំឡាញ់នឹងលោកីយ នោះឈ្មោះថា បានតាំងខ្លួនជាខ្មាំងសត្រូវនឹងព្រះវិញ

**៤:៤** នៅពេលដែលអ្នកជឿរត់តាមសេចក្តីប៉ងប្រាថ្នាដ៏អាត្មានិយម ដើម្បីឲ្យបានការសប្បាយរីករាយរបស់លោកីយ៍ នេះមានន័យថាពួកគេកំពុងតែមិនស្មោះត្រង់ចំពោះព្រះ។ ពួកគេសំលឹងទៅកាន់លោកីយ៍ ចង់បានការស្កប់ស្កល់ពីលោកីយ៍ ជាជាងការស្វែងការស្កប់ស្កល់ដ៏ពិតប្រាកដ ដែលស្ថិតនៅក្នុងព្រះអម្ចាស់។

ព្រះគម្ពីរសញ្ញាចាស់ពណ៌នាអំពីទំនាក់ទំនងនៃការតាំងសញ្ញា រវាងព្រះជាម្ចាស់ និងអ៊ីស្រាអែលថាដូចជាអាពាហ៍ពិពាហ៍មួយ។ ប៉ុន្តែពេលខ្លះ អ៊ីស្រាអែលបានងាកចេញពីព្រះជាម្ចាស់ ទៅកាន់ការថ្វាយបង្គំរូបព្រះ ដែលគឺជាការថ្វាយបង្គំព្រះក្លែងក្លាយ។ ព្រះជាម្ចាស់បានពណ៌នាអាកប្បកិរិយានេះថាជាអំពើ “កំផិត (ការផិតក្បត់)” ពីព្រោះពួកគេមិនស្មោះត្រង់នឹងទ្រង់។ តាមរយៈព្រះគម្ពីសញ្ញាថ្មីបាននាំយើង ឃើញថាក្រុមជំនុំ គឺជាកូនក្រមុំរបស់ព្រះគ្រីស្ទ (វិវរណៈ ១៩,២១)។ ប៉ុន្តែ លោកយ៉ាកុបនិយាយថាពួកគេក៏កំពុងប្រព្រឹត្តកំផិតដែរ! ពួកគេមិនបានស្រឡាញ់ព្រះជាម្ចាស់ ដូចដែលពួកគេគួរធ្វើនោះទេ ផ្ទុយទៅវិញពួកគេបានស្រលាញ់អ្វីៗដែលជារបស់ផងលោកីយ៍វិញ។ លោកីយ៍ឲ្យតម្លៃទៅកាន់ សេចក្តីប៉ងប្រាថ្នា ទ្រព្យសម្បត្តិ ឋានៈបុណ្យសក្តិ និង សេចក្តីរីករាយផ្លូវអារម្មណ៍លើសជាងអ្វីៗទាំងអស់។ ការទាំងនេះបានក្លាយជាព្រះក្លែងក្លាយនៅក្នុងជីវិតរបស់មនុស្សជាច្រើន ហើយពួកគេថ្វាយបង្គំទៅកាន់ការទាំងនេះ ជាជាងការថ្វាយបង្គំទៅកាន់ព្រះដ៏ពិត។

លោកយ៉ាកុប បានប្រមានយើងអំពី ការធ្វើជាមិត្តសំឡាញ់នឹងលោកីយ៍។ ពាក្យភាសាក្រិកសម្រាប់ពាក្យថាមិត្តសំឡាញ់នៅទីនេះ(φιλία) ចំណងផ្លូវអារម្មណ៍យ៉ាងរឹងមាំ វាដូចជាប្រភេទមួយ នៃសេចក្តីស្រឡាញ់។ អស់អ្នកណាដែលបាន សម្រេចចិត្តធ្វើជាមិត្តសំឡាញ់របស់លោកីយ៍ នោះឈ្មោះថាតាំងខ្លួនជាខ្មាំងសត្រូវនឹងព្រះវិញ (រ៉ូម ៨៖៥-៧) ។ អស់អ្នកណាដែលធ្វើជា មិត្តសំឡាញ់របស់លោកីយ៍ ពួកគាត់នឹងមានការឲ្យតម្លៃដូចជាលោកីយ៍ ដែរ។ លោកីយ៍ស្អប់ព្រះ (យ៉ូហាន៣: ១៩-២០, ១៥:១៨-២៥)។ បុគ្គលណាមួយដែលរឹងតែចង់បាន ការទទួលស្គាល់ពីលោកីយ៍ អ្នកនោះនឹងរឹតតែឃ្លាតឆ្ងាយចេញពីព្រះ។ ការធ្វើជាមិត្តសំឡាញ់នឹង លោកីយ៍នឹងដឹកនាំឆ្ពោះទៅកាន់ ការស្រលាញ់លោកីយ៍ (១ យ៉ូហាន ២:១៥-១៧, ២ ធីម៉ូថេ ៤:១០) ធ្វើការត្រាប់តាមលោកីយ៍ (រ៉ូម ១២:២) ហើយចុងបញ្ចប់នឹងទទួលការកាត់ទោសជាមួយលោកីយ៍ដែរ (១ កូរិនថូស ១១:៣២)។ ដូចនេះយើងត្រូវតែធ្វើការជ្រើសរើសឲ្យច្បាស់ថា តើយើងត្រូវធ្វើជាមិត្តសំឡាញ់ជាមួយលោកីយ៍ ឬ ធ្វើជាមិត្តសំឡាញ់ជាមួយនឹងព្រះ។

ឬតើអ្នករាល់គ្នាស្មានថា គម្ពីរសំដែងចេញជាឥតប្រយោជន៍ឬអី រីឯព្រះវិញ្ញាណដែលបានសណ្ឋិតនៅក្នុងយើង ទ្រង់រំឭកដល់យើង ដោយមានព្រះហឫទ័យប្រចណ្ឌ

**៤:៥** ព្រះអង្គចង់ឲ្យយើងថ្វាយជីវិតរបស់យើងទៅកាន់ទ្រង់ឲ្យអស់អំពីចិត្តរបស់យើង។ ដ្បិតទ្រង់គឺជាព្រះដែលមានសេចក្តីប្រច័ណ្ឌ (និក្ខមនំ ២០:៥, ៣៤:១៤)។ ដោយសារតែពាក្យថា ប្រច័ណ្ឌអាចមានន័យអវិជ្ជមាន មនុស្សមួយចំនួនអាចមិនយល់ពីព្រះអង្គថាទ្រង់ គឺជាព្រះដែលមានសេចក្តីប្រច័ណ្ឌ។ យើងត្រូវតែមានការដឹងខ្លួនថា យើងមានការតាំងសញ្ញាជាមួយព្រះ ដូចជាការរៀបអាពាហ៍ ពិពាហ៍ដែរ។

ប្តីគឺជាអ្នកដែលផ្គត់ផ្គង់គ្រប់យ៉ាងទៅកាន់ប្រពន្ធ ហើយគ្មានប្តីឯណាសប្បាយចិត្តនោះទេ នៅពេលដែលគាត់ដឹងថា ប្រពន្ធរបស់គាត់មិនមានភាពស្មោះត្រង់ចំពោះគាត់។ ហើយបើគាត់គិត ថាការនេះគឺជាការដែលអាចទទួលយកបាន នេះបង្ហាញឲ្យឃើញថាគាត់មិនខ្វល់ពីអាពាហ៍ពិពាហ៍ របស់គាត់នោះទេ។ យើងគួរតែ មានភាពសប្បាយរីករាយ ចំពោះការដែលយើងមានព្រះអង្គ ដែល ទ្រង់មានសេចក្តីប្រច័ណ្ឌ ហើយមាន ការឲ្យតំលៃមកកាន់ទំនាក់ទំនងរបស់ទ្រង់ជាមួយយើង ហើយទ្រង់ ក៏រំពឹងឲ្យយើងឲ្យតំលៃទៅកាន់ទំនាក់ទំនងនេះផងដែរ។

តែទ្រង់ផ្តល់ព្រះគុណមកកាន់តែខ្លាំងឡើង ហេតុនោះបានជាទ្រង់មានបន្ទូលថា «ព្រះទ្រង់ទាស់ទទឹងនឹងពួកមានឫកធំ តែទ្រង់ផ្តល់ព្រះគុណមកពួករាបសាវិញ»

**៤:៦** យើងអាចមានទំនាក់ទំនងជាមួយព្រះអង្គបាន គឺដោយសារតែព្រះគុណរបស់ទ្រង់។ ព្រះគុណគឺជាអ្វីដែលព្រះអង្គបានប្រទានឲ្យយើង ហើយគ្មានអ្វីដែលយើងអាចធ្វើបាន ដើម្បីធ្វើឲ្យយើងសក្តិសមទទួលព្រះគុណរបស់ទ្រង់ឡើយ។ ព្រះគុណ គឺជាការដែលព្រះអង្គបានឈោងព្រះហស្តទ្រង់មកកាន់មនុស្សយើង ដើម្បីប្រទានពរ និង ការល្អ ទោះបីជាយើងមិនសក្តិសមទទួលការទាំងនោះក៏ដោយ។ គ្រប់ទាំង ព្រះពររបស់ព្រះមកកាន់យើងជីវិតរបស់យើង គឺកើតឡើងដោយសារព្រះគុណរបស់ព្រះ។

ព្រះគម្ពីរសុភាសិត ៣:៣៤ បានប្រាប់យើងថាតើព្រះជាម្ចាស់ទ្រង់ផ្តល់ព្រះគុណទ្រង់ទៅកាន់អ្នកណាខ្លះ។ គឺអស់អ្នកណាដែលចេះបន្ទាបខ្លួន (មនុស្សរាបសារ)។ ការបន្ទាបខ្លួន (ταπεινοῖς) គឺជាការ "ធ្វើឲ្យខ្លួនទាបចុះ"។ នៅក្នុងភាសាក្រិកពាក្យនេះគឺត្រូវបានពណ៌នាអំពីរុក្ខជាតិដែលដុះលូតលាស់ផ្តេកដើមគាកនឹងដី។ ដើមឈើ ទាំងនេះលូតលាស់ ដោយមានកំពស់ទាបផ្តេកគាកនឹងដី។ មនុស្សបន្ទាប

ខ្លួនស្គាល់ពីចំនុចខ្សោយ របស់ពួកគេ ដូច្នេះពួកគេសំលឹងមើលទៅកាន់ព្រះអង្គ ហើយពឹងផ្អែកទៅលើទ្រង់ ហើយទ្រង់ក៏ប្រទាន ព្រះគុណទ្រង់ទៅកាន់ពួកគេ។

ចំនុចដែលផ្ទុយពីការបន្ទាបខ្លួនគឺជាអំនួត ហើយព្រះទ្រង់ទាស់ប្រឆាំងអស់អ្នកណាដែលមានអំនួត (មនុស្សឫកធំ)។ ពាក្យក្រិកសម្រាប់ពាក្យថាអំនួត (ឫកធំ) (ὑπερηφάνοις) មកពីពាក្យ "ὑπέρ" មានន័យថា លើសពី ឬ ជ្រុល, ហើយ "φαίνω" មានន័យថាជះពន្លឺ។ ពាក្យទាំងពីនេះបូកបញ្ចូលគ្នាមានន័យថា ការជះពន្លឺជ្រុល។ មនុស្សមានអំនួត ស្វែងរកសិរីល្អសម្រាប់តែខ្លួនឯង ជាជាងការដែលថ្វាយសិរីល្អទៅកាន់ព្រះ ដែលបានបង្កើតពួកគេ។ ពួកមិនដឹងខ្លួនថាពួកគេត្រូវការព្រះ ហើយគិតក្នុងចិត្តថាពួកគេអាចរស់នៅមានជីវិត ដោយគ្មានទ្រង់បាន។ ពួកគេបានបែរចេញពីម្ចាស់ជីវិតរបស់ពួកគេ ដូច្នេះទ្រង់ក៏បានបែរចេញពីជីវិត របស់ពួកគេដែរ។ ព្រះអង្គទាស់ប្រឆាំងជាមួយនឹង មនុស្សមានអំនួត (មនុស្សឫកធំ)។ ទ្រង់បានរៀបចំព្រះអង្គទ្រង់ទាស់ប្រឆាំងនឹងពួកគេ ដូចជានៅសមរភូមិ (ἀντιτάσσεται) ពីព្រោះតែការបះបោរប្រឆាំងរបស់ពួកគេទាស់ប្រឆាំងនឹងទ្រង់។

ដូច្នេះ ត្រូវចុះចូលចំពោះព្រះ ហើយតស៊ូនឹងអារក្សវិញចុះ នោះវានឹងរត់ចេញពីអ្នករាល់គ្នាទៅ

**៤:៧** លោកយ៉ាកុបបង្ហាញពី ១០ ជំហាន ដែលនិយាយពីរបៀបនៃការទទួល ព្រះគុណរបស់ព្រះ។

១) **ចុះចូលចំពោះព្រះ**។ ការចុះចូលមានន័យថា លោកអ្នកដាក់ខ្លួននៅក្រោមសិទ្ធិអំណាច។ នៅក្នុងភាសាក្រិកនេះត្រូវបានគេប្រើនៅក្នុងជួរទាហាន ដែលមានន័យថាស្ថិតនៅក្រោមបង្គាប់បញ្ជា។ ពាក្យនេះត្រូវបានប្រើដើម្បីនិយាយអំពី កូនទាហានស្ថិតនៅក្រោមអំណាចរបស់មេបញ្ជាការ។ លោកយ៉ាកុបកំពុងប្រាប់មកកាន់យើង ឲ្យដាក់ខ្លួនយើងនៅក្រោមសិទ្ធិអំណាចរបស់ព្រះ ដោយទទួលស្គាល់

ថាទ្រង់គឺជាម្ចាស់នៃជីវិតរបស់យើង ហើយធ្វើតាមពាក្យបង្គាប់បញ្ជារបស់ទ្រង់។ ការចុះចូលទៅកាន់ព្រះនឹងនាំយើងឆ្ពោះទៅកាន់ ការស្តាប់បង្គាប់ធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់ សម្រាប់ជីវិតយើង។ ព្រះអង្គសម្រេចកិច្ចការធំៗ តាមរយៈការដែលទ្រង់ប្រើមនុស្សផ្សេងៗ ដែលចុះចូលជាមួយទ្រង់ដោយមានការបន្ទាបខ្លួន។

២) **តស៊ូនឹងអារក្ស**។ ការតស៊ូ (ἀνθίστημι) មានន័យថា យកជំហរប្រឆាំង។ ពាក្យនេះត្រូវបានប្រើនិយាយពីកងទ័ព ដែលមិនព្រមដកថយ ដោយមិនចង់បានបាត់បង់ដែនដី ដែលពួកគាត់កាន់កាប់។ ដូចគ្នាជាមួយការនេះ យើងការពារការគ្រប់យ៉ាងដែលព្រះអង្គបានប្រទានមក កាន់យើងដោយធ្វើការប្រឆាំងជាមួយនឹងការវាយប្រហាររបស់ខ្មាំងសត្រូវ។ គ្រប់ពេលដែលយើងតស៊ូ ជាមួយនឹងអារក្សនោះវានឹងរត់ចេញ។ នេះគឺជាសេចក្តីសន្យាទៅកាន់អ្នកជឿគ្រប់គ្នា មិនថាគាត់ជាអ្នក ដែលទើបតែជឿព្រះ ឬ ជាអ្នកជឿដែលមានភាពទន់ខ្សោយប៉ុណ្ណានោះទេ។ របៀបដែលយើងអាចធ្វើការតស៊ូជាមួយនឹង អារក្សបាន គឺដោយយើងធ្វើការចុះចូលជាមួយនឹងព្រះ។ នោះយើងនឹងអាចប្រើ ប្រាស់សិទ្ធិអំណាចនៃព្រះបន្ទូលរបស់ព្រះ ប្រឆាំងជាមួយនឹងអារក្ស ដូចជាការដែលព្រះយេស៊ូវបានធ្វើ នៅក្នុងគម្ពីរម៉ាថាយ ៤:១-១១។

ត្រូវចូលទៅជិតព្រះ នោះទ្រង់នឹងចូលមកជិតអ្នករាល់គ្នាដែរ ឱពួកមានបាបអើយ ចូរលាងដៃឲ្យស្អាតចុះ ឱពួកអ្នកមានចិត្ត២អើយ ចូរសំអាតចិត្តឡើង

**៤:៨** ៣) **ត្រូវចូលមកជិតទ្រង់** នោះទ្រង់នឹងចូលមកជិតអ្នករាល់គ្នាដែរ។ នេះគឺជាសេចក្តីសន្យា និងជាការអញ្ជើញ។ ការសន្យាទាំងពីនេះបានលើកទឹកចិត្តដល់អ្នកជឿថា ៖ អារក្សនឹងរត់ចេញពីអ្នករាល់គ្នា ហើយព្រះទ្រង់ចូលមកជិតអ្នករាល់គ្នា។ សេចក្តីពិតដ៏អស្ចារ្យក្រៃលែង គឺជាការដែលលោកអ្នកអាចចូល

មកកាន់ព្រះដ៏មានអំណាចព្រះចេស្ដា ទ្រង់គឺជាព្រះអទិករ ដែលបានបង្កើតចក្រវាឡ។ នៅពេលដែលយើងចូលមកជិតទ្រង់ នោះយើង នឹងឃើញថា ទ្រង់ស្វាគមន៍យើងជាកូនស្ងួនភ្ងារបស់ទ្រង់ ហើយការនេះគឺជាព្រះពរយ៉ាងធំធេង លើសពីការដែលយើងអាចនឹកស្មានដល់ ។ ដូច្នេះចូរឲ្យយើងចូលមកជិតព្រះអង្គចុះ។

៤) **ចូរលាងដៃអ្នកឲ្យស្អាតចុះ**។ លោកយ៉ាកុបមិនបានហៅពួកអ្នកអាន ថា "បងប្អូន" ដូចជាការធម្មតាដែលគាត់ធ្វើនោះឡើយ នៅក្នុងសំបុត្រនេះ។ តែផ្ទុយទៅវិញគាត់បានហៅពួកគាត់ថា "ពួកមនុស្សមានបាបអើយ"។ សេចក្ដីប៉ងប្រាថ្នារបស់ពួកគាត់ ដែលជាការចង់ ចង់បានអ្វីៗដែលនៅក្នុងលោកីយ៍នេះ បានទាញពួកគាត់ចេញពីឆ្ងាយពីព្រះ។ ដូចនេះហើយបានជាលោកយ៉ាកុបបានប្រាប់ពួកគាត់ ឲ្យលាង សម្អាតដៃរបស់ពួកគាត់ឲ្យបានស្អាត។ ការលាងសម្អាតដៃ គឺជាផ្នែកមួយនៃពិធីញែកខ្លួនចេញជាបរិសុទ្ធ របស់ពួកសង្ឃនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ប្រយោគដែលថា ចូរលាងដៃឲ្យស្អាតចុះ បានក្លាយជារបៀបមួយនិយាយថា ចូរបែរចេញពីអំពើបាប ។ លោកយ៉ាកុប និយាយសំដៅទៅលើអត្ថន័យបែបនេះឯង។

៥) **ចូរសំអាតចិត្តឡើង**។ មុននេះលោកយ៉ាកុបបានប្រើពាក្យ "អ្នកមានចិត្តពីរ" សម្រាប់សំដៅទៅលើអ្នកណាដែលមិនមានការសម្រេចចិត្តច្បាស់លាស់រវាង សេចក្ដីជំនឿ និងការសង្ស័យ (១:៥-៨)។ នៅត្រង់នេះ "អ្នកមានចិត្តពីរ" គឺជាការនិយាយសំដៅលើអ្នកណា ដែលកំពុងប៉ុនប៉ងចង់ ធ្វើជាមិត្តសំឡាញ់របស់លោកីយ៍ផង និង មិត្តសំឡាញ់ជាមួយនឹងព្រះផង ហើយគាត់ក៏កំពុងព្យាយាមក្នុងការបម្រើព្រះផង និង បម្រើខ្លួនឯងផង។

ដំណោះស្រាយទៅលើការនេះគឺជា ដែលពួកគាត់ត្រូវសំអាតចិត្តរបស់ពួកគាត់ឲ្យបានស្អាតឡើង។ ដើម្បីធ្វើការសម្អាតចិត្ត លោកអ្នកត្រូវតែដាក់ចិត្តដាក់កាយថ្វាយខ្លួនទាំងស្រុងទៅកាន់ទ្រង់។ បើសិន

ផ្នែកខ្លះនៃចិត្តរបស់យើង គឺជារបស់ព្រះ ហើយផ្នែកខ្លះទៀតគឺជារបស់ផងលោកីយ៍ យើងត្រូវសំអាត ចិត្តរបស់យើង ដើម្បីឲ្យយើងអាចថ្វាយចិត្តរបស់យើងទាំងស្រុងទៅកាន់ព្រះ។

ចូរឲ្យមានសេចក្តីទុក្ខ ហើយយំសោក ទាំងស្រក់ទឹកភ្នែកចុះ សូមឲ្យសំណើចរបស់អ្នករាល់គ្នា ត្រឡប់ជាដំងូរ ហើយឲ្យសេចក្តីអំណរទៅជាសេចក្តីព្រួយវិញ

**៤:៩ ៦-៩) ចូរឲ្យមានសេចក្តីទុក្ខ ហើយយំសោក ទាំងស្រក់ទឹកភ្នែកចុះ សូមឲ្យសំណើចរបស់ អ្នករាល់គ្នាត្រឡប់ជាដំងូរ ហើយឲ្យសេចក្តីអំណរទៅជាសេចក្តីព្រួយវិញ។**

ចំនុចទាំងអស់នេះកើតមាន ឡើងអមជាមួយនឹងការប្រែចិត្ត។ សេចក្តីទុក្ខសោក (ταλαιπωρήσατε) នាំឲ្យមានទុក្ខ ហើយ សេចក្តី យំសោក (កាន់ទុក្ខ) (πενθήσατε) គឺបានបង្ហាញឲ្យឃើញពីការបាត់បង់ ដ៏ធំធេងដូចជាការបាត់បង់ជីវិត របស់នរណាម្នាក់នៅក្នុងគ្រួសារ ឬ មនុស្សជាទីស្រលាញ់។ ទាំងស្រក់ទឹកភ្នែកចុះ (ការស្រែក ទ្រហោយំ) គឺ (κλαύσατε) គឺជាការបន្លឺសំលេង ស្រែកទ្រហោយំ យ៉ាងខ្លាំង។ នេះគឺជា ការឆ្លើយតប យ៉ាងត្រឹមត្រូវនៅពេល ដែលយើងមើលឃើញយ៉ាងច្បាស់ថា អំពើបាបរបស់យើងអាក្រក់ ប៉ុណ្ណា។ តើលោកអ្នកធ្លាប់មានបទពិសោធន៍ជាមួយនឹងការទាំងនេះដែរ ឬទេ? បើអត់ ចូរទូលសូមឲ្យព្រះអង្គ ប្រទានមកកាន់លោកអ្នក នូវអំណោយទាននៃការប្រែចិត្តចេញពី អំពើបាប។

ប្រសិនបើយើងមានចិត្តគំនិត២ ហើយស្រលាញ់លោកីយ៍ នោះយើងនឹងមិនមានការយល់ច្បាស់ថា តើអំពើបាបរបស់យើង វាអាក្រក់ប៉ុណ្ណានោះទេ។ ប៉ុន្តែ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធ បានចាក់ ចុចចិត្តរបស់យើង បង្ហាញឲ្យយើងឃើញពីអំពើបាប សេចក្តីសុចរិត និង សេចក្តីជំនុំជំរះ (យ៉ូហាន ១៦:

៨) នោះយើងនឹងមាន សេចក្ដីទុក្ខសោក ទួញសោក ស្រែកទ្រហោយំ ចំពោះអំពើបាបរបស់យើង។ ការនេះកើតឡើងដោយសារតែយើងដឹងថា អំពើបាបយើងអាក្រក់ប៉ុណ្ណា ហើយវាបានធ្វើឲ្យយើងមានការបាត់បង់ខូចខាតច្រើនប៉ុណ្ណាមកកាន់យើង មកកាន់មនុស្សជុំវិញខ្លួនយើង ហើយ ជាពិសេសទៅធ្វើឲ្យ ព្រះអង្គមានការបង់ថ្លៃយ៉ាងធំធេងដើម្បីសង្គ្រោះយើងឲ្យរួចពីបាប គឺទ្រង់បានបញ្ជូនព្រះយេស៊ូវមក សុគតជំនួសអំពើបាបរបស់យើង។  ឥទ្ធិពលនៃសេចក្ដីព្រួយដែល គាប់ ព្រះទ័យព្រះ គឺត្រូវបាន បើកសម្ដែងឡើងនៅក្នុង ២ កូរិនថូស ៧:១០។ ពេលវេលានៃសេចក្ដីព្រួយ ចិត្តនេះមិននៅជានិច្ចតទៅនោះទេ ប៉ុន្តែវាជាដំណាក់ដែលចាំបាច់ត្រូវ កើតឡើងនៅពេលដែលយើង ប្រែចិត្ត ជាអ្វីដែលនាំឆ្ពោះទៅកាន់ជីវិត។

ចូរបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់ នោះទ្រង់នឹងដំកើងអ្នករាល់គ្នាឡើង។

**៤:១០** ១០) **ចូរបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់**។ នៅពេលមនុស្សដឹងថាពួកគេនៅក្នុងព្រះវត្ត មានព្រះនោះពួកគេនឹងត្រូវបានបន្ទាបខ្លួនចុះ (និក្ខមនំ ៣:៦, អេសាយ ៦:៥)។ នេះគឺមកពី ភាពគ្មានដែនកំណត់នៃភាពបរិសុទ្ធ ភាពអស្ចារ្យ និង ភាពរុងរឿងរបស់ព្រះ។ ដូច្នេះហើយ បានជា លោកយ៉ាកុបបានប្រាប់ទៅកាន់អ្នកអានរបស់គាត់ ឲ្យចូលមកកាន់ព្រះដោយមានឥរិយាបថបន្ទាបខ្លួន។ យើងធ្វើការបន្ទាបខ្លួនយើង តាមរយៈការដែលយើងទទួលស្គាល់ថា យើងមានការពឹង ផ្អែកទាំង ស្រុងទៅកាន់ព្រះ ទៅលើចំនុចគ្រប់យ៉ាងនៃជីវិតរបស់យើង។ មានតែអស់អ្នកដែល ចូលមកកាន់ទ្រង់ ដោយការបន្ទាបខ្លួនទេដែលអាចស្គាល់ពីព្រះពរនៃការដែលទ្រង់ដំកើងពួកគាត់ឡើង។ នេះគឺជាសេចក្ដី សន្យាទី៣ នៅក្នុងអត្ថបទគម្ពីរនេះ ៖ អារក្សនឹងរត់ចេញពីអ្នករាល់គ្នាទៅ ព្រះទ្រង់នឹងចូលមកចិត្តអ្នក រាល់គ្នា ហើយទ្រង់នឹងដំកើងអ្នករាល់គ្នាឡើង។

សេចក្ដីសន្យាអំពី ការដែលព្រះទ្រង់លើកដំកើងទៅកាន់អស់អ្នកដែលបន្ទាបខ្លួន ត្រូវនិយាយម្ដងហើយម្ដងទៀត ៤ ទៅ ៥ដង នៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ ការទទួលការលើកដំកើងមកពីព្រះ តាមរយៈការបន្ទាបខ្លួន គឺជាអ្វីបានយើងបានឃើញមាននៅក្នុងគំរូជីវិតរបស់ព្រះយេស៊ូវ ។ ទ្រង់បានបន្ទាបអង្គទ្រង់មកយក រូបភាពជាអ្នកបម្រើវិញ ទាំងចុះចូលស្ដាប់បង្គាប់ រហូតដល់ទីមរណៈ (ភីលីព ២:៥-៨)។ ហើយនៅ ពេលវេលាត្រឹមត្រូវបានមកដល់ ព្រះវរបិតាបានលើកដំកើងទ្រង់ឡើងយ៉ាងខ្ពស់  ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរ លើសជាងអស់ទាំងនាមផង (ភីលីព ២:៩-១១)។ ព្រះទ្រង់ត្រាស់ហៅយើងឲ្យដើរនៅក្នុងផ្លូវដូចគ្នានេះដែរគឺ ធ្វើការបន្ទាបខ្លួននៅសព្វថ្ងៃនេះ ក្រោយមកនឹងទទួលការលើកដំកើងពីព្រ ជារៀងរហូត។

**សំនួរឆ្លុះបញ្ជាំង**

- តើខ្ញុំកំពុងបន្ទាបខ្លួនទុកចិត្តទៅកាន់ព្រះគុណរបស់ព្រះ ថាទ្រង់នឹងលើកតំកើងខ្ញុំ ឬក៏ខ្ញុំកំពុងតែប្រឆាំងជាមួយទ្រង់ដើម្បីឲ្យបានតាមបំណងប្រាថ្នារបស់ខ្ញុំ?

## បម្រាមអំពីការថ្កោលទោស និង ការរអ្ហូតអាង

បងប្អូនអើយ កុំឲ្យនិន្ទាគ្នាឡើយ អ្នកណាដែលនិន្ទា ហើយថ្កោលទោសបងប្អូនខ្លួន នោះក៏និន្ទាហើយថ្កោលទោសចំពោះក្រិត្យវិន័យដែរ បើអ្នកថ្កោលទោសក្រិត្យវិន័យ នោះអ្នកមិនមែនកាន់តាមក្រិត្យវិន័យទេ គឺឈ្មោះថាជាអ្នកថ្កោលទោសវិញ

**៤:១១** អ្នកជឿព្រះ គឺដាច់ខាតមិនត្រូវនិយាយនិន្ទាគ្នាឡើយ (καταλαλέω) ឬនិយាយប្រឆាំងគ្នាទៅវិញទៅមកនោះទេ។ ភាសាក្រិកសម្រាប់ពាក្យ “អារក្សសាតាំង” (διαβόλῳ) មានន័យថាគឺអ្នកដែលនិយាយ

និន្ទា។ ដូច្នេះហើយការនិយាយនិន្ទានណាម្នាក់ គឺជាការលាតត្រដាងបញ្ហាចំបងខាងឯព្រលឹងវិញ្ញាណ។ ពេលដែលនិយាយនិន្ទានណាម្នាក់ មានន័យថាយើង កំពុងតែប្រព្រឹត្តខ្លួនដូចជាអារក្ស!។ ការដែលយើងនិយាយអាក្រក់ និន្ទាពីបងប្អូនប្រុសស្រីគ្រីស្ទានគឺនាំឲ្យមានបញ្ហាបី ៖

**ទី១ វាគឺជាការថ្កោលទោសបងប្អូនប្រុសស្រីរបស់យើង**។ នៅពេលដែលនិយាយនិន្ទានណាម្នាក់ នោះយើងនឹងចាប់ផ្តើមថ្កោលទោសពួកគេ។ តាមការពិតយើងមិនមានសិទ្ធក្នុងការថ្កោលទោសអ្នកដទៃនោះទេ។ ប្រសិនបើព្រះបានអត់ទោស និង លើកតម្កើងទៅកាន់អ្នកមានបាប ដែលបានប្រែចិត្តហើយ នេះបង្ហាញថា យើងមិនអាចថ្កោលទោសទៅកាន់អស់អ្នកដែលព្រះបានអត់ទោសឲ្យហើយនោះទេ។ បើយើងថ្កោលទោសពួកគេ នោះមានន័យថាយើងកំពុងបដិសេធទៅកាន់គ្រប់ការដែលព្រះអង្គបានធ្វើសម្រាប់ពួកគេ និង បដិសេធទៅកាន់សិទ្ធិអំណាចរបស់ទ្រង់ជាចៅក្រមជំនុំជំរះ។ មនុស្សមានបាបដែលបានបន្ទាបខ្លួននៅចំពោះព្រះ និងបានទទួលព្រះគុណរបស់ទ្រង់ហើយ មិនត្រូវលើកខ្លួនឡើងធ្វើចៅក្រមថ្កោលទោសអ្នកដទៃឡើយ។

**ទី២ វាគឺប្រឆាំងនឹងក្រឹត្យវិន័យរបស់ព្រះ**។ នៅពេលដែលយើងថ្កោលទោសអ្នកដ៏ទៃ យើងបានធ្វើខុសនៅក្រឹត្យវិន័យរបស់ព្រះដែលបានចែងថា គឺត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង(លេវីវិន័យ១៩:១៨) យើងមិនអាចនិយាយនិន្ទាហើយស្រលាញ់អ្នកដ៏ទៃក្នុងកំឡុងពេលតែមួយបានឡើយ។ ហេតុដូចនេះ នៅពេលដែលយើងនិយាយអាក្រក់ពីអ្នកដទៃ នោះយើងក៏កំពុងតែនិយាយប្រឆាំងជាមួយនឹងក្រឹត្យវិន័យរបស់ព្រះផងដែរ។ វាហាក់បីដូចជាយើងនិយាយថាក្រឹត្យវិន័យរបស់ព្រះមិនត្រឹមត្រូវអញ្ចឹង។ តួនាទីរបស់យើងគឺមិនមែនថ្កោលទោសក្រឹត្យវិន័យនោះទេ តែជាការស្តាប់បង្គាប់ក្រឹត្យវិន័យនោះវិញ។

ឯអ្នកដែលតែងក្រិត្យវិន័យ ហើយជំនុំជំរះផង នោះមានតែ១ទេ គឺជាព្រះ ដែលទ្រង់អាចនឹងជួយសង្គ្រោះ ឬបំផ្លាញក៏បាន ចុះតើអ្នកជាអ្វី ដែលថ្កោលទោសអ្នកដទៃនោះ។

**៤:១២ ទី៣ ការថ្កោលទោសគឺជាការប្រឆាំងនឹងព្រះ។** យើងកំពុងតែប្រព្រឹត្តរំលង និង ថ្កោលទោសទៅកាន់ក្រឹត្យវិន័យនៃសេចក្ដីស្រឡាញ់ ដែលជាក្រឹត្យវិន័យរបស់ព្រះ។ ទ្រង់គឺជាអ្នកប្រទានក្រឹត្យវិន័យ។ នៅពេលដែលយើងថ្កោលទោសអ្នកដទៃ យើងធ្វើដូចជាក្រឹត្យវិន័យទ្រង់មិនទាមទារឲ្យយើងអនុវត្តន៍ដូចអ្នកឯទៀតដែរ ហើយបដិសេធទៅកាន់សិទ្ធិអំណាចទ្រង់មកលើជីវិតរបស់យើង។ លើសពីនេះ នៅពេលដែលយើងថ្កោលទោសទៅកាន់អ្នកដទៃ យើងកំពុងលើកខ្លួនធ្វើតួនាទីរបស់ព្រះ ដែលមានតែទ្រង់ទេដែលសក្តិសមមានតួនាទីនេះ។ មានតែទ្រង់ទេគឺជាចៅក្រមដ៏ពិតតែមួយ។ មានតែទ្រង់ទេដែលមានអំណាចក្នុងការសង្គ្រោះជីវិត ឬ បំផ្លាញជីវិត។ នៅពេលយើងថ្កោលទោសអ្នកដទៃ យើងកំពុងតែប្រព្រឹត្តខ្លួនដូចជាព្រះ ហើយថាយើងមានសិទ្ធិអំណាច និង សមត្ថភាពផ្សេងៗ ដែលយើងគ្មាន។

ឥឡូវនេះ ឯពួកអ្នកដែលថា ថ្ងៃនេះ ឬថ្ងៃស្អែកយើងនឹងទៅឯក្រុងណាមួយ ហើយនឹងនៅស្រុកនោះអស់១ឆ្នាំ ដើម្បីនឹងរកស៊ីឲ្យបានចំណេញ

**៤:១៣** បន្ទាប់មកលោកយ៉ាកុបបង្រៀនយើងថា វាគឺជាការខុសឆ្គងក្នុងការរៀបចំផែនការនៃជីវិតរបស់យើងដោយគ្មានការចូលរួមរបស់ព្រះ។ ពួកយូដាតែងធ្វើដំណើរ ដើម្បីធ្វើការជួញដូរផ្សេងៗ។ សម្រាប់ជាឧទាហរណ៍លោកយ៉ាកុប បានលើកឡើងអំពីការរៀបចំផែនការធ្វើដំណើររបស់ពួកអ្នកជំនួញ ។ ពួកគេរៀបចំផែនការធ្វើអ្វីដែលពួកគេចង់ធ្វើ។ ពួកគេមានការរៀបចំ ពេលវេលាចាប់ផ្តើម (ថ្ងៃនេះឬថ្ងៃស្អែក) កំនត់ពីទីក្រុងណាដែលពួកគាត់ ពេលវេលាដែលត្រូវទៅ ហើយនិង គោលដៅ

(ពួកយើងនឹងធ្វើជំនួញដើម្បីបានប្រាក់ចំណេញ)។ ប៉ុន្តែ ព្រះអង្គមិនបានមានការរួមចំណែកនៅក្នុង ផែនការ របស់ពួកគេនោះទេ ដោយព្រោះពួកគេមិនទូលសូមឲ្យព្រះអង្គឲ្យធ្វើការដឹកនាំមកកាន់ផែនការ របស់ពួកគេ។ ពួកគេ បានសម្រេចចិត្ត ធ្វើដូចជា ពួកគេគឺជាអ្នកដែលមានអំណាចគ្រប់គ្រងទៅលើ អនាគត។

អ្នករាល់គ្នាមិនដឹងជានឹងកើតមានយ៉ាងណាដល់ថ្ងៃស្អែកទេ ដ្បិតជីវិតអ្នករាល់គ្នាជាអ្វី គឺជាចំហាយ ទឹកទេតើ ដែលឃើញតែ១ភ្លែត រួចបាត់ទៅ

**៤:១៤** ប៉ុន្តែអ្នកជំនួញទាំងនោះមិនបានដឹងថានឹងមានអ្វីកើតឡើងនៅឆ្នាំបន្ទាប់នោះទេ។ ជាការជាក់ ស្តែងនោះ ពួកគេមិនដឹងថាមានអ្វីកើតឡើងនៅថ្ងៃស្អែកផង! ពួកគេថែមទាំងមិនបានដឹងថាពួកគេអាច រស់ទៅដល់ឆ្នាំក្រោយ ឬអត់ផង។ ចំហាយទឹកគ្រប់ដណ្តប់មកលើដែនដី ហើយក៏រលាយបាត់នៅពេល ថ្ងៃ។ ជីវិតរបស់មនុស្សគឺដូចនេះ មាននៅទីនេះមួយភ្លែត ហើយមួយរំពេចក៏បាត់ទៅ។

គួរតែបាននិយាយដូច្នេះវិញថា បើយើងរស់នៅ ហើយព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យ នោះយើងនឹង ធ្វើការនេះ ឬការនោះ

**៤:១៥** លោកយ៉ាកុប គាត់មិនបាននិយាយថា ការរៀបចំផែនការគឺជាការខុសឆ្គងនោះទេ។ បញ្ហានោះគឺ យើងបានរៀបចំដោយមិនគ្មានការចូលរួមរបស់ព្រះ។ ពួកយើងត្រូវការព្រះដឹកនាំយើង។ មានតែព្រះជា ម្ចាស់ទេដែលជ្រាបពីអនាគត និង ជ្រាបដឹងថាអ្វីដែលល្អបំផុតសម្រាប់យើង។ ដូច្នេះហើយយើងគប្បី ស្វែងរកព្រះជាមុន មុនពេលដែលយើងរៀបចំផែនការ ហើយបន្ទាប់មកទុកចិត្តទ្រង់ចំពោះលទ្ធផល។

យើងមិនគួរនិយាយថា យើងនឹងធ្វើអ្វី។ ប៉ុន្តែយើងគួរនិយាយវិញថា "ពួកយើងនឹងធ្វើប្រសិនបើវាជាបំណងព្រះហឫទ័យរបស់ព្រះ"។ សាវកប៉ុលក៏បានធ្វើតាមគោលការណ៍នេះដែរ (កិច្ចការ ១៨: ២១; ១ កូរិនថូស ៤:១៩; ១ កូរិនថូស ១៦:៧)។ ហើយលោក យ៉ាកុបចង់ឲ្យយើងមានការបន្ទាបខ្លួនពឹងផ្អែកទៅលើព្រះជាម្ចាស់ ដោយដឹងថាពួកយើងត្រូវធ្វើការពឹង ផ្អែកទៅលើទ្រង់ គ្រប់ពេលវេលានៃជីវិតរបស់យើង។

តែឥឡូវនេះ អ្នករាល់គ្នាមានសេចក្ដីអំនួត អំពីពាក្យអួតអាងរបស់ខ្លួនដូច្នោះ ហើយគ្រប់ទាំងសេចក្ដីអំនួតយ៉ាងនោះ សុទ្ធតែអាក្រក់ទាំងអស់

**៤:១៦** ពួកអ្នកជំនួញមានជំនឿចិត្តលើខ្លួនឯង។ ពួកគេមានការជឿជាក់ថាពួកគេនឹងមានជោគជ័យដោយសារតែផែនការ និងការខិតខំប្រឹងប្រែងរបស់គេ។ ពួកគេបានរៀបចំផែនការ និង ប្រព្រឹត្តធ្វើដូចជាពួកគេមានសម្ថតភាពគ្រប់គ្រងអនាគតរបស់គេអញ្ចឹង។ សេចក្ដីអំនួតទាំងនេះសុទ្ធតែអាក្រក់ទាំងអស់។ យើងមិនគួរប្រកាសនិយាយមិនពិត ពីអ្វីដែលយើងអាចធ្វើបានឡើយ។ យើងមិនអាចគ្រប់គ្រងអនាគតបានទេ ហើយយើងមិនត្រូវនិយាយធ្វើឫកដូចជា យើងអាចគ្រប់គ្រងទៅកាន់អនាគតបាន។

ដូច្នេះ ឯអ្នកណាដែលចេះធ្វើល្អ តែមិនធ្វើសោះ នោះរាប់ជាបាបដល់អ្នកនោះវិញ។

**៤:១៧** អំពើបាបមិនមែនគ្រាន់តែជាការដែលប្រព្រឹត្តអំពើខុសឆ្គងនោះទេ។ តែវាក៏ជាការដែលបរាជ័យក្នុងការធ្វើអំពើត្រឹមត្រូវផងដែរ ។ យើងធ្វើបាបទាស់នឹងព្រះ នៅពេលណាដែលយើងមិនធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។ នៅពេលដែលព្រះអង្គបានត្រាស់ហៅយើងឲ្យធ្វើកិច្ចកាណា មួយបម្រើទ្រង់

យើងមិនត្រូវព្រងើយកន្តើយចំពោះការនោះទេ។ យើងគួរស្តាប់បង្គាប់ព្រះអង្គ ហើយ ត្រូវដឹងថាព្រះទ្រង់នឹងប្រទានពរមកកាន់ការស្តាប់បង្គាប់របស់យើង។

## ការព្រមានអំពីទ្រព្យសម្បត្តិ

ឥឡូវនេះ ពួកអ្នកមានអើយ ចូរយំសោកចុះ ព្រមទាំងស្រែកទ្រហោផង ដោយព្រោះសេចក្តីវេទនាដែលត្រូវមកលើអ្នករាល់គ្នា

**៥:១** បន្ទាប់មក លោកយ៉ាកុបបានសសេរអំពីការជំនុំជំរះដែលនឹងកើតមានឡើងដល់ពួកអ្នកមាន។ គាត់បានលើកហេតុផល៤យ៉ាង ដែលព្រះជាម្ចាស់ជំនុំជំរះពួកគេ។

ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នាបានពុករលួយ ហើយសំលៀកបំពាក់អ្នករាល់គ្នា ត្រូវកន្លាតកាត់អស់ហើយ មាសប្រាក់របស់អ្នករាល់គ្នាបានដុះស្នឹម ឯស្នឹមនោះ នឹងបានទុកសំរាប់ជាទីបន្ទាល់ ទាស់នឹងអ្នករាល់គ្នា ហើយនឹងស៊ីសាច់អ្នករាល់គ្នាដូចជាភ្លើង ដ្បិតអ្នករាល់គ្នាបានខំប្រមូលបង្គរទ្រព្យសម្បត្តិឡើងនៅជាន់ក្រោយបង្អស់នេះ

**៥:២-៣** ទោសទី១របស់អ្នកមានគឺពួកគេខំប្រមូលទ្រព្យសម្បត្តិលើសលុប រហូតដល់ពុកផុយរលួយ។ ពួកអ្នកមាន បានខំប្រមូលទ្រព្យសម្បត្តិ ៣ ប្រភេទ៖

- ពួកគេមានទ្រព្យច្រើន (πλοῦτος) ហើយសំដៅទៅលើទ្រព្យសម្បត្តិទាំងអស់។ របស់ទាំងនោះជាធម្មតារួមមាន គ្រាប់ធញ្ញជាតិ ប្រេង និង អាហារ។ ពួកគេបានខំប្រមូល របស់ទាំងនេះ ស្តុកទុក យូររហូតដល់របស់ទាំងនេះ ខូចពុករលួយ ប្រើការលែងកើត។

- ពួកគេមានសម្លៀកបំពាក់ច្រើន ហើយនេះគឺជាទ្រព្យមួយប្រភេទនៅក្នុងទ្រព្យសម្បត្តិនៅពេលនេះ។ មនុស្សក្រីក្រមានតែមួយកំផ្លេប៉ុន្នោះសម្រាប់ស្លៀកពាក់។ ហើយពួកអ្នកមានមានសម្លៀកបំពាក់ច្រើនពេក ដល់ថ្នាក់ពួកគេពាក់មិនអស់។ ពួកគេបានទុកសម្លៀកបំពាក់ទាំងនោះរហូតដល់កន្លាតកាត់អស់។
- ពួកគេមានមាសប្រាក់ ប៉ុន្តែមិនបានចាយវាយនោះទេ។ ឥឡូវនេះរបស់ទាំងអស់នោះបានដុះស្នឹមប្រលាក់ហើយកខ្វក់ផង។

ការលើកឡើងខាងលើគឺបានបញ្ជាក់យ៉ាងច្បាស់ថា ទ្រព្យសម្បត្តិនៅលើផែនដីនេះគឺមិនមានតម្លៃស្ថិតស្ថេររហូតអស់កល្បជានិច្ចនោះទេ។ ជាជាងដែលយើងខំប្រមូលទ្រព្យសម្បត្តិទាំងនេះ យើងត្រូវតែប្រើប្រាស់ ទ្រព្យសម្បត្តិដែលយើងមានសម្រាប់អ្វីៗ ដែលមានតម្លៃអស់កល្បជានិច្ច។ មនុស្សបានគិតថាទ្រព្យរបស់គេ និង ថែរក្សាការពារពួកគេ ប៉ុន្តែតាមពិតទៅ ទ្រព្យសម្បត្តិទាំងនោះនឹងធ្វើឲ្យពួកគាត់វិនាសវិញ។ ការដុះស្នឹម ច្រេះស៊ី និង ការពុករលួយនៃទ្រព្យសម្បត្តិរបស់ពួកគាត់ គឺជាទីបន្ទាល់ភស្តុតាងថាពួកគេ មិនបានត្រូវការវាណាស់ណានោះទេ ប៉ុន្តែពួកគាត់បានខំប្រឹងប្រមូលទុក ដោយសារភាពលោភលន់។ នេះគឺជាភស្តុតាងទាស់ប្រឆាំងចំពោះពួកគេ នៅពេលដែលពួកគេទទួលការជំនុំជំរះរបស់ព្រះ។

មើល ប្រាក់ឈ្នួល ដែលអ្នករាល់គ្នាបានបង្ខានចំពោះពួកជើងឈ្នួល ជាអ្នកច្រូតនៅស្រែរបស់អ្នករាល់គ្នានោះក៏ស្រែកឡើង ហើយសំរែកនៃពួកអ្នកដែលច្រូតនោះ បានឮទៅដល់ព្រះកាណ៌របស់ព្រះអម្ចាស់នៃពួកពលបរិវារដែរ

**៥:៤** ទោសទីពីរបស់គេនោះគឺមិនបានបង្ខានផ្តល់ប្រាក់ឈ្នួលដល់អ្នកច្រូតស្រែ។ ពួកគេបានបង្ខាន ប្រាក់ឈ្នួលដោយការបន្លំបំបាត់ និង ការបោកប្រាស់។ នៅពេលដែលពួកជើងឈ្នួលរមានទុក្ខវេទនា នោះ ពួកគេក៏ចាប់ផ្តើមស្រែកយំទៅព្រះជាម្ចាស់ ហើយសេចក្តីអធិស្ឋានរបស់ពួកគេក៏បានលឺដល់ព្រះ កាណ៍ទ្រង់។ ឃ្លាដែលលោកយ៉ាកុបបានប្រើ ពណ៌នាអំពីព្រះអង្គ គឺជា “ព្រះអម្ចាស់នៃពួកបរិវារ” មានន័យថា ទ្រង់គឺជាព្រះអង្គបញ្ជាការនៃពលទ័ពទេវតា។ ការដែលគាត់បានប្រើព្រះនាមមួយនេះរបស់ ព្រះ គឺដើម្បីប្រមានទៅកាន់ពួកអ្នក ដែលមានបានដោយសារភាពអយុត្តិធម៌។ ព្រះអង្គគឺជាព្រះដែល មានគ្រប់ទាំងព្រះចេស្តា។ ព្រះទ្រង់លឺ ហើយនឹងធ្វើកិច្ចការ ដោយអំណាចចេស្តាដ៏អស្ចារ្យរបស់ទ្រង់។

អ្នករាល់គ្នាបាននៅលើផែនដី បែបប្រសើររុងរឿង តាមតែចិត្តសំរើបស្រើប ទាំងចំអែតចិត្ត ដូចជានៅថ្ងៃ សំឡាប់សត្វ

**៥:៥** ទោសទីបីរបស់ពួកអ្នកមានគឺពួកគេបាននៅលើផែនដី បែបប្រសើររុងរឿង តាមតែចិត្តសំរើបស្រើប ទាំងចំអែតចិត្ត។ ពួកគេបាន “ចំអែតចិត្ត” ដោយការខំប្រមូលយកអ្វីៗ ដែលចិត្តពួកគេប្រាថ្នាចង់បាន។

អ្នករាល់គ្នាបានកាត់ទោស ក៏បានសំឡាប់មនុស្សសុចរិត តែគេមិនបានតយុទ្ធនឹងអ្នករាល់គ្នាវិញសោះ។

**៥:៦** ទោសទីបួនរបស់ពួកអ្នកមាននោះគឺ របៀបដែលពួកគេបានក្លាយជាអ្នកមាន។ ពួកគេបានរៀបចំ ឲ្យមានការសំឡាប់មនុស្សសុចរិត។ ភាសាក្រិកសម្រាប់ពាក្យ “កាត់ទោស” បង្ហាញថាមានការរួម ចំណែកនៃច្បាប់តុលាការ។ ពួកអ្នកមានបានប្រើអំណាចរបស់គេទៅតុលាការពុករលួយដើម្បីកាត់ ទោសទៅកាន់មនុស្សស្លូតត្រង់ ហើយកេងប្រវ័ញ្ចប្រាក់ឈ្នួល ឬ រឹបអូសយកដីធ្លីរបស់ពួកគេ។

ដោយសារតែ គ្មានធនធានដែលពួកគាត់ត្រូវការ មនុស្សជាច្រើនបានស្លាប់ដោយសារការអត់ឃ្លាន ឬ ដោយសារជំងឺ ដែលកើតឡើងដោយសារភាពក្រីក្រ។

បន្ទាប់ពីបានអានពីការហាមប្រាមរបស់លោកយ៉ាកុប យើងគួរគប្បីតែធ្វើការពិចារណាថា តើអ្វីជាឥរិយាបថត្រឹមត្រូវ ដែលយើងគួរមានចំពោះទ្រព្យសម្បត្តិ។ ទី១យើងត្រូវតែដឹងថាទ្រព្យសម្បត្តិទាំងអស់ជាកម្មសិទ្ធរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់បានឲ្យយើងកាន់កាប់ប្រើប្រាស់របស់ទ្រង់ ដើម្បីជាការថ្វាយសិរីល្អទៅកាន់ទ្រង់។ ដូច្នេះហើយយើងត្រូវតែប្រើប្រាស់អ្វីដែលយើងមាន ដើម្បីជាការថ្វាយកិត្តិយសដល់ព្រះ។ ទី២យើងត្រូវតែដឹងថា ជីវិតគឺត្រូវផ្ដោតទៅលើអ្វីដែលមានសារៈសំខាន់ជាងទ្រព្យសម្បត្តិមាសប្រាក់។ "រួចទ្រង់មានបន្ទូលទៅគ្រប់គ្នាថា ចូរប្រយ័ត ហើយខំចៀសពីសេចក្ដីលោភចេញ ដ្បិតជីវិតនៃមនុស្សមិនស្រេចនឹងបានទ្រព្យសម្បត្តិជាបរិបូរទេ" (លូកា ១២:១៥)។ ដូច្នេះ យើងត្រូវតែប្រុងប្រយ័ត្នមិនគួរងប់ងល់នឹងលុយកាក់នោះទេ ដែលវាដល់ថ្នាក់ក្លាយជា អ្វីដែលរំខាន យើងមិនឲ្យយើងធ្វើអ្វីដែលសំខាន់ៗនៅក្នុងជីវិត។ ទី៣ យើងត្រូវតែដឹងអំពីគ្រោះថ្នាក់ នៃទ្រព្យសម្បត្តិ។ ការនៅលើ ផែនដីបែបប្រសើររុងរឿង តាមតែចិត្តសំរើបស្រើប ទាំងចំអែតចិត្តនឹង បំផ្លាញចរិតលក្ខណៈមនុស្ស ហើយនាំឆ្ពោះទៅកាន់ការជំនុំជំរះ។ ហេតុនេះហើយយើងត្រូវតែ ប្រុងប្រយត្ន័កុំឲ្យធ្លាក់ខ្លួនជាអ្នកស្រឡាញ់លុយ។

**សំនួរឆ្លុះបញ្ចាំង**

- តើខ្ញុំកំពុងតែដើរតាមអ្វីនៅក្នុងជីវិតរបស់ខ្ញុំ ទ្រព្យសម្បត្តិមាសប្រាក់ ឬ ផែនការរបស់ព្រះ ?

## មានចិត្តអត់ធ្មត់ ដរាបដល់ព្រះអម្ចាស់ទ្រង់យាងមក

បងប្អូនអើយ ចូរមានចិត្តអត់ធ្មត់ ដរាបដល់ព្រះអម្ចាស់ទ្រង់យាងមក មើល អ្នកធ្វើស្រែ គេរង់ចាំផល វិសេស ដែលកើតពីដីមក ដោយសេចក្ដីអត់ធ្មត់ ទាល់តែបានភ្លៀងធ្លាក់មកខាងដើមរដូវ នឹងចុងរដូវផង

**៥:៧** ពួកអ្នកដែលបានអានសំបុត្ររបស់លោកយ៉ាកុបបានទទួលការបៀតបៀនពីពួកអ្នកមាន ហើយពួកគាត់ប្រហែលជាមានបំណងចង់សងសឹកទៅដល់ពួកគេវិញ។ ក៏ប៉ុន្តែលោកយ៉ាកុបបានប្រាប់ពួកគេឲ្យមានភាពអត់ធ្មត់រហូតដល់ព្រះទ្រង់យាងមក។ ពាក្យអត់ធ្មត់នៅក្នុងភាសាក្រិកនៅទីនេះ (μακροθυμέω) មានន័យថាការអត់ធ្មត់ជាមួយមនុស្ស ដែលមានន័យថាយើងត្រូវយឺតនឹងខឹង។ ពួកយើងគឺមិនត្រូវធ្វើការសងសឹកទៅកាន់អស់អ្នក ដែលបានធ្វើខុសមកលើយើងឡើយ។ ផ្ទុយទៅវិញ យើងត្រូវរង់ចាំព្រះយេស៊ូវនាំយកភាពយុត្តិធម៌មក នៅថ្ងៃដែលទ្រង់យាងមកវិញ។ ពាក្យការយាងមក បានបកប្រែនៅក្នុងភាសាក្រិកមានន័យថា ការយាងមកសួរសុខទុក្ខរបស់ព្រះមហាក្សត្រទៅទីក្រុង ឬ ខេត្ត ដែលនៅក្នុងនគររបស់ទ្រង់។ នៅពេលដែលព្រះយេស៊ូវយាងត្រលប់មកវិញ ទ្រង់នឹងយាងមក ក្នុងនាមជាស្ដេចនៃផែនដី។ ពួកយើងជាគ្រីស្ទបរិស័ទ្ធគឺទន្ទឹងរង់ចាំថ្ងៃទ្រង់យាងត្រលប់មកវិញ និងសិរីល្អ ដែលរងចាំយើង នៅពេលទ្រង់យាងមក ហើយការទាំងអស់នេះនឹងជួយឲ្យយើងមានការអត់ធ្មត់ជាមួយ នឹងបញ្ហា ហើយភាពអយុត្តិធម៌ក្នុងជីវិតនាពេលបច្ចុប្បន្ននេះ។

លោកយ៉ាកុបបានផ្ដល់ជាឧទាហរណ៍ ៣ សម្រាប់សេចក្ដីអត់ធ្មត់ រួមមាន កសិករ ពួកហោរា និង លោកយ៉ូប។

កសិករគឺជាឧទាហរណ៍នៃសេចក្ដីអត់ធ្មត់។ ពួកគេបានកាប់គាស់ដី ហើយសាបព្រោះ គ្រាប់ពូជ។ រួចបន្ទាប់មកពួកគេត្រូវរង់ចាំទឹកភ្លៀង។ នៅប្រទេសអ៊ីស្រាអែល ទឹកភ្លៀងចាប់ផ្ដើមធ្លាក់នៅខែតុលា និង វិច្ឆិកា។ បើគ្មានភ្លៀងនោះទេគ្រាប់ពូជនឹងមិនដុះលូតលាស់ឡើយ។ ហើយភ្លៀងចុងក្រោយគឺនៅខែ មេសា និង ឧសភា។ បើគ្មានភ្លៀងនេះ គ្រាប់ធញ្ញជាតិមិនអាចទុំបានដែរ។ រដូវភ្លៀងទាំង២មានសារៈ សំខាន់ខ្លាំងណាស់សម្រាប់ការប្រមូលយ៉ាងជោគជ័យ។ តាមរយៈការដឹងពីការនេះ កសិករសុខចិត្ត រង់ចាំអត់ធ្មត់រហូតដល់រដូវភ្លៀងទាំង២បង្អុរចុះមក។

ចូរឲ្យអ្នករាល់គ្នាអត់ធ្មត់ដូច្នោះដែរ ទាំងតាំងចិត្តឲ្យខ្ជាប់ខ្ជួនឡើង ដ្បិតព្រះអម្ចាស់ជិតយាងមកហើយ

**៥:៨** យើងគួរណាស់តែមានការអត់ធ្មត់ហើយមាន ការតាំងចិត្តឲ្យខ្ជាប់ខ្ជួនឡើង (ភាពរឹងមាំ)។ ការ មានភាពរឹងមាំ មានន័យថា ពង្រឹងចិត្តឲ្យមានភាពរឹងមាំ។ ការនេះមានន័យថាបន្តមានភាពរឹងមាំ ទោះបីជាប្រទះបញ្ហាការលំបាកក៏ដោយ។ ហេតុផលដែលយើងអាចឈររឹងមាំបានគឺដោយសារតែ ព្រះយេស៊ូវនឹងយាងត្រលប់មកវិញ។ ការដឹងជាក់ច្បាស់នៅក្នុងចិត្តថា ព្រះយេស៊ូវនឹងយាងមកវិញ ផ្ដល់នៅកម្លាំងចិត្តដល់អស់អ្នកដែលមានជំនឿលើទ្រង់ ហើយធ្វើឲ្យពួកគាត់បន្តរស់នៅសម្រាប់ទ្រង់។

បងប្អូនអើយ កុំឲ្យរទូរទាំទាស់នឹងគ្នាទៅវិញទៅមកឡើយ ក្រែងមានទោស មើលចៅក្រម លោកឈរនៅមាត់ទ្វារហើយ

**៥:៩** ការមានភាពអត់ធ្មត់ជាមួយអ្នកដទៃ មានន័យថាយើងមិន “រទូរទាំ” (រអ៊ូរទាំ)ទាស់ នឹងពួកគេ ឡើយ។ លោកយ៉ាកុបមិនមែនគ្រាន់តែហាមមិនឲ្យ ពួកគេមានការរអ៊ូរទាំនឹងអ្នកផ្សេងប៉ុណ្ណោះទេ

ប៉ុន្តែ ក៏ហាមមិនឲ្យពួកគេមានអារម្មណ៍ ល្វីងជូរចត់ ឬ តូចចិត្តនឹងគ្នា ដោយបង្ហាញចេញតាមរយៈ សម្រែកត្អូញ និង ការដកដង្ហើមធំ។ ការត្រឡប់មកវិញរបស់ព្រះយេស៊ូវ គឺជាជំនុំជម្រះប្រមានផង ហើយក៏ព្រឹត្តិការណ៍ដ៏រីករាយផង សម្រាប់គ្រីស្ទបរិស័ទ។ ព្រះយេស៊ូវនឹងយាងមកជំនុំជំរះលោកីយ៍នេះ ដោយភាពយុត្តិធម៌ ប៉ុន្តែទ្រង់ក៏នឹងជំនុំជំរះទៅកាន់គ្រីស្ទបរិស័ទ ដោយយោងតាមក្រឹត្យវិន័យនៃសេចក្តីស្រឡាញ់។ ដូច្នេះហើយ យើងមិនត្រូវអនុញ្ញាតឲ្យការល្បួងល ធ្វើឲ្យយើងលែងមានសេចក្តីស្រឡាញ់ ហើយរទូរទាំ ទាស់នឹងគ្នាទៅវិញទៅមកនោះឡើយ។

បងប្អូនអើយ ចូរយកពួកហោរា ដែលបានទាយដោយនូវព្រះនាមព្រះអម្ចាស់ ទុកជាគំរូពីសេចក្តីទុក្ខលំបាក នឹងពីសេចក្តីអត់ធ្មត់ចុះ

**៥:១០** សម្រាប់ការលើកទឹកចិត្តដល់អ្នកអានសំបុត្រ របស់គាត់ឲ្យមានសេចក្តីអត់ធ្មត់ ក្នុងសេចក្តីទុក្ខលំបាក លោកយ៉ាកុបបានលើកពីគំរូរបស់ពួកហោរា នៅក្នុងគម្ពីរសញ្ញាចាស់។ ពួកហោរានៅសញ្ញាចាស់បានប្រកាស ព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលជាញឹកញាប់មានទាំង ការជំនុំជំរះ ដែលនឹងមកដល់ ហើយការហៅឲ្យមនុស្សធ្វើការប្រែចិត្ត។ ដោយសារតែពួកហោរាធ្វើការទាំងនេះ មនុស្សដែលបានឮពីការទាំងនេះមានការខឹងសម្បាយ៉ាងខ្លាំង។ ពេលជាច្រើនឆ្នាំអាចកន្លងផុតទៅ មុនពេលដែលទំនាយទាំងនេះបានសម្រេចឡើង ពួកហោរាទទួលការរងទុក្ខលំបាក និង ការបៀតបៀននៅក្នុងកំឡុងពេលទាំងនោះ។ ពួកគេនៅតែបន្តអត់ធ្មត់ នៅក្នុងសេចក្តីទុក្ខលំបាករបស់ពួកគាត់ ហើយទុកចិត្តព្រះអម្ចាស់ ថាទ្រង់នឹងរក្សាពួកគាត់ រហូតដល់ពេលដែលព្រះបន្ទូលរបស់ទ្រង់បានសម្រេចឡើង ឬ រហូតដល់ពេល ដែលសេចក្តីទុក្ខលំបាកបានចប់។ ពួកយើងក៏គួរធ្វើដូចពួកគាត់ដែរ។

មើល យើងហៅពួកអ្នកដែលទ្រាំទ្រ ថាជាអ្នកមានពរ ចុះអ្នករាល់គ្នាបានឮនិយាយពីសេចក្ដីអត់ធន់ របស់លោកយ៉ូបទៅហើយ ក៏បានឃើញថាដល់ចុងបំផុត នោះព្រះអម្ចាស់ទ្រង់មានព្រះហឫទ័យ មេត្តាករុណា នឹងសេចក្ដីអាណិតអាសូរពោរពេញដែរ

**៥:១១** លោកយ៉ូប គឺជាជនគំរូបន្ទាប់។ ទោះបីគាត់បានឆ្លងកាត់បញ្ហាជាច្រើន លោកយ៉ូបមិនដែល បាត់បង់នៅជំនឿរបស់គាត់លើព្រះអម្ចាស់នោះទេ។ គាត់បានរងទុក្ខជាច្រើនក្នុងការ ល្បងលធំៗជា ច្រើន ហើយមានការតស៊ូពុះពារ ថែមទាំងសួរសំនួរជាច្រើនទៅកាន់ព្រះ។ ក៏ប៉ុន្តែលោកបានជឿដល់ ទ្រង់ទោះបីជាលោកមិនយល់ថាហេតុអ្វីបានជា លោកត្រូវជួបជាមួយនឹងសេចក្ដីទុក្ខវេទនា។ លោក យ៉ាកុបបានជំរុញស្នើរសុំឲ្យអ្នកអានសំបុត្ររបស់គាត់ឲ្យធ្វើដូចជាលោកយ៉ូប ហើយទុកចិត្តលើព្រះអង្គ នៅក្នុងគ្រប់ទាំងបញ្ហាការលំបាក។ លោកយ៉ាកុបបានប្រើពាក្យ ὑπομονήν ម្ដងទៀត (មើលនៅ ចំនុច ១:៣) នេះជាសេចក្ដីខ្ជាប់ខ្ជួន អត់ធន់ របស់លោកយ៉ូប ដែលពួកយើងត្រូវការមាននៅក្នុងជីវិតយើង។

ព្រះជាម្ចាស់មានផែនការចំពោះការរងទុក្ខវេទនា របស់លោកយ៉ូប។ តាមរយៈការរងទុក្ខវេទនារបស់គាត់ លោកយ៉ូបកាន់តែស្គាល់ព្រះជាម្ចាស់ច្បាស់ជាងមុន។ នៅពេលដែលការល្បងលបានមកដល់ពីបញ្ចប់ ព្រះទ្រង់បានសម្រេចកិច្ចការដ៏អស្ចារ្យ ហើយលទ្ធផលនៃកិច្ចការនោះ គឺលោកយ៉ូបបានក្លាយជាមនុស្ស មានភាពល្អប្រសើរជាងមុន និង មានព្រះពរច្រើនជាងមុន។ យើងចងចាំថាលោកយ៉ូបគឺជាមនុស្សល្អ តាំងពីដើមនៃសៀវភៅ ប៉ុន្តែនៅចុងបញ្ចប់នៃសៀវភៅគាត់បានក្លាយជាមនុស្សកាន់តែប្រសើរជាង មុនទៅទៀត។ លោកមានចរិកលក្ខណៈល្អប្រសើរជាងមុន មានការបន្ទាបខ្លួនច្រើនជាមុន ហើយបាន ទទួល ព្រះពរច្រើនជាងមុន។ ព្រះទ្រង់មានសេចក្ដីអាណិតអាសូរ និង សេចក្ដីមេត្តាដល់លោកយ៉ូប។ ហើយនៅចុងបញ្ចប់លោកទទួលព្រះពរទ្វេរគុណ បើប្រៀបធៀបទៅនឹងអ្វីដែលលោកមាន មុនពេល

ដែលសេចក្តីទុក្ខលំបាកបានចូលមកក្នុងជីវិតរបស់លោក។ មេរៀនសម្រាប់អ្នកជឿគ្រប់រូប នោះគឺ ព្រះទ្រង់ធ្វើកិច្ចការតាមរយៈការរងទុក្ខលំបាករបស់យើង ដើម្បីនាំការល្អមកកាន់ពួកយើង។ ហើយនៅចុងបញ្ចប់ ប្រសិនបើយើងនៅតែរក្សាការទុកចិត្តរបស់យើងលើទ្រង់ ព្រះអង្គទ្រង់នឹងប្រទាន រង្វាន់ និង ប្រទានពរមកកាន់យើង។

តែបងប្អូនអើយ កុំឲ្យស្បថជាដើម ទោះបើនឹងស្ថានសួគ៌ ឬនឹងផែនដីក្តី ក៏កុំឲ្យស្បថយ៉ាងណាឲ្យសោះ តែឲ្យពាក្យ «បាទ» របស់អ្នករាល់គ្នា បាននៅតែ «បាទ» ហើយពាក្យ «ទេ» នៅតែ «ទេ» ដដែល ក្រែងអ្នករាល់គ្នាធ្លាក់ទៅជាមានទោស។

**៥:១២** មនុស្សប្រើពាក្យស្បថដើម្បីទូលសូមឲ្យព្រះធ្វើជាសាក្សី ចំពោះអ្វីដែលខ្លួនកំពុងនិយាយ។ មនុស្សបានប្រើពាក្យសម្បថដើម្បីបង្ហាញថាពួកគេពិតជានិយាយការពិត។ យ៉ាងណាមិញ វាជាទម្លាប់របស់សាសន៍យូដាក្នុងការយកអ្វីគ្រប់យ៉ាងមកស្បថ លើកលែងតែព្រះនាមរបស់ព្រះអម្ចាស់ (ហើយគ្រាន់តែចំនុចនេះ អាចរាប់បានថាជាការជាសច្ចានុម័ត)។ ដូច្នេះ ពាក្យសម្បថត្រូវបានប្រើប្រាស់សម្រាប់ជាការបោកបញ្ឆោតទៅកាន់មនុស្ស។ ដូចនេះលោកយ៉ាកុប បានលើកឡើងពីអ្វីដែលព្រះយេស៊ូវបានមានបន្ទូលដើម្បីកុំឲ្យអ្នកអានរបស់គាត់ ប្រើប្រាស់ពាក្យសម្បថ (ម៉ាថាយ ៥:៣៣-៣៧)។ ពួកគេគួរនិយាយជាមួយគ្នាទៅវិញទៅមកដោយភាពស្មោះត្រង់ និង ពាក្យទៀងត្រង់។ គ្រីស្ទបរិស័ទ្ធគួរធ្វើជាមនុស្ស ដែលមានពាក្យសំដីគួរឲ្យទុកចិត្តបាន។

## **អំណាចនៃការអធិស្ឋាន**

តើមានពួកអ្នករាល់គ្នាណា កើតទុក្ខលំបាកឬទេ ត្រូវឲ្យអ្នកនោះអធិស្ឋាន តើមានអ្នកណាអរសប្បាយឬទេ ត្រូវឲ្យគេច្រៀងសរសើរដល់ព្រះចុះ

**៥:១៣** មិនថាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយយើងគួរតែទៅបែររកព្រះជានិច្ច។ នៅពេលដែលយើងជួបប្រទះបញ្ហាការលំបាក ការល្អបំផុតដែលយើងអាចធ្វើបានក្នុងការឆ្លើយតបទៅកាន់ការទាំងនោះ គឺជាការដែលយើងស្វែងរកការកំសាន្តចិត្តមកពីទ្រង់ និងសុំប្រាជ្ញាមកពីទ្រង់តាមរយៈការអធិស្ឋាន ។ ហើយនៅពេលដែលយើងសប្បាយរីករាយ អ្វីល្អបំផុតដែលយើងគួរធ្វើ គឺជាការសរសើរតម្កើងព្រះ។ គ្រិស្តបរិស័ទគួរគប្បីសំលឹងមើលទៅព្រះនៅក្នុងគ្រប់កាលៈទេសៈ ទោះបីជីវិតកំពុងជួប ការល្អ ឬ ការមិនល្អ មិនថាយើងមានអារម្មណ៍សប្បាយ ឬ មិនសប្បាយចិត្តក៏ដោយ។

តើមានពួកអ្នករាល់គ្នាណាឈឺឬទេ ត្រូវឲ្យអ្នកនោះហៅពួកចាស់ទុំក្នុងពួកជំនុំមកអធិស្ឋានឲ្យចុះ ព្រមទាំងលាបប្រេងឲ្យ ដោយនូវព្រះនាមព្រះអម្ចាស់ផង

**៥:១៤** ពាក្យឈឺត្រូវបានបកប្រែ (ἀσθενεῖ) គឺមានន័យថាដោយខ្សោយកម្លាំង។ នៅពេលដែលគ្រិស្តបរិស័ទមានអារម្មណ៍ថាពួកគេខ្សោយកម្លាំង ពួកគេត្រូវតែសុំជំនួយពីពួកចាស់ទុំក្នុងក្រុមជំនុំរបស់ ពួកគេឲ្យមកអធិស្ឋានសម្រាប់ពួកគេ។ ហើយពួកចាស់ទុំនឹងដាក់ប្រេងនៅលើបុគ្គលនោះ ដោយនូវព្រះនាមរបស់ព្រះអម្ចាស់។ នេះគឺជាការទូលសូមឲ្យព្រះធ្វើការ ដោយព្រោះថាទ្រង់ហើយ គឺជាប្រភពនៃអស់ទាំងការព្យាបាល។

នោះពាក្យអធិស្ឋាននៃសេចក្តីជំនឿ នឹងជួយសង្គ្រោះដល់មនុស្សហេវនោះ ហើយព្រះអម្ចាស់ទ្រង់នឹងប្រោសឲ្យគាត់បានជាឡើង បើគាត់បានធ្វើបាបអ្វី នោះនឹងបានអត់ទោសឲ្យផង

**៥:១៥** ការពិតដែលមនុស្សឈឺ ហើយបានសុំកោះហៅឲ្យពួកចាស់ទុំមក នោះគឺជាការបង្ហាញពី សេចក្តីជំនឿ ដែលនេះហើយ គឺជាលក្ខខណ្ឌសម្រាប់ឲ្យមានការអធិស្ឋានដ៏ខ្លាំងពូកែ។ ពួកចាស់ទុំត្រូវតែមានជំនឿថា ព្រះទ្រង់នឹងឆ្លើយតបមកកាន់សេចក្តីអធិស្ឋានរបស់ពួកគាត់។ ហើយប្រសិនបើ អំពើបាប គឺជាអ្វីដែល បណ្តាលឲ្យបុគ្គលនោះឈឺ ព្រះទ្រង់នឹងអត់ទោសអំពើបាបនោះ។ ពាក្យថា "ប្រសិនបើ" បង្ហាញឲ្យឃើញច្បាស់ថាមិនគ្រប់ទាំងជំងឺទាំងអស់កើតឡើងដោយសារអំពើបាបនោះទេ។ យើងត្រូវដឹងថា ពួកចាស់ទុំគ្មានអំណាចក្នុងការអត់ទោសបាបឲ្យមនុស្សនោះទេ គឺមានតែព្រះអង្គទេ ដែលមានអំណាចក្នុងការអត់ទោសបាបឲ្យមនុស្ស។

ដូច្នេះ ចូរឲ្យអ្នករាល់គ្នាលន់តួទោសនឹងគ្នា ហើយអធិស្ឋានឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យបានជាចុះ ដ្បិតសេចក្តីទូលអង្វរដ៏អស់ពីចិត្តរបស់មនុស្សសុចរិត នោះពូកែណាស់

**៥:១៦** ពេលខ្លះការប្រកាសលន់តួអំពើបាប គឺជាផ្នែកនៅក្នុងដំណើរការនៃការព្យាបាល។ នៅពេលដែលយើងលន់តួសារភាពអំពើបាបរបស់យើងទៅកាន់គ្នាទៅវិញទៅមក ហើយអធិស្ឋាន នោះព្រះទ្រង់នឹងប្រទានការព្យាបាលមកកាន់យើង។ ពេលយើងសារភាពលន់តួអំពើបាបរបស់យើង ព្រះអង្គនឹងអត់ទោសបាបឲ្យយើង។ អស់អ្នកណា ដែលព្រះអង្គបានអត់ទោសឲ្យ ទ្រង់ក៏បានរាប់ពួកគេជាសុចរិតដែរ។ នៅពេលដែលមនុស្សសុចរិត អធិស្ឋានទៅកាន់ព្រះ ការអស្ចារ្យអាចកើតឡើងបាន។ ការអធិស្ឋានមាន

អំណាច និង ប្រសិទ្ធិភាព ដោយសារតែព្រះទ្រង់មានអំណាចព្រះចេស្តា ហើយកិច្ចការដែលទ្រង់ធ្វើមានប្រសិទ្ធិភាព។ ព្រះអង្គអាចធ្វើការអស្ចារ្យធំ ដើម្បីជាការឆ្លើយតបទៅកាន់សេចក្តីអធិស្ឋាន។

ឯហោរាអេលីយ៉ា លោកមានចិត្តដូចជាយើងដែរ តែលោកបានអធិស្ឋាន សូមកុំឲ្យមានភ្លៀងនោះនៅផែនដីក៏រាំងអស់រវាង៣ឆ្នាំ៦ខែ រួចលោកបានអធិស្ឋានម្តងទៀត នោះមេឃក៏បង្អុរភ្លៀងធ្លាក់មក ហើយដីបានបង្កើតផលផ្លែឡើង។

**៥:១៧-១៨** លោកយ៉ាកុបបានប្រើហោរាអេលីយ៉ា ជាគំរូបង្ហាញពីអំណាចនៃសេចក្តីអធិស្ឋាន។ លោកអេលីយ៉ាបានអធិស្ឋានដោយចិត្តក្លៀវក្លា ហើយបន្ទាប់មកគាត់បានប្រកាសមិនឲ្យមានភ្លៀង រហូតដល់ពេល ដែលគាត់នឹងប្រកាសឲ្យមានភ្លៀងវិញ (១ ពង្សាវតាក្សត្រ ១៧: ១) ព្រះអង្គបានឆ្លើយតបទៅកាន់សេចក្តីអធិស្ឋានរបស់គាត់ ធ្វើឲ្យពេលនោះគ្មានភ្លៀងរយៈពេល ៣ឆ្នាំកន្លះ។ បន្ទាប់ពីពេលវេលានោះបានកន្លងផុតទៅ គាត់បានអធិស្ឋានម្តងទៀត ហើយភ្លៀងក៏បានធ្លាក់ចុះមក (១ ពង្សាវតាក្សត្រ ១៨: ៤១-៤៥)។

លោកអេលីយ៉ា គឺជាមនុស្សធម្មតាដូចជាយើងដែរ។ លោកគឺមិនមានអំណាចអ្វីពិសេសសម្រាប់គ្រប់គ្រងលើធម្មជាតិនោះទេ។ តែអំណាចនោះគឺជារបស់ព្រះអម្ចាស់ ហើយទ្រង់នេះហើយដែលលោកអេលីយ៉ាបានអធិស្ឋានសូមឲ្យទ្រង់ធ្វើការអស្ចារ្យ។ គាត់បានទុកចិត្តទាំងស្រុងទៅកាន់ព្រះ ហើយទ្រង់បានឆ្លើយតបទៅកាន់សេចក្តីអធិស្ឋានរបស់គាត់។ ហើយនេះគឺជាការពិត ដែលអាចកើតឡើងមកកាន់យើងផងដែរ។ លោកយ៉ាកុបចង់ឲ្យអ្នកអាន សំបុត្ររបស់គាត់ ដឹងថាអស់អ្នកណាដែលមានទំនាក់ទំនងត្រឹមត្រូវជាមួយនឹងព្រះ ពួកគេអាចអធិស្ឋាន សេចក្តីអធិស្ឋានដែលពេញដោយអំណាចចេស្តា។

បងប្អូនអើយ បើមានអ្នកណាក្នុងពួកអ្នករាល់គ្នា គេវង្វេងចេញពីសេចក្ដីពិត ហើយមានអ្នកណា នាំអ្នកនោះឱ្យត្រឡប់មកវិញ

**៥:១៩** មនុស្សមួយចំនួនមកព្រះវិហារបានតែមួយរយៈពេលខ្លីប៉ុណ្ណោះ ពួកគេបានលឺអំពីសេចក្ដីពិត តែបន្ទាប់មកពួកគេ ក៏បានវង្វេងចេញពីសេចក្ដីពិត។ ពេលដែលពួកគេបានវង្វេងចេញទៅ ពួកយើងត្រូវតែព្យាយាមហៅ នាំពួកគេឲ្យត្រលប់មករកសេចក្ដីពិតវិញ។ លោកយ៉ាកុបតែងតែរជាមនុស្សដែលមាន ការអនុវត្តន៍ជាក់ ស្តែងជានិច្ច គាត់មិនបានសួរសំនួរថា ហេតុអ្វីបានជាពួកគេបានវង្វេងចេញនោះទេ គាត់គ្រាន់តែប្រាប់ពួកយើងឲ្យទៅនាំពួកគេឲ្យប្រលប់វិញតែប៉ុណ្ណោះ។

នោះត្រូវដឹងថា អ្នកណាដែលនាំមនុស្សបាប ឲ្យត្រឡប់ពីផ្លូវវង្វេងមកវិញ នោះឈ្មោះថា បានជួយសង្គ្រោះព្រលឹង១ ឲ្យរួចពីសេចក្ដីស្លាប់ ហើយក៏គ្របបាំងអំពើបាបជាអនេកអនន្តផង។:៙៚

**៥:២០** អស់អ្នកណាដែលវង្វេងចេញពីសេចក្ដីពិត គឺកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់។ នៅពេលដែលអំពើបាបបានធំឡើងពេញលេញហើយ នោះវានឹងបណ្ដាលឲ្យមានសេចក្ដីស្លាប់។ លោកយ៉ាកុបនិយាយសំដៅលើសេចក្ដីស្លាប់ដ៏អស់កល្បជានិច្ច នោះគឺជា "សេចក្ដីស្លាប់លើកទីពីរ" នៅក្នុងស្ថាននរក (វិវរណៈ ២០:១១-១៥, ២១:៨)។ ការដែលដឹងថាវាគឺជាគ្រោះថ្នាក់យ៉ាងធំធេងទៅកាន់ អស់អ្នកណាដែលវង្វេង ចេញពីសេចក្ដីពិត គួរលើកទឹកចិត្តគ្រីស្ទបរិស័ទ្ធឲ្យមានភាពស្វះស្វែងទៅតាមរកអស់អ្នកណាដែលបានវង្វេងចេញពីសេចក្ដីពិត។

ការនាំនរណាម្នាក់ឲ្យត្រលប់មកសេចក្តីពិត គឺជាកិច្ចការយ៉ាងល្អប្រពៃ។ នៅពេលដែលពួកគាត់បានប្រែចិត្ត នោះនឹងមានការគ្រប់បាំងទៅលើអំពើបាបរបស់ពួកគាត់យ៉ាង អនេកអនន្ត។ លោកយ៉ាកុប កំពុងតែសំដៅទៅលើការធួនបាប ឬ ការលោះបាប។ នៅក្នុងភាសាហេព្រើរ មានន័យថា "ការគ្របបាំង"។ វាគឺជាការពណ៌នាអំពីកិច្ចការដែល សម្តេចសង្ឃធ្វើ ហើយនោះគឺជាការគ្របបាំង (ថ្វាយឲ្យធួននឹង) បាបរបស់បណ្តាមនុស្ស ដោយការឈាមមកលើអាសនា (និក្ខមនំ ៣០:១០; លេវីវិន័យ ១៧:១១)។ ឥឡូវព្រះលោហិតរបស់ព្រះយេស៊ូវបានធួននឹងអំពើបាប ហើយថែមទាំងគ្របបាំងអំពើរបស់អ្នកជឿដែលរស់នៅក្នុងការប្រែចិត្ត។ ព្រះគុណរបស់ព្រះគឺ មានសម្រាប់មនុស្សទាំងអស់ គឺអស់អ្នកដែលបែរចេញពីអំពើបាបរបស់ខ្លួន ហើយទុកចិត្តលើ ព្រះយេស៊ូវគ្រីស្ទ។ ព្រះទ្រង់នឹងទទួលស្គាល់ទៅកាន់ការប្រែចិត្តរបស់ពួកគេ ហើយនឹងអត់ទោស ទៅកាន់អំពើបាបរបស់ពួកគេព្រមទាំងសង្គ្រោះពួកគេផងដែរ។

**សំនួរឆ្លុះបញ្ចាំង**

- តើមាននរណាម្នាក់ ដែលខ្ញុំអាចអធិស្ឋានឲ្យ ហើយជួយឲ្យគាត់ត្រលប់មករកសេចក្តីពិតវិញដែរឬទេ?